# ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២

## រាជរដ្ឋាភិបាល

## ស្វែងរក និងផ្តល់ឱកាសការងារដល់ពលករ ធ្វើការនៅក្រៅប្រទេសជាង ១លាននាក់

https://dap-news.com/ ByDR103Posted on May 1, 2022

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា បានថ្លែងថា មកដល់ពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា ខិតខំស្វែងរក និងផ្តល់ឱកាសការងារដល់ពលករធ្វើការងារ នៅក្រៅប្រទេសសរុប ចំនួន ១,៣០១,៦០៩នាក់។ តាមរយៈសារលិខិតរបស់រាជរដ្ឋាភិបាល ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣៦ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ឧសភា ក្រោមប្រធានបទ «សន្តិភាព សុខភាព និងសន្តិសុខការងារ» សម្តេចតេជោ ហ៊ុន សែន បានឲ្យដឹងថា រាជរដ្ឋាភិបាល ក៏កំពុងបន្តជំរុញការអនុវត្តគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារ សម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងការការពារ និងលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍ពលករ ទាំងការទទួលបានកិច្ចគាំពារសង្គម ក្នុងពេលបម្រើការងារ និងពេលត្រឡប់មកស្រុកកំណើតវិញ។ សម្តេចតេជោ បានថ្លែងបញ្ជាក់ថា «រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ឱកាសការងារ ដល់ពលករធ្វើការងារ នៅក្រៅប្រទេសសរុបចំនួន១,៣០១,៦០៩នាក់។ ប្រទេសថៃមានចំនួន១,២២០,១៩៧នាក់, កូរ៉េ ៤៥,៨៦៦នាក់, ម៉ាឡេស៊ី ២៣,០២៧នាក់, ជប៉ុន ១១,៤៥៣នាក់, សិង្ហបុរី៨២១នាក់, ហុងកុង ២០២នាក់ និងអារ៉ាប់ប៊ីសាអូឌីត ៤៣នាក់»។

សម្តេចតេជោ បានបន្តថា បើតាមការប៉ាន់ប្រមាណពីប្រាក់បញ្ញើ ដែលពលករបានផ្ញើជូនក្រុមគ្រួសារ ក្នុង១ឆ្នាំៗជាច្រើនពាន់លានដុល្លារអាមេរិក ដែលតាមរយៈទឹកប្រាក់ទាំងនេះ បានចូលរួមចំណែកជំរុញដល់កំណើនសេដ្ឋកិច្ច ហើយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករ កាន់តែប្រសើរឡើងផងដែរ។ ក្នុងសារលិខិតដដែល សម្តេចតេជោ ហ៊ុន សែន ក៏បានលើកឡើងថា ក្រៅពីការខិតខំការពារសិទ្ធិ-ផលប្រយោជន៍ ពង្រឹងសន្តិសុខការងារ សុខភាព ការដំឡើងប្រាក់ឈ្នួលអប្បបរមា និងការគាំពារផ្សេងទៀត ជូនកម្មករនិយោជិតនោះ រាជរដ្ឋាភិបាលក៏បានចំណាយថវិកាប្រមាណជិត ២៨លានដុល្លារ ផ្តល់ជូនស្ត្រីសម្រាលកូន ដែលមានចំនួនប្រមាណជាង២៨ម៉ឺននាក់ គិតចាប់ពីឆ្នាំ២០១៨-២០២១ តាមរយៈបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)។ សម្តេចតេជោ បញ្ជាក់ថា «បើគិតចាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២១ ស្ត្រីសម្រាលកូនមានចំនួន២៨២,០៧៣នាក់ ដោយចំណាយថវិកាសរុបចំនួន១១៣.៦ប៊ីលានរៀល (ប្រមាណ២៧.៧លានដុល្លារអាមេរិក)»៕

## តើមកដល់ពេលនេះ

## មានពលករកម្ពុជា ទៅធ្វើការនៅក្រៅប្រទេស ប៉ុន្មាននាក់? និងនៅប្រទេសណាខ្លះ?

https://kohsantepheapdaily.com.kh/ ភ្នំពេញ២៨ ខែ មេសា ឆ្នាំ ២០២២ ម៉ោង ២២:១៣

ភ្នំពេញ៖ ពលករកម្ពុជា បានធ្វើការងារនៅក្រៅប្រទេស សរុប ចំនួន ១ ៣០១ ៦០៩នាក់។ ក្នុងនោះ នៅប្រទេសថៃ ចំនួន ១ ២២០ ១៩៧នាក់ កូរ៉េ ៤៥ ៨៦៦នាក់ ម៉ាឡេស៊ី ២៣ ០២៧នាក់ ជប៉ុន ១១ ៤៥៣នាក់ សិង្ហបុរី ៨២១នាក់ ហុងកុង ២០២នាក់ និងអារ៉ាប់ប៊ីសាអូឌីត ៤៣នាក់។

តួលេខពលករកម្ពុជា ចេញទៅធ្វើការដោយស្របច្បាប់ នៅក្រៅប្រទេសខាងលើនេះ ត្រូវបានលើកបង្ហាញក្នុងសារលិខិតរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងឱកាសខួបអនុស្សាវរីយ៍ លើកទី១៣៦ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២។ សារលិខិតដដែល លើកឡើងថា បើតាមការប៉ាន់ប្រមាណពីប្រាក់បញ្ញើ ដែលក្នុងយុ ពលករធ្វើការនៅក្រៅប្រទេស បានផ្ញើជូនក្រុមគ្រួសារ ក្នុង ១ឆ្នាំៗ ជាច្រើនពាន់លានដុល្លារ

អាម៉េរិក ដែលតាមរយៈទឹកប្រាក់ទាំងនេះ បានចូលរួមចំណែកជំរុញដល់កំណើនសេដ្ឋកិច្ច ហើយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករ កាន់តែប្រសើរឡើងផងដែរ៕

## ទាហានឈុតខ្មៅថៃ និងទាហានខ្មែរ ជួបពិភាក្សាគ្នា ប្តេជ្ញារួមគ្នាទប់ស្កាត់រាល់បទល្មើសឆ្លងដែន ពិសេសមនុស្សឆ្លងដែនទៅមក

http://freshnewsasia.com/ 2022-04-29 12:01pm

**(បន្ទាយមានជ័យ)៖** ទាហានឈុតខ្មៅថៃ ១ក្រុម និងទាហានខ្មែរ ១ក្រុម បានជួបពិភាក្សាគ្នា ដើម្បីរឹតចំណងសាមគ្គីភាព មិត្តភាព និងរួមគ្នាទប់ស្កាត់រាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ពិសេសមនុស្សឆ្លងដែនទៅមករកការងារធ្វើ។ ជំនួបនេះ ធ្វើឡើងនៅល្ងាចថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ នៅចំណុចមាត់អូរព្រំដែនដីថៃ ស្ថិតក្នុងភូមិគុតហ៊ីន ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ចំណែកភាគីខ្មែរទល់មុខភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ បើតាមលទ្ធផលជំនួប កិច្ចពិភាក្សាគ្នានោះ ផ្តោតទៅលើការទប់ស្កាត់ការលួចឆ្លងដែនតាមច្រករបៀងរបស់ពលករខ្មែរ និងប្រជាជនថៃ ឆ្លងដែនមកធ្វើការនៅក្រុងប៉ោយប៉ែត ព្រោះប្រទេសថៃ នៅតែធ្វើការទប់ស្កាត់កូវីដ១៩ នៅឡើយ ខណៈរោងចក្រថៃត្រូវបិទ ហើយរហូតមកដល់សព្វថ្ងៃនេះប្រទេសថៃមិនទាន់ដំណើរការដូចមុននោះទេ ព្រោះកូវីដ១៩ មិនទាន់បានធូរស្បើយ។ ប្រជាជនថៃ នៅតែមានការប្រុងប្រយ័ត្នទាំងអស់គ្នាជានិច្ច ពោលគឺអ្វីៗមិនទាន់ដំណើរការ នៅឡើយទេ ដូច្នេះពលករខ្មែរទាំងអស់ចង់មកធ្វើការនៅថៃ ងាយនឹងចាញ់បោកមេខ្យល់។ លទ្ធផលជំនួប បានឲ្យដឹងទៀតថា សព្វថ្ងៃនេះ សមត្ថកិច្ចថៃធ្វើការទប់ស្កាត់ពលករខ្មែរ ដែលលបលួចចូលឆ្លងដែនទៅធ្វើការក្នុងប្រទេសថៃខុសច្បាប់ខ្លាំងសំបើមណាស់ ដើម្បីការពារទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩។

សូមជម្រាបថា ប្រជាពលរដ្ឋខ្មែរជាច្រើនពាន់គ្រួសារ ក្រោយពីចេញពីប្រទេសថៃមកលេងបុណ្យចូលឆ្នាំខ្មែរកន្លងមកនេះរួចរាល់ហើយ បានបុកសម្រុកទៅរកការងារធ្វើនៅប្រទេសថៃ ១ថ្ងៃៗខ្ទង់រាប់រយនាក់តាមរយៈមេខ្យល់ឆ្លង ដែនខុសច្បាប់ ភាគច្រើនមិនជោគជ័យតាមបំណងទេត្រូវ ប្រឈមនឹងគេចាប់បញ្ជូន ត្រឡប់មកវិញ ក៏នៅតែប្រថុយ អស់ទាំងប្រាក់ ខាតទាំងពេលវេលា ខណៈអ្នកខ្លះត្រូវសមត្ថកិច្ចថៃចាប់ដាក់គុកបន្ត ថែមទៀតផង៕

## សាលារៀនមួយចំនួនចេញវិធានការការពារក្មេងស្រីពីការរំលោភបំពានផ្លូវភេទ

https://www.khmertimeskh.com/ យឹម ស្រីលីន April 29, 2022

សាលារដ្ឋមួយចំនួនបានប្រាប់សិស្សរបស់ពួកគេកុំឱ្យទៅសាលារៀនលឿនពេក ឬចេញយឺតពេលពេកដើម្បីការពារក្មេងស្រីពីការរំលោភបំពានផ្លូវភេទ។ វិទ្យាល័យរដ្ឋមួយចំនួនក្នុងរាជធានីភ្នំពេញបានព្រមានសិស្សស្រីកុំឱ្យធ្វើដំណើរទៅសាលារៀននៅពេលព្រឹកព្រលឹម ឬចាកចេញពីសាលាពេលល្ងាចពេក ដើម្បីចៀសវាងការក្លាយជាជនរងគ្រោះពីការកេងប្រវញ្ចផ្លូវភេទ។ ការស៊ើបអង្កេតរបស់អ្នកយកព័ត៌មានខ្មែរថាមស៍ នៅវិទ្យាល័យមួយចំនួនក្នុងរាជធានីបង្ហាញថា សិស្សា នុសិស្ស គ្រូបង្រៀន និងនាយកសាលាបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីលទ្ធភាពនៃការរំលោភ ជាពិសេសកន្លែងដែលមានសន្តិសុខធូររលុង។

សិស្សស្រីម្នាក់ឈ្មោះ ឡេង ភានូ អាយុ ១៥ឆ្នាំ រៀនថ្នាក់ទី១០ បាននិយាយថា សេចក្តីប្រកាសរបស់សាលាដែលថាសិស្សត្រូវប្រុងប្រយ័ត្ន និងការពារខ្លួននៅក្នុងសាលាជៀសវាងហេតុការណ៍អាក្រក់ផ្សេងៗកើតឡើង។ សិស្សរូបនោះនិយាយថា៖ « ខ្ញុំត្រូវបានគេណែនាំកុំឲ្យមកសាលាមុនម៉ោង ហើយក៏មិនត្រូវចេញយឺតដែរ។ ការណែនាំនេះត្រូវបានផ្តល់ជូនក្រោយចូលឆ្នាំខ្មែរ»។ នាងបាននិយាយថា៖ « ចាប់តាំងពីពេលនោះមក ខ្ញុំមិនបានស្នាក់នៅក្នុងទី

ធ្លាសាលា ឬក្នុងថ្នាក់រៀនតែម្នាក់ឯងទេ។ ជារឿយៗខ្ញុំមានអារម្មណ៍ថា ប្រុសៗកំពុងមើលខ្ញុំហើយចង់យាយីខ្ញុំ» ។ នាងបាននិយាយថា៖ «ទីធ្លាសាលាគឺធំ ហើយមានគុម្ពោតច្រើន ដែលវាងាយស្រួលសម្រាប់អ្នកដែលចង់ទាញយកប្រយោជន៍ពីមនុស្សស្រី»។

សិស្សស្រីម្នាក់ទៀតឈ្មោះ ចាន់ ដានី អាយុ ១៦ ឆ្នាំ ដែលរៀននៅថ្នាក់ទី ១១ បាននិយាយថា បរិយាកាសសាលាបានផ្លាស់ប្តូរខ្លះបន្ទាប់ពីមានការប្រកាស។ នាងបាននិយាយថា គ្រូជាច្រើនឥឡូវនេះកំពុងទទួលភារកិច្ចយាមសន្តិសុខ ហើយវាល្អដែលគ្រូកំពុងការពារសិស្ស ប៉ុន្តែសិស្សមួយចំនួនជាច្រើននាក់ឥឡូវមានអារម្មណ៍អសន្តិសុខ។ សិស្សដានីបន្តថា៖ « ខ្ញុំយល់ថាគ្រូបង្រៀន និងនាយកសាលាមានការព្រួយបារម្ភចំពោះយើង និងសុវត្ថិភាពរបស់យើង ហើយកំពុងព្យាយាមការពារយើង ប៉ុន្តែការដែលឃើញគ្រូបង្រៀនដើរតួជាអ្នកយាមធ្វើឱ្យមានការចាប់អារម្មណ៍ថាអ្វីៗមិនល្អ» ។ នាងបាននិយាយថា៖ « ខ្ញុំតែងតែមានអារម្មណ៍ថា សាលារៀនគឺជាកន្លែងដែលមានសុវត្ថិភាព ប៉ុន្តែការការពារប្រសើរជាងព្យាបាល»។

កុមារី អោប ទេពី អាយុ ១៦ឆ្នាំ ជាសិស្សរៀនថ្នាក់ទី១១ បានរៀបរាប់ពីការអំពាវនាវកុំឱ្យចូលរៀនមុនព្រលឹម និងកុំចេញពីរៀនយឺតថាជាដំបូន្មានដ៏ល្អ។ កុមារីរូបនោះនិយាយថា៖ « ខ្ញុំគិតថាប្រព័ន្ធផ្សព្វផ្សាយសង្គមបានប៉ះពាល់ដល់យើងទាំងអស់គ្នា ព្រោះវាហាក់ដូចជាមនុស្សប្រុសគ្រាន់តែចង់បានរបស់ខ្លះពីមនុស្សស្រី ហើយវាជារឿងធម្មតា»។ នាងបាននិយាយទាំងគ្រវីក្បាល។

កុមារី សេង សូពិសី អាយុ១៥ឆ្នាំ ជាសិស្សថ្នាក់ទី១០ បាននិយាយថា សាលារបស់នាងមិនដែលមានករណីចាប់រំលោភ ឬរំលោភផ្លូវភេទម្តងណាឡើយ។ ទោះជាយ៉ាងនេះក្តី ការព្រមានមិនឱ្យមកឆាប់ ឬចាកចេញយឺត គឺជាមូលហេតុនៃការព្រួយបារម្ភសម្រាប់សិស្សានុសិស្ស។ នាងបានបន្ថែមថា៖ «ក្នុងនាមជាមនុស្សស្រី ខ្ញុំនឹងមានការប្រុងប្រយ័ត្នកាន់តែខ្លាំងនៅពេលនេះ មិនថាខ្ញុំនៅទីណាក៏ដោយ។ ខ្ញុំនឹងត្រូវនៅការពាររាល់វិនាទី»។

អ្នកស្រី ភោគ ដាវី នាយករងនៃវិទ្យាល័យមួយ បាននិយាយកាលពីថ្ងៃពុធថា អ្នកស្រីបានណែនាំសិស្សទាំងអស់ឱ្យមកសាលារៀនមុនម៉ោងចាប់ផ្តើម ហើយកុំឱ្យយឺតពេល។ អ្នកស្រីថា៖ «សាលារបស់យើងមានបរិវេណដ៏ធំ ហើយយើងមិនចង់ឲ្យមានឧបទ្ទវហេតុអាក្រក់ណាមួយឡើយ ជាពិសេសករណីរំលោភផ្លូវភេទ»។ អ្នកស្រី បានបន្ថែមថា គ្រូបង្រៀនត្រូវបានប្រាប់ ដើម្បីជួយការពារសាលា និងសិស្ស ។ អ្នកស្រីថា៖ «គ្រូបង្រៀនបញ្ចប់ការងារនៅម៉ោង ១១ព្រឹក ប៉ុន្តែឥឡូវពួកគេត្រឡប់មកវិញដើម្បីតាមដានអ្វីៗក្នុងសាលា។ គ្រូក៏ផ្តល់សុវត្ថិភាពផងដែរ អំឡុងពេលសម្រាក។ វិធានការទាំងនេះជួយពង្រឹងសន្តិសុខ»។ លោកស្រីបន្ថែមថា៖ «យើងដឹងថា មានក្មេងប្រុសដែលបៀតបៀនក្មេងស្រីដោយពាក្យសំដី។ យើងគិតថា នេះអាចមានផលអាក្រក់ ហើយយើងត្រូវតែធ្វើការដើម្បីទប់ស្កាត់បញ្ហានេះ»។

អ្នកនាំពាក្យក្រសួងអប់រំ លោក រស់ សុវាចា បានមានប្រសាសន៍កាលពីថ្ងៃពុធថា គណៈគ្រប់គ្រងសាលារៀនរដ្ឋ និងឯកជននៅទូទាំងប្រទេសត្រូវតែបន្តអនុវត្តគោលការណ៍សណ្តាប់ធ្នាប់ សុវត្ថិភាព និងសុវត្ថិភាពដែលមានស្រាប់។ លោកបន្តថា៖ «យើងនឹងបន្តពង្រឹងសន្តិសុខ និងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់»៕

## សមត្ថកិច្ចឃាត់ខ្លួនពលករខ្មែរ បម្រុងឆ្លងដែនដោយខុសច្បាប់ បានចំនួនជិត ៥០០នាក់ រួមជាមួយកុមារ ក្រោយបុណ្យចូលឆ្នាំខ្មែរ ចប់ ក្នុងខែមេសានេះ

*https://www.facebook.com/FridayDailynewsfri/ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២២ : លោក ម៉ែ សារី*

ខេត្តបន្ទាយមានជ័យ ÷ ចាប់តាំង ប្រទេសកម្ពុជារៀបចំកម្មពិធីចូលឆ្នាំថ្មី ប្រពៃណីខ្មែរ ព.ស ២៥៦៥ ឈានចូល ព.ស ២៥៦៦ ត្រូវ និង គ.ស ២០២២ ចប់សព្វគ្រប់ រួចមក ត្រូវបានគេសង្កេត ឃើញ ថា ពលរដ្ឋខ្មែរបានព្យាយាមទាក់ទងមេខ្យល់ឲ្យនាំពួកគេឆ្លងដែន ដោយខុសច្បាប់ចូលទៅប្រទេសថៃ តាមច្រករបៀងមួយចំនួន ក្នុងភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ ។ តែក្នុងនោះ ត្រូវបានគេសង្កេតឃើញថា ដោយគោរពតាមបទបញ្ជាយ៉ាងម៉ឺងម៉ាត់របស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាល ខេត្តបន្ទាយមានជ័យ និងលោកឧត្តមសេនីយ៍ត្រី អ៊ុំ សុផល ស្នងការរងទទួលបន្ទុកការងារ ព្រំដែន នគរបាល ការពារព្រំដែនគោក បានធ្វើការ យ៉ាងយកចិត្តទុកដាក់ សហការជាមួយកម្លាំង យោធា ដែលឈរជើង តាមគោលដៅ នីមួយៗ ក្នុង ភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ បានឃាត់ខ្លួនពលករខ្មែរ បានជាបន្តបន្ទាប់។

បន្ទាប់ពីឃាត់ខ្លួន ពលករខ្មែរ គេសង្កេតឃើញ ថា កម្លាំងសមត្ថកិច្ច តែងតែ ធ្វើការផ្សព្វផ្សាយ អប់រំ ដល់ពួកគាត់ ឲ្យ យល់ដឹងពី ផលវិបាក អាចនិង ងាយគ្រោះថ្នាក់ ដោយសារ ការឆ្លងដែន ខុសច្បាប់ ដោយ ប្រថុយប្រថាន ។ ហើយកម្លាំងសមត្ថកិច្ច បានស្នើសុំ ដល់ពលករ ខ្មែរ ត្រូវ បញ្ឈប់ សកម្មភាព ឆ្លងដែន ដោយខុស ច្បាប់ តទៅទៀតផងដែរ ។ បន្ទាប់ពីអប់រំ ណែនាំ និង ធ្វើកិច្ចសន្យា រួចមក ពលករខ្មែរ ទាំងអស់ ត្រូវបាន បញ្ជូនទៅនគរបាលជំនាញ ដើម្បី ចាត់ការបន្តតាមនីតិវិធី ។

សូមបញ្ជាក់ថា នៅព្រឹកថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២២នេះ ដោយយោង តាម របាយ ការ ណ៍ របស់សមត្ថកិច្ច ដែលមាន លោក ឧត្តម សេនីយ៍ត្រី អ៊ុំ សុផល ស្នងការ រង ខេត្តបន្ទាយ មានជ័យ ទទួល បន្ទុក ការងារព្រំដែន បានឲ្យដឹងថា បន្ទាប់ពីប្រទេសកម្ពុជា ចូលឆ្នាំថ្មី ២០២២ ចប់សព្វគ្រប់ រួចមក ដោយគិត ចាប់ពី ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២២ ដល់ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២២ នេះ ពលករ ខ្មែរ មានចំនួន សរុប ៣៤០ នាក់ ស្រី ១៣៤ នាក់ កុមារ ២៨ នាក់ ដែលត្រូវ កម្លាំងសមត្ថកិច្ច ជួរមុខ ដែលឈរជើង តាមបន្ទាត់ ព្រំដែន កម្ពុជា -ថៃ ឃាត់ខ្លួនបានដែលពួកគាត់ (ពលករខ្មែរ) បម្រុងឆ្លងដែន ដោយខុសច្បាប់ចូលទៅរកការងារធ្វើនៅឯប្រទេស ថៃ ។ ជាចុង ក្រោយនេះ សូមអំពាវនាវ ដល់ប្រជាពលរដ្ឋ ខ្មែរ ទាំងអស់ ដែល មានបំណង ចង់ចេញពី ប្រទេសកម្ពុជា ទៅប្រទេស ជិត ខាង ដើម្បី ស្វែង រកការងារ ធ្វើ គួរតែ បំពេញ បែបបទ (មានប៉ាស្ព័រ) ឲ្យត្រឹមត្រូវ តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសជាដៃគូ ដើម្បីចេញ-ចូលឲ្យស្របច្បាប់ ដើម្បីអាចគេចផុតពីហានិភ័យជាយថាហេតុណាមួយ មួយ។ សូមបញ្ឈប់ សកម្មភាព ដោយ ឆ្លងដែន ដោយខុស ច្បាប់ តាមច្រករបៀង តទៅទៀត ៕

## ត្រឹម ២ ខែ កម្ពុជាបញ្ជូនពលករ ១៤ ០០០ នាក់ ទៅធ្វើការនៅប្រទេសជប៉ុន

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៣០ មេសា ២០២២ដោយ Dy Bunnara

រយៈពេល ២ខែ គឺខែមីនា និងខែមេសា ឆ្នាំ២០២២នេះ កម្ពុជាបានបញ្ជូនកម្មសិក្សាការី និងពលករជំនាញប្រមាណ ១៤ ០០០ នាក់ ទៅធ្វើការទៅលើវិស័យផ្សេងៗ នៅប្រទេសជប៉ុន បន្ទាប់ពីបានផ្អាករយៈពេលជាង ១ ឆ្នាំ ដោយសារការផ្ទុះរាតត្បាតជំងឺកូវីដ-១៩។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហេត្ថពលកម្មកម្ពុជាបានឱ្យដឹងនៅព្រឹកថ្ងៃទី៣០មេសានេះថា កម្ពុជាទើបចាប់ផ្តើមបញ្ជូនពលករជំនាញ និងកម្មសិក្សាវីទៅធ្វើការនៅប្រទេសជប៉ុននៅខែមីនាឆ្នាំ២០២២នេះទេ ដោយសារប្រទេសជប៉ុនបានបិទព្រំដែន ដែលបណ្តាលមកពីការឆ្លងរាតត្បាតជំងឺកូវីដ-១៩។ លោក អន ប៊ុន

ហាក់ បានបន្តថា រយៈពេល២ខែនេះ គឺខែមីនា និងខែមេសានេះ យើងបានបញ្ជូនពលករ និងកម្មសិក្សាការីទៅប្រទេសជប៉ុនបានប្រមាណ ១៤០០០នាក់ ដែលជាចំនួនដ៏ច្រើន ដោយសារមានការបិទព្រំដែនកន្លងមកធ្វើឱ្យពលករមានការកកស្ទះច្រើននៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាល ទើបមានការបញ្ជូនច្រើនបែបនេះ។ លោក អន ប៊ុនហាក់ បានបន្តទៀតថា ចាប់ពីពេលនេះទៅយើងអាចបញ្ជូនពលករ និងកម្មសិក្សាការីទៅជប៉ុនបានទៀងទាត់ឡើងវិញហើយដោយក្នុង១ខែៗ អាចបញ្ជូនពី ៣០០០ ទៅ ៤០០០នាក់នាក់។ លោក អន ប៊ុនហាក់ បានបន្ថែមទៀតថា ក្នុងចំណោមពលករខ្មែរទៅធ្វើការនៅជប៉ុនភាគច្រើនជាកម្មសិក្សាការី។ ចំណែកពលករជំនាញមានមិនច្រើនទេ ដោយពួកគេទៅធ្វើការលើផ្នែករវេចខ្ចប់ សំណង់ ចំណីអាហារ សេវាកម្ម សណ្ឋាគារ ភោជនីដ្ឋាន កសិកម្មដាំដុះ និងចិញ្ចឹមសត្វ។

ប្រធានភ្នាក់ងារហត្ថពលកម្មកម្ពុជា រូបនេះបានបន្ថែមថា ចំពោះនីតិវិធី និងបែបបទសុខាភិបាលក្នុងការបញ្ជូនពលករខ្មែរទៅប្រទេសជប៉ុន មិនខុសពីប្រទេសថៃទេ ដោយសារពលករខ្មែរត្រូវមានលក្ខខណ្ឌមួយចំនួនដូចជាត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ-១៩ រយៈពេល ៧២ ម៉ោង តាមម៉ាស៊ីន PCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថាមិនមានឆ្លងជំងឺកូវីដ-១៩។ ទៅដល់ទីនោះត្រូវអនុវត្តវិធានសុខាភិបាលជប៉ុន ដោយធ្វើចត្តាឡីស័ក និងមានការមកទទួលពីថៅកែជប៉ុនផងដែរ។

នៅក្នុងជំនួបជាមួយលោក Fumiaki Takahashi ប្រធានសមាគមជប៉ុនកម្ពុជា(JC A)កាលពីពេលថ្មីៗនេះ លោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានជំរុញឲ្យខាងភាគីជប៉ុនទទួលកម្មសិក្សាការី ក៏ដូចជាពលករជំនាញរបស់កម្ពុជា បានទៅធ្វើការនៅប្រទេសជប៉ុនឲ្យកាន់តែច្រើនខណៈបច្ចុប្បន្នមានប្រមាណជាង១ម៉ឺននាក់កំពុងសិក្សា និងធ្វើការនៅទីនោះ។ លោករដ្ឋមន្ត្រីបានបន្តថា នៅពេលដែលពួកគេវិលត្រឡប់មកកាន់មាតុភូមិកំណើតវិញនឹងទទួលបានចំណេះ ជំនាញ សម្រាប់បង្កើតអាជីវកម្មផ្ទាល់ខ្លួន ឬក៏ក្លាយជាអ្នកគ្រប់គ្រងនៅក្នុងក្រុមហ៊ុន សហគ្រាសរបស់ជប៉ុនដែលមានវត្តមាននៅកម្ពុជា។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះមាន ពលករខ្មែរប្រមាណជាង១លាន២សែននាក់ធ្វើការនៅក្រៅប្រទេសក្នុងនោះនៅថៃមានច្រើនជាងគេរហូតដល់ទៅ១,២២លាននាក់ ជាង ៤៥, ០០០នាក់ នៅកូរ៉េខាងត្បូង ២៣,០២៧នាក់ នៅម៉ាឡេស៊ី ១១,៤៥៣នាក់ នៅជប៉ុន ៨២១ នាក់ នៅសិង្ហបុរី នៅចិនហុងកុង២០២នាក់ និងអារ៉ាប៊ីសាអូឌីត ៤៣នាក់៕ អត្ថបទ៖ សំអឿន

## ក្នុងខែមេសា ជនជាតិថៃជាង ១៣០នាក់ ត្រូវបានជួយសង្គ្រោះពីអ្នកបោកប្រាស់តាមអនឡាញ នៅក្រុងព្រះសីហនុ និងក្រុងបាវិត

https://www.khmertimeskh.com/ Khmer Times May 1, 2022

ខែមេសា កន្លងទៅនេះ មានការសហការគ្នាយ៉ាងជិតស្និទ្ធរវាងនគរបាលថៃ និងកម្ពុជា បានឈានទៅដល់ការជួយសង្គ្រោះជនជាតិថៃជាង ១៣០នាក់ ដែលគេជឿថា បានចាញ់បោកក្រុមឆបោកតាមប្រព័ន្ធអ៊ីនធឺណែតដែលមានទីតាំងនៅក្រុងព្រះសីហនុ ក្រុងបាវិតដែលជាក្រុងជាប់ព្រំដែនកម្ពុជា-ថៃ។ ទោះបីជាមានការជួយសង្គ្រោះ និងការបញ្ជូនជនជាតិថៃជាង ៧០០ នាក់ ពីមជ្ឈមណ្ឌលហៅទូរស័ព្ទឆបោកផ្សេងៗក្នុងប្រទេសកម្ពុជា តាំងពីដើមឆ្នាំ ២០២២ ក៏ដោយ ក៏ប៉ូលីសថៃនិយាយថា ក្រុមឆបោកនៅតែឃុំជនជាតិថៃជាង ១.៥០០ នាក់ ដោយប្រឆាំងនឹងឆន្ទៈរបស់ពួកគេនៅក្នុងខេត្តព្រះសីហនុ។

ប្រភពពីប៉ូលីសថៃ និងកម្ពុជា ដែលដឹងពីសេណារីយ៉ូបាននិយាយថា ចំនួនជនរងគ្រោះកើនឡើងដល់ចន្លោះពី ២៣០០ ទៅ ២៥០០ ប្រសិនបើជនរងគ្រោះទាំងនោះនឹងតែត្រូវបានឃុំឃាំងដោយក្រុមផ្សេងទៀតដែល

ប្រតិបត្តិការនៅតាមខេត្តព្រំដែនកម្ពុជា-ថៃ។ ភាគច្រើន រហូតទៅដល់ ៩០ ភាគរយនៃជនជាតិថៃដែលជាប់ក្នុងស្ថានភាពធ្ងន់ធ្ងរត្រូវបានគេរាយការណ៍ថាបានចូលមកប្រទេសកម្ពុជាតាមរយៈការឆ្លងកាត់ព្រំដែនខុសច្បាប់ ដូច្នេះធ្វើឱ្យមានការលំបាកក្នុងការកំណត់ចំនួនពិតប្រាកដនៃជនជាតិថៃដែលកំពុងធ្វើការ ឬជាប់អន្ទាក់ដោយក្រុមឆបោកនៅក្នុងប្រទេសកម្ពុជា។ យ៉ាងណាក៏ដោយ ប៉ូលីសកម្ពុជា រួមជាមួយនឹងសមភាគីថៃ បាននិយាយថា យ៉ាងហោចណាស់ ជនជាតិថៃ ៣០ ភាគរយ ឬច្រើនជាងនេះ ដែលជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការក្រុមឆបោក ប្រហែលជាមានឆន្ទៈចូលរួមក្នុងការឆបោក ដោយសារតែពួកគេទទួលបានប្រាក់កម្រៃសមរម្យ ប្រសិនបើពួកគេធ្វើការបានល្អ។

ប៉ូលីសថៃបាននិយាយថា ចាប់តាំងពីខែមករា ដល់ចុងខែធ្នូ ឆ្នាំ ២០២១ ជនជាតិថៃជិត ៩០០ នាក់ត្រូវបានជួយសង្គ្រោះ និងនាំត្រឡប់ទៅប្រទេសថៃវិញ ខណៈដែលជនជាតិថៃមួយចំនួនត្រូវបានគេជឿថាបានរត់គេចខ្លួន ឬគ្រាន់តែត្រូវបានបោះបង់ចោលដោយអ្នកចាប់របស់ពួកគេនៅពេលដែលក្រុមប៉ូលីសបានចាប់ផ្តើមប្រតិបត្តិការជួយសង្គ្រោះ។ «ទោះបីជាប្រតិបត្តិការកាន់តែច្រើន កំពុងត្រូវបានគ្រោងរួមគ្នាជាមួយប៉ូលិសថៃ ក្នុងការជួយសង្គ្រោះជនជាតិថៃពីក្រុមឆបោកទាំងនោះក៏ដោយ ក៏នៅតែមានជនជាតិថៃដែលនៅតែឆ្លងដែនដោយខុសច្បាប់ដើម្បីស្វែងរកការងារនៅក្នុងឧស្សាហកម្មល្បែងស៊ីសងខុសច្បាប់ដោយសារហេតុផលកត្តាជីវភាព នេះបើតាមការស៊ើបអង្កេតដែលបានចែករំលែកដោយប្រភពប៉ូលីសកម្ពុជាជាមួយកាសែតខ្មែរថាមស៍៕

## សមាគមបញ្ជូនពលករ សាទរចំពោះការបើកច្រកព្រំដែនកម្ពុជា-ថៃឡើងវិញ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ១ ឧសភា ២០២២ដោយ sopheak khoun

ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានសម្តែងនូវការសាទរចំពោះភាគីថៃ ដែលបានបើកច្រកព្រំដែនអន្តរជាតិមួយចំនួនឡើងវិញ ដែលនឹងជួយសម្រួលដល់ការបញ្ជូនពលករ ទៅធ្វើការនៅប្រទេសថៃ កាន់តែមានភាពងាយស្រួលថែមទៀត។ បន្ទាប់ពីប្រទេសថៃ បានជួបការរាតត្បាតជំងឺកូវីដ-១៩ធ្ងន់ធ្ងរ បានធ្វើឲ្យប្រទេសនេះសម្រេចបិទព្រំដែនជាលក្ខណៈឯកតោភាគី ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩។ ប៉ុន្តែបានចាប់ផ្តើមទទួលពលករឡើងវិញចាប់ពីដើមខែមករាឆ្នាំ២០២២កន្លងទៅនេះក្រោយពីស្ថានភាពជំងឺកូវីដ-១៩បានធូរស្រាល។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឲ្យដឹងនៅព្រឹកថ្ងៃទី ១ ខែឧសភានេះថា ជារួមការបើកច្រកព្រំដែនឡើងវិញ ពីសំណាក់អាជ្ញាធរថៃនេះ មិនត្រឹមតែជួយធ្វើឲ្យសេដ្ឋកិច្ច មានការដំណើរការឡើងវិញប៉ុណ្ណោះទេ ថែមទាំងជួយបង្កលក្ខណៈងាយស្រួល ក្នុងការបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ជាងបច្ចុប្បន្នដែលច្រកបិទ ហើយការចេញចូលមានការលំបាក។ លោក អន ប៊ុនហាក់ បានរំលឹកថា កម្ពុជាបានចាប់ផ្តើមបញ្ជូនពលករស្របច្បាប់ ទៅធ្វើការនៅប្រទេសថៃឡើងវិញ កាលពីដើមខែមករា ឆ្នាំ ២០២២កន្លងទៅនេះ ដោយបញ្ជូនតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ទល់នឹងខេត្តស្រះកែវ។ ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ ២០២២នេះតទៅ រាជរដ្ឋាភិបាលថៃ បានចេញលិខិតអនុញ្ញាតឲ្យភ្ញៀវទេសចរ អាចធ្វើដំណើរចេញ-ចូលប្រទេសខ្លួនបាន តាមច្រកទ្វារព្រំដែនចំនួន ២ នៅខេត្តស្រះកែវ ជាប់ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង គឺច្រកព្រំដែនបានខ្លងលឹក ស្រុកអារញ្ញ ខាងកម្ពុជាគឺច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកព្រំដែនបានខារដិន ស្រុកខ្លងហាត ខាងកម្ពុជាច្រកទ្វារអន្តរជាតិភ្នំដី ក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង។ ប៉ុន្តែត្រូវអនុវត្តតឹងរឹង តាមវិធានការបង្ការជំងឺកូវីដ-១៩។ សម្រាប់ប្រជាពលរដ្ឋខ្មែរ ដែលជាអាជីវករលក់ដូរនៅផ្សាររុងខ្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ អាជ្ញាធរថៃ នៅមិនទាន់អនុញ្ញាតឲ្យចេញ-ចូលបាននៅឡើយទេ ពោលការអនុញ្ញាតនេះ អនុវត្តបានតែចំពោះភ្ញៀវទេសចរ ដែលមានលិខិតឆ្លងដែន បណ្ណព្រំដែន ព្រមទាំងមានបណ្ណចាក់វ៉ាក់សាំងជាដើម។

លោក សៀម ប៊ុនរិទ្ធិ អភិបាលរង និងជាអ្នកនាំពាក្យសាលាខេត្តបាត់ដំបង បានបានស្វាគមន៍ការបើកច្រកព្រំដែនឡើងវិញ និងរីករាយសហការជាមួយភាគីថៃ ព្រោះកន្លងមក កម្ពុជាមិនដែលបានបិទព្រំដែនទេ គឺមានតែភាគីថៃទេជាអ្នកបិទ ដោយសារមានការរាតត្បាតធ្ងន់ធ្ងរ នៃជំងឺកូវីដ-១៩។ លោកអភិបាលរងខេត្ត បានបន្ថែមថា កន្លងមកច្រកទ្វារអន្តរជាតិដូង និងច្រកទ្វារអន្តរជាតិគីឡូ ១៣(ភ្នំដី) ស្ថិតតក្នុងស្រុកសំពៅលូន ច្រកទ្វារអន្តរជាតិខៅឌីន ស្ថិតនៅឃុំខ្លងហាត ស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ អនុញ្ញាតឲ្យមានការធ្វើចរាចរណ៍ ដឹកជញ្ជូនចេញចូលនូវទំនិញប៉ុណ្ណោះ ដោយឲ្យមានអ្នកគ្រប់គ្រងរថយន្ត និងអ្នកនៅប្រចាំក្នុងរថយន្តដឹកជញ្ជូនទំនិញមិនឲ្យលើស ២នាក់ ជារៀងរាល់ថ្ងៃ ដោយត្រូវអនុវត្តតាមវិធានការ នៃការការពារពេគឆ្លងកូវីដ-១៩។ លោកអភិបាលរងខេត្ត បានបន្តដឹងទៀតថា ការបើកច្រកទ្វារព្រំដែនអន្តរជាតិឡើងវិញ នឹងជួយសម្រួលដល់ប្រជាពលរដ្ឋប្រទេសទាំងពីរ អាចធ្វើដំណើរទៅធ្វើការការទៅវិញទៅមក បានងាយស្រួល ពិសេសប្រជាពលរដ្ឋដែលមានបំណងទៅពិនិត្យសុខភាព និងព្យាបាលជំងឺនៅប្រទេសថៃ ខណៈបច្ចុប្បន្ននេះ មានតែការធ្វើដំណើរតាមផ្លូវអាកាសប៉ុណ្ណោះ ព្រោះតាមផ្លូវគោកត្រូវបានបិទទាំងស្រុង។

លោក អន ប៊ុនហាក់ បានបន្ថែមទៀតថា ការបើកច្រកព្រំដែនដ៏សំខាន់នេះឡើងវិញ ក៏នឹងជួយឲ្យកម្ពុជាអាចបញ្ជូនពលករទៅថៃ បានកាន់តែច្រើនថែមទៀត ខណៈនាពេលខាងមុខនេះ អាជ្ញាធរថៃនឹងលែងតម្រូវឲ្យពលករខ្មែរ ទៅធ្វើការដោយស្របច្បាប់ ធ្វើចត្តាឡីស័ករយៈពេល ៧ថ្ងៃដូចមុនទៀតហើយ ពោលគឺគ្រាន់តែធ្វើតេស្តរហ័សប៉ុណ្ណោះ។ ក្នុងករណីអវិជ្ជមាន នឹងអាចចូលទៅធ្វើនៅតាមរោងចក្រតែម្តង។ លោកបានបញ្ជាក់ថា ការលើកលែងការធ្វើចត្តាឡីស័កនេះ វានឹងជួយកាត់បន្ថយការចំណាយដ៏ធំរបស់និយោជកថៃ ក្នុងការទទួលយកពលករម្នាក់ប្រមាណ ១ម៉ឺនបាត ប្រហាក់ប្រហែល ៣០០ដុល្លារ និងជួយជំរុញឲ្យនិយោជកថៃ បង្កើនចំនួនក្នុងការទទួលយកពលករខ្មែរ ដោយរំពឹងថា នឹងអាចបញ្ជូនទៅក្នុង ១ខែពី ១ម៉ឺននាក់ ទៅ ១ម៉ឺន ៥ពាន់នាក់។

យ៉ាងណាក៏ដោយលោក អន ប៊ុនហាក់ បានបញ្ជាក់បន្ថែមថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ-១៩ រយៈពេល ៧២ម៉ោង តាមម៉ាស៊ីន PCR ឬតេស្តរហ័ស ដែលធ្វើដោយគ្រូពេទ្យជំនាញ ដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ-១៩ដដែល៕ អត្ថបទ៖ សំអឿន

## ជនជាតិខ្មែរ២នាក់បន្លំខ្លួនជាព្រះសង្ឃនៅប្រទេសថៃ ត្រូវបានចាប់ខ្លួន

https://www.khmertimeskh.com/ Khmer Times May 2, 2022

បុរសខ្មែរពីរនាក់ ដែលបន្លំខ្លួនជាព្រះសង្ឃត្រូវបានចាប់ខ្លួន និងជាប់ចោទពីបទចូលប្រទេសថៃដោយខុសច្បាប់ដោយប៉ូលីសអន្តោប្រវេសន៍ក្នុងស្រុក Muang កាលពីថ្ងៃសៅរ៍។ លោក Pol Col Parinya Klinkeson មេប៉ូលីសអន្តោប្រវេសន៍ខេត្ត Samut Prakan បាននិយាយថា ប៉ូលីសទទួលព័ត៌មានបានពីអ្នកស្រុក និងបានឆ្មក់ចូលផ្ទះឈើមួយកន្លែងនៅខាងក្រោយផ្សារ Siwa នៅលើផ្លូវ Phuttharaksa ក្នុង Tambon Thai Ban Bai ។ ប៉ូលីសបានចាប់ខ្លួនបុរសពីរនាក់នៅទីនោះ។ "ព្រះសង្ឃ" ត្រូវបានស្គាល់អត្តសញ្ញាណត្រឹមតែឈ្មោះ ជី ណា អាយុ ៣០ ឆ្នាំ និង វ៉ែន្ន អាយុ ២៧ ឆ្នាំតែប៉ុណ្ណោះ និងបានខផែកឃើញក្រដាសប្រាក់ ២០បាត និង ១០០ បាត សរុបប្រហែល ១,០០០ បាត ដែលពួកគេបានប្រមូលពីអ្នកស្រុក។ ប៉ូលីសក៏បានរកឃើញផងដែរនូវស្បង់ និងវត្ថុជាច្រើនទៀតដែលព្រះសង្ឃប្រើប្រាស់។

អ្នកទាំងពីរបានសារភាពថា ពួកគេស្ថិតក្នុងចំណោមជនជាតិខ្មែរផ្សេងទៀត ដែលបានលួចឆ្លងដែនចូលទៅក្នុងប្រទេសថៃ។ ដោយបន្លំខ្លួនជាព្រះសង្ឃ ពួកគេបានធ្វើដំណើរតាមរថយន្តក្រុងទៅកាន់ខេត្តសាមុតប្រាកាន ហើយបានចែកផ្លូវគ្នាជាក្រុមទៅកាន់តំបន់ផ្សេងៗ ដោយពួកគេបានសង់ខ្ទមបណ្តោះអាសន្នមួយនៅក្នុងព្រៃ ដើម្បី

ស្នាក់នៅពេលយប់។ ពេលថ្ងៃពួកគេចេញទៅបិណ្ឌបាទ។ អ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទចូលប្រទេសថៃដោយខុសច្បាប់ ហើយនឹងត្រូវបញ្ជូនមកវិញបន្ទាប់ពីចាត់តាមនីតិវិធីច្បាប់។ ប៉ូលីសកំពុងស្វែងរកព្រះសង្ឃខ្មែរក្លែងក្លាយផ្សេងទៀត៕ ប្រភព: Bangkokpost

## ក្រោយបើកដំណើរការឆ្លងកាត់នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត, ប្រជាពលរដ្ឋរាប់រយនាក់ សម្រុកទៅធ្វើបណ្ណឆ្លងព្រំដែនកម្ពុជា-ថៃ គំរូថ្មីនៅច្រកចេញ-ចូលតែមួយ

http://freshnewsasia.com/ 2022-05-02 04:49pm

**(បន្ទាយមានជ័យ)៖** គ្រាន់តែភាគីថៃ បើកឲ្យដំណើរការឆ្លងកាត់នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតកាលពីម្សិលមិញភ្លាម, គេសង្កេតឃើញមានប្រជាពលរដ្ឋជាច្រើនរយនាក់ បាននាំគ្នាសម្រុកធ្វើបណ្ណឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ គំរូថ្មី (Border Pass) នៅច្រកចេញចូលតែមួយក្នុងសាលាខេត្តបន្ទាយមានជ័យ។ តាមសេចក្តីរាយការណ៍ពីភ្នាក់ងារព័ត៌មាន Fresh News បានឲ្យដឹងថា ភាគច្រើនអ្ន កដែលទៅធ្វើបណ្ណព្រំដែននោះ ជាប្រជាពលកទៅធ្វើការងារនៅខេត្តសាកែវ ប្រទេសថៃ។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានថ្លែងថា អាជ្ញាធរបានយកចិត្តទុកដាក់ដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋភ្លាមៗ ជាពិសេសនៅពេលមកធ្វើបណ្ណព្រំដែន ដើម្បីឲ្យពួកគេអាចដំណើរចូលទៅថៃបាន ក្រោយច្រកទ្វារអន្តរជាតិប៉ោយប៉ែត ត្រូវបានបើកដំណើរការឲ្យឆ្លងកាត់។ លោកអភិបាលខេត្តបានបញ្ជាក់ថា កាលពី២ឆ្នាំមុន ប្រជាពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យ ភាគច្រើនជាពលករ ទោះបីមានបណ្ណព្រំដែនកម្ពុជា-ថៃ ក៏មិនអាចឆ្លងដែនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីចូលទៅប្រទេសថៃ ស្វែងរកការងារធ្វើបានដែរ ព្រោះ២ឆ្នាំមុននោះជំងឺកូវីដ១៩ កំពុងតែផ្ទុះយ៉ាងខ្លាំង ហើយរោងចក្រ កន្លែងធ្វើការនៅក្នុងប្រទេសថៃត្រូវបានបិត រហូតពលករខ្មែរបានត្រឡប់មកស្រុកវិញ។

លោកបានបញ្ជាក់ថា «**នាថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ នាយករដ្ឋមន្ត្រីថៃ បានអនុញ្ញាតឱ្យបើកច្រកទ្វារអន្តរជាតិឡើងវិញ ក្នុងនោះភាគីខាងថៃ តម្រូវឱ្យប្រជាពលរដ្ឋខ្មែរបើចង់ឆ្លងដែនចូលខេត្តសាកែវ ទាល់តែមានបណ្ណព្រំដែនកម្ពុជា-ថៃ និងលិខិតឆ្លងដែន ទើបប្រជាពលរដ្ឋសម្រុកមកធ្វើបណ្ណព្រំដែនកម្ពុជា-ថៃ ភ្លូកទឹកភ្លូកដីបែបនេះ**»។ **លោកអភិបាលខេត្ត បានគូសបញ្ជាក់ថា ដំណើរការធ្វើបណ្ណព្រំដែនកម្ពុជា-ថៃ រួមមាន៖**

*ពាក្យស្នើសុំបណ្ណព្រំដែនចំនួន១ច្បាប់ ដោយមានបិតរូបថត និងចុះហត្ថលេខា ឬផ្តិតមេដៃ នៅលើពាក្យស្នើរសុំ

*រូបថតរបស់សាមីខ្លួន ៤គុណ ៦ ចំនួន២សន្លឹក

*អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ថតចំលង១ច្បាប់

*សេចក្តីចំលងសំបុត្រកំណើត១ច្បាប់

*សេចក្តីចំលងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅចំនួន១ច្បាប់

*កូនចាប់ពីអាយុ១២ឆ្នាំចុះ មិនបាច់ធ្វើទេ គឺអាចរួមដំណើរជាមួយឪពុកម្តាយបាន

*តម្លៃសេវាក្នុង១ច្បាប់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន ២០,០០០រៀល រយៈពេលផ្តល់សេវាយ៉ាងយូរ៥ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើរសុំ៕

# ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២

## នៅព្រឹកថ្ងៃចន្ទ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេស ថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ចំនួន២លើក

https://gdlf-kh.com/ 2022/05/02/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង៩ និង០០នាទី នាថ្ងៃចន្ទ ២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២លើក សរុបចំនួន៣៤នាក់ ស្រី១៥នាក់ ក្មេង ៤នាក់ ក្មេងស្រីម្នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ត្រួតពិនិត្យ និងមានប័ណ្ណចាក់វ៉ាក់សាំងស្តែនចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## តុលាការកំពូល តម្កល់ទោសទណ្ឌិតម្នាក់ ជាប់គុក៥ឆ្នាំ ពាក់ព័ន្ធការបើកកន្លែងម៉ាស្សា តែបង្កប់កន្លែងវ៉ៃសិច

https://cen.com.kh/ Posted ByPen Srey NeatMay 4, 2022

ភ្នំពេញ : តុលាការកំពូលកាលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២២ នេះ បានប្រកាសសាលាដីការ តម្កល់ទោសទណ្ឌិតម្នាក់ ដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ ជាប់ពាក់ព័ន្ធករណីបើកកន្លែងម៉ាស្សា តែបង្កប់កន្លែងវ៉ៃសិច ( អំពីពេស្យាចារ ) ប្រព្រឹត្តភូមិវិហារសួគ៌ ឃុំវិហារសួគ៌ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ ២០២០ ។

លោកជំទាវ គិម សត្ថាវី ជាប្រធានចៅក្រមជំនុំជម្រះនៃ តុលាការកំពូល បានថ្លែងឲ្យដឹងថា ទណ្ឌិតរូបនេះមាន ឈ្មោះ ថៃ ម៉េងគង់ ភេទប្រុស អាយុ ២៩ ឆ្នាំ មុខរបរ ថៅកែហាងម៉ាស្សា ។ នៅក្នុងសំណុំរឿងក្តីនេះ សាលាដំបូងខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែ មករា ឆ្នាំ ២០២១ បានកាត់ទោសទណ្ឌិត ថៃ ម៉េង ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ពីបទ ″ សញ្ជារកម្មមានស្ថានទម្ងន់ទោស ″ តាមមាត្រា ២៧ នៃច្បាប់ស្តីពីការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ គាត់បានប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍រាជធានី បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដែល ។ គាត់ ក៏បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ ទណ្ឌិត ថៃ ម៉េង ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២០ នៅភូមិវិហារសួគ៌ ឃុំវិហារសួគ៌ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល៕ ចន្ទា ភា

## អាជ្ញាធរខេត្តក្រចេះចុះផ្អាកពិធីអាពាហ៍ពិពាហ៍ខាងកូនក្រមុំខ្មែរជាមួយជនបរទេស

https://kohsantepheapdaily.com.kh/ ក្រចេះ០៤ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ០៨:៥៣

ខេត្តក្រចេះ ៖ អាជ្ញាធរមានសមត្ថកិច្ចខេត្តក្រចេះបានអោយដឹងថា កាលពីរសៀលថ្ងៃទី២ ខែមេសា ឆ្នាំ ២០២២ បានសម្រេចចុះផ្អាកពិធីរៀបអាពាហ៍ពិពាហ៍មួយគូរវាងកូនក្រមុំជាជនជាតិខ្មែរ ជាមួយនិងកូនកម្លោះជាជនបរទេសក្រោយបានរកឃើញថា ជាអាពាហ៍ពិពាហ៍ខុសច្បាប់ ។

មន្ត្រីនគរបាលការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី នៃស្នងការដ្ឋាននគរបាលខេត្តបានបញ្ជាក់ថា អាជ្ញាធរបានសម្រេចចុះបិទពិធីមង្គលការមួយទាំងស្រុង នៅក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ អាពាហ៍ពិពាហ៍ដែលមានកូនក្រមុំជាជនជាតិខ្មែរ ចំណែកឯកូនកម្លោះជាជនបរទេសគឺជាជនជាតិហុងគ្រី និងបានសិទ្ធិចូលមកស្នាក់នៅក្នុងប្រទេសកម្ពុជាដោយស្របច្បាប់ ។ អ្វីដែលចាប់អារម្មណ៍នោះ គឺពិធីមង្គលការ ដែលបានធ្វើឡើងតាមប្រពៃណីខ្មែរតាំងពីព្រឹក គឺត្រូវផ្អាកវិញទាំងស្រុងនៅពេលរសៀល ខណៈការរៀបចំតុទទួលភ្ញៀវ ដើម្បីមកចូលរួមអបអរសាទរផឹកស៊ីក៏និងត្រូវជិតចាប់ផ្តើមទៅហើយនោះ ក៏ត្រូវបានរំសាយទាំងស្រុង មិនតែប៉ុណ្ណោះសូម្បីតែរោងពិធី ក៏ត្រូវបានសមត្ថកិច្ចបញ្ជាឲ្យរុះរើចេញទាំងអស់។អាជ្ញាធរមូលដ្ឋានអះអាងថា ពិធីមង្គលការនេះ ខាងម្ចាស់សាមីកូនក្រមុំពុំបានមកសុំច្បាប់អាពាហ៍ពិពាហ៍ ឬប្រាប់អាជ្ញាធរឲ្យដឹងនោះទេ ដោយសម្រេចធ្វើពិធីមង្គលការយ៉ាងអធឹកអធមតាមតែចិត្តនឹកឃើញរបស់ពួកគេតែប៉ុណ្ណោះ ។ យ៉ាងណា យើងនៅមិនទាន់មានការបកស្រាយណាមួយពីភាគីខាងគ្រួសារកូនក្រមុំនៅឡើយទេ ។

## ២ ថ្ងៃមានពលករខ្មែរ ៨៦ នាក់ វិលមកពីថៃតាមច្រកព្រំដែនក្នុងស្រុកសំពៅលូន

https://www.postkhmer.com/ គឹម សារុំ | Publication date 03 May 2022 | 10:18 ICT

**បាត់ដំបង:** ក្នុងរយៈពេល ២ ថ្ងៃមានពលករចំនួន ៨៦ នាក់រួមទាំងក្មេងៗផង បានឆ្លងដែនមកពីថៃវិញ ប៉ុន្តែមិនមានពលករណាម្នាក់ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនោះទេ ដោយសារតែពួកគាត់សុទ្ធតែមានបណ្ណចាក់វ៉ាក់សាំង។

លោក ប្រាក់ សាយ មេបញ្ជាការវរសេនាតូច នគរបាលការពារព្រំដែនលេខ ៨១៧ ប្រចាំប៉ុស្តិ៍គីឡូម៉ែត្រលេខ ១៣ ភូមិពោធិ៍ជ្រៃ ឃុំ សិរីមានជ័យស្រុកសំពៅលូន ថ្លែងនៅថ្ងៃទី ២ ឧសភា ថា ចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ២ ឧសភា មានពលករចំនួន ៨៦ នាក់ (ស្រី ២៥ នាក់ ក្មេង ៥ នាក់) បានឆ្លងដែនពីប្រទេសថៃចូលមកតាមប៉ុស្តិ៍គីឡូម៉ែត្រលេខ ១៣។ ប៉ុន្តែពលករទាំងនោះមិនត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កទេ ដោយសារតែពួកគេសុទ្ធតែមានបណ្ណចាក់វ៉ាក់សាំង។ លោកថា៖ «ពលករទាំងនោះ បើពួកគាត់ណាម្នាក់ គ្មានបណ្ណចាក់វ៉ាក់សាំងទេគឺគ្រូពេទ្យមិនអនុញ្ញាតឱ្យទៅផ្ទះទេ គឺត្រូវបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ក ១៤ ថ្ងៃសិន»។ លោកបន្តថាចាប់តាំងពីក្រោយចូលឆ្នាំខ្មែរចប់ចំនួននៃការសម្រុកមកប្រទេសវិញរបស់ពលករកម្ពុជាក្នុង ១ ថ្ងៃមានមិនដល់ ១០០ នាក់ផងទេ។ ចំពោះអ្នកដែលបន្តឆ្លងដែនពីប្រទេសថៃវិលមកស្រុកវិញនាពេលនេះ គឺដោយសារភាគច្រើនពួកគាត់អស់ការងារធ្វើនៅប្រទេសថៃ ឬក៏ស្ទើរមិនសូវមានការងារធ្វើ និងម្យ៉ាងទៀត ពួកគាត់ចង់មករស់នៅឯស្រុកភូមិរបស់ពួកគាត់វិញ។ រីឯពលករដែលវិលមកលេងបុណ្យចូលឆ្នាំខ្មែរហើយត្រូវវិលទៅធ្វើការនៅថៃវិញ គឺពួកគាត់ចូលទៅតាមច្រកអន្តរជាតិស្របច្បាប់ ឈប់លួចឆ្លងដែនដូចមុនទៀតហើយ។ លោកបញ្ជាក់ថា៖ «រឿងមេខ្យល់លួចនាំពលករឆ្លងដែនពេលនេះស្ងប់ស្ងាត់អស់ហើយ។ ការស្ងប់ស្ងាត់នេះដោយសារកម្លាំងសមត្ថកិច្ចយើងចាប់ និងត្រូវបានតុលាការឃុំខ្លួន»។ ចំពោះមេខ្យល់ដែលសមត្ថកិច្ចចាប់បាន និងត្រូវបានតុលាការឃុំខ្លួននោះគឺពួកគាត់ជាប់ពាក់ព័ន្ធនឹងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ៕

## ពលរដ្ឋសម្រុកនាំគ្នាធ្វើបណ្ណព្រំដែនចូលប្រទេសថៃ ក្រោយប្រកាសបើកច្រកព្រំដែន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៤ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៦:០២

ខេត្តបន្ទាយមានជ័យ ៖ ច្រកចេញ-ចូលតែមួយខេត្តបន្ទាយមានជ័យ ក្នុងរយៈពេលទទួលបានពាក្យប្រជាពលរដ្ឋសុំធ្វើបណ្ណព្រំដែន ប្រមាណជិត៥០០នាក់ គិតត្រឹមម៉ោង១១ព្រឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ នៅសាលាខេត្តបន្ទាយមានជ័យចាប់ពីថ្ងៃប្រកាសបើកច្រកព្រំដែនមក ។

លោក ឈឹន សូរិយា ប្រធានច្រកចេញ-ចូលតែមួយខេត្តបន្ទាយមានជ័យបានប្រាប់ថា ក្រោយពេលមានការបើកឱ្យប្រជាពលរដ្ឋចេញ-ចូលតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដែលឈមនឹងច្រកខ្លងលឹក ខេត្តស្រះកែវប្រទេសថៃ ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២នេះមក ច្រកចេញ-ចូលតែមួយសាលាខេត្តបន្ទាយមានជ័យ បានទទួលពាក្យប្រជាពលរដ្ឋរស់នៅខេត្តបន្ទាយមានជ័យបានមកធ្វើបណ្ណព្រំដែន ឬ (BORDER PASS) មានចំនួន៤៩២ពាក្យ ។ លោកបានបញ្ជាក់ថា មន្ត្រីច្រកចេញ-ចូលតែមួយខេត្តបន្ទាយមានជ័យ បានចាប់ផ្តើមទទួលពាក្យពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ បានចំនួន៦៤ពាក្យ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ទទួលពាក្យបានចំនួន២៣៩ពាក្យ និងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ គិតត្រឹមម៉ោង១១ ទទួលពាក្យបានចំនួន១៨៩ ។ លោក ឈឹន សូរិយា បានបញ្ជាក់ថា ការធ្វើបណ្ណព្រំដែន (BORDER PASS) តម្រូវមាន ៖

១-អត្តសញ្ញាណបណ្ណ ។

២-សំបុត្រកំណើតឬចម្លងសំបុត្រកំណើត ។

៣-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ។

៤-រូបថត៤x៦ចំនួន២សន្លឹក បើមានកូនទៅតាមត្រូវមានរូបថត៣x៤ចំនួន២សន្លឹក ។

៥-សៀវភៅបណ្ណព្រំដែន១ក្បាលតម្លៃ២ម៉ឺនរៀល ។

៦-សៀវភៅបណ្ណព្រំដែនចាស់ផុតសុពលភាពតថ្មីតម្លៃ១ម៉ឺនរៀល ។

លោកបានបញ្ជាក់ថា ធ្វើបណ្ណព្រំដែន (BORDER PASS) នេះ មានសុពលភាពរយៈពេល២ឆ្នាំ ហើយអាចប្រើប្រាស់ធ្វើដំណើរបាន២ខេត្តជាប់ជាយដែនក្នុងប្រទេសថៃមានដូចជា ខេត្តស្រះកែវ និងខេត្តប្រាជិនបូរី ៕

## នៅព្រឹកថ្ងៃពុធ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ចំនួន២លើក

https://gdlf-kh.com/ 2022/05/04/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡែ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុំង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២លើក សរុបចំនួន២៦នាក់ ស្រី១៣នាក់ ក្មេងស្រី៣នាក់ ។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើការពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងឃោះញថាត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២

### តុលាការកំពូល តម្កល់ទោសជនជាតិ

### អង់គ្លេសម្នាក់ ជាប់គុក ២ ឆ្នាំ ៦ ខែ ពាក់ព័ន្ធនឹងការប្រ.ទូស្តកេ.រ្តិ៍ខ្មា.ស នៅខេត្តសៀមរាប

https://cen.com.kh/ Posted ByPen Srey NeatMay 5, 2022

ភ្នំពេញ : តុលាការកំពូល កាលពីព្រឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២២នេះ បានតម្កល់ទោស ជនជាប់ចោទជនជាតិអង់គ្លេសម្នាក់ ជាប់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ ជាប់ពាក់ព័ន្ធនឹងបទល្មើសប្រទូស្តកេរ្តិ៍ខ្មាសមានស្ថានទម្ងន់ទោស ធ្វើសកម្មភាពបៀតបៀន កេរ្តិ៍ខ្មាស ទៅលើជនរងគ្រោះ ប្រព្រឹត្តនៅសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប និងខេត្តសៀមរាប កាលពីអំឡុង ឆ្នាំ ២០២០។

លោកជំទាវ គិម សត្ថាវី ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាកំពូល បានថ្លែងឲ្យដឹងថា ជនជាប់ចោទរូបនេះ មានឈ្មោះ ៖ មេតហ្សិវ វីល្លាម វ៉ែតឃិន ( MATTHEW WILL AM WATKIN ) ភេទប្រុស អាយុ ៣៩ ឆ្នាំ មុខរបរមុនចាប់ខ្លួន គ្រូបង្រៀនភាសាអង់គ្លេស ។ ចំណែកឯ ជនរងគ្រោះ គឺជាក្មួយស្រីរបស់ប្រពន្ធរបស់ជនត្រូវចោទ MATTHEW WILL AM WATKIN មានអាយុ ១៣ ឆ្នាំ ស្នាក់នៅជាមួយក្រុមគ្រួសាររបស់ MATTHEW WILL AM WATKIN នៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាបខេត្តសៀមរាប ។ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ឈ្មោះ MATTHEW WILL AM WATKIN ត្រូវបានសាលាដំបូងខេត្តសៀមរាប កាលពីថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០២១ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ និងពិន័យជាប្រាក់ចំនួន ៤ លានរៀល សម្រាប់បង់ចូលថវិការដ្ឋ ក្រោមការចោទប្រកាន់ពីបទ : « ប្រទូស្តកេរ្តិ៍ខ្មាស មានស្ថានទម្ងន់ទោស ទាក់ទងនឹងជនរងគ្រោះ« តាមមាត្រា ២៤៨ នៃក្រមទណ្ឌកម្ម ។

សាលាដំបូងខេត្តសៀមរាប ក៏បានបង្គាប់អោយ MATTHEW WILL AM WATKIN ត្រូវសង់ថ្លៃជម្ងឺចិត្តចំនួន១០ លានរៀល។ តែជនជាប់ចោទ MATTHEW WILL AM WATKIN បានប្តឹងឧទ្ធរណ៍ខណៈដែលសាលាឧទ្ធរណ៍ បានតម្កល់ទណ្ឌកម្មរបស់គាត់ រក្សាទុកជាបានការដដែល។ គាត់ក៏ប្តឹងសាទុក្ខ មកតុលាការកំពូលទៀត។ ជនជាប់ចោទ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០ នៅភូមិសាលាកំរើក សង្កាត់សាលាកំរើក នៅក្រុងសៀមរាប ខេត្តសៀមរាប ៕ រក្សាសិទ្ធដោយ ៖ ចន្ទា ភា

### កម្លាំងការពារបន្ទាត់ព្រំដែនកម្ពុជា ថៃទទួលពលរដ្ឋត្រឡប់មកពីប្រទេសថៃ២២នាក់

http://nokorwatnews.com/ 04/05/2022

ខេត្តបាត់ដំបង ៖ កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជា មេបញ្ជាការបានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ជាកម្លាំងចំណុះ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង ជាប្រចាំ។ ការយកចិត្តទុកដាក់ចេញល្បាតតាមព្រំដែននេះ ធ្វើឲ្យនៅថ្ងៃទី៣ខែឧសភាម្សិលមិញនេះកម្លាំង បានទទួលប្រជាពលរដ្ឋវិលត្រ

ឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព ឃុំជ្រៃសីមា និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៤លើក សរុបចំនួន២២នាក់ ក្នុងនោះមាន ស្រី៩នាក់ ក្មេង៦នាក់ ក្មេងស្រី១នាក់ ។

ប្រភពពីមន្ត្រីនគរបាលការពារព្រំដែនក្នុងវរសេនាតូចលេខ ៨១៦ បានឲ្យដឹងថា ក្រោយពីទទួលប្រជាពលរដ្ឋទាំង២២នាក់នេះ កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ ពួកគាត់រួចប្រគល់បងប្អូនទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការត្រួតពិនិត្យសុខភាព និងស្វែនប័ណ្ណចាក់វ៉ាក់សាំងកូវីដ.១៩នៅនឹងប៉ុស្តិ៍តែម្តង ។ ជាលទ្ធផលឃើញថាពួកគាត់បានអនុវត្តត្រឹមត្រូវទាំងអស់ ។ បន្ទាប់មកក្រុមពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ ៕

## សមត្ថកិច្ចថៃចាប់បានពលករខ្មែរលួចឆ្លងដែនខុសច្បាប់ ១៤នាក់ ព្រមទាំងមេខ្យល់ជនជាតិថៃ

https://gntimes.com/ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២

បន្ទាយមានជ័យ៖ កម្លាំងនគរបាលស៊ើបអង្កេតខេត្តស្រះកែវ សហការជាមួយនគរបាលខេត្តប្រាជីនបុរី បានស្កាត់ចាប់មេខ្យល់ជនជាតិថៃ ព្រមទាំងពលករខ្មែរបានចំនួន ១៤នាក់ (ប្រុស ១០នាក់ ) និងវត្ថុតាងរថយន្តដឹកពលករខ្មែរមួយគ្រឿង នៅបរិវេណចំណុចផ្លូវបំបែកជា៣ ភូមិព្រះភ្លើង២ ឃុំព្រះភ្លើង ស្រុកខៅឆ្កូច ខេត្តស្រះកែវ និងឃុំខ្លួនយកមកសួរនាំបន្ថែម ។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មានថៃ កាលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២២ ម្សិលមិញនេះ ។ ពលករខ្មែរទាំង ១៤នាក់ ត្រូវបានចោទជាបុគ្គលអន្តោប្រវេសន៍ជនជាតិខ្មែរ ដែលលួចចូលប្រទេសថៃដោយមិនមានលិខិតអនុញ្ញាត ។ សារព័ត៌មានថៃបានបញ្ជាក់ថា កម្លាំងការពារព្រំដែនខេត្តស្រះកែវ និងកងកម្លាំងបូរផា ចាប់ឃុំពលករខ្មែរដែលលួចចូលប្រទេសដោយខុសច្បាប់ចំនួន ៦លើក សរុបជិត ១០០នាក់ហើយ ៕ ដោយ៖ ចន្ទ្រា

## រយៈពេល ៤ថ្ងៃ ដើមខែឧសភា
## ពលករខ្មែរត្រឡប់ពីថៃ តាមច្រកអូរបីជាន់ មានជាង ៥០០នាក់ តែមិនមានកូវីដ ២នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៥ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៨:២៩

បន្ទាយមានជ័យ៖ រយៈពេល ៤ថ្ងៃ ក្នុងដើមខែឧសភានេះ មានពលករខ្មែរត្រឡប់ មកពីប្រទេសថៃ ចូលកម្ពុជា ជាង ៥០០នាក់ តាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ។ ក្នុងនោះ មានអ្នកវិជ្ជមានកូវីដ១៩ ចំនួន ២នាក់។

លោកវរៈសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារ ទទួលពលករខ្មែរច្រកអូរបីជាន់ បានប្រាប់ថា រយៈពេល ៤ថ្ងៃ ក្នុងដើមខែឧសភានេះ មានពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា តាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ មានចំនួន ៥០១នាក់ ក្នុងនោះ មានស្ត្រី ២២៨នាក់។ អ្នកទាំងនោះ មានអ្នកចាក់វ៉ាក់សាំងដូសទី២ និងដូសទី៣ចំនួន ៤៥៩នាក់ ស្រី ២១២នាក់ និងមានអ្នកវិជ្ជមានកូវីដ.១៩ ចំនួន ២នាក់ ស្រី ម្នាក់។ លោកបានបញ្ជាក់ថា ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលតាមច្រកអូរបីជាន់ ដែលក្រុមការងារទទួល នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ មានចំនួន ១០៤នាក់ ស្រី ៤៤នាក់ កុមារ ៨នាក់។ ក្នុងនោះ មានអ្នកចាក់វ៉ាក់សាំងដូសទី២ និងដូសទី៣ ចំនួន ១០៤នាក់ ស្រី ៤៤នាក់ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ មានចំនួន ១២០នាក់ ស្រី ៦៧នាក់ កុមារ ៩នាក់ អ្នកចាក់វ៉ាក់សាំងដូសទី២ និងដូសទី៣ មានចំនួន ១២០នាក់ ស្រី ៥៨នាក់ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ មានចំនួន ១៤២នាក់ ស្រី ៦២នាក់ កុមារ ១២នាក់ អ្នកចាក់វ៉ាក់សាំងដូសទី២ និងដូសទី៣ មានចំនួន ១៣៣នាក់ ស្រី ៥៩នាក់ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២ មានចំនួន ១១២នាក់ ស្រី ៥៥នាក់ កុមារ ១៣នាក់ អ្នកចាក់វ៉ាក់សាំងដូសទី២ និងដូសទី៣ មានចំនួន ១០២នាក់ ស្រី ៥១នាក់។

ដោយឡែក នៅច្រកបឹងត្រកួន ក្នុងស្រុកថ្មពួក រយៈពេល ៤ថ្ងៃនេះ ក្រុមការងារទទួលពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ មានចំនួន ៣១នាក់ ស្រី ២០នាក់។ ប៊ុន ធឿន

## ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២

### ស្ត្រីខ្មែរឥស្លាមម្នាក់ ត្រូវថៅកែធ្វើបាប កំពុងជាប់គាំងនៅអារ៉ាប់ សុំអង្វរឯកឧត្តម អូស្មាន ហាស្សាន់ ជួយគាត់ផង ខណៈក្រុមហ៊ុនបញ្ជូនទៅមិនអើពើ!

https://cen.com.kh/ Posted ByLeng KhunMay 6, 2022

ថ្មីៗនេះ (ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២) តាមរយៈគណនីហ្វេសប៊ុកឈ្មោះ Nor Inee បានបង្ហោះវីដេអូចំនួន២ឃ្លីប បង្ហាញស្ត្រីខ្មែរឥស្លាមម្នាក់ បានលើកដៃសំពះសុំអង្វរដល់ថ្នាក់ដឹកនាំនៃក្រសួងពាក់ព័ន្ធ មេត្តាជួយគាត់ផង បន្ទាប់ពីក្រុមហ៊ុនខ្មែរមួយបញ្ជូនគាត់មកកាន់ប្រទេសអារ៉ាប់ ពុំអើពើជួយដោះស្រាយឲ្យគាត់បានវិលត្រឡប់មកផ្ទះវិញ។ ស្ត្រីរងគ្រោះរូបនេះ ដែលមានឈ្មោះ សាលេស ម៉ាស់ បានរៀបរាប់ឲ្យដឹងថា គាត់រស់នៅភូមិស្រះ ឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ គាត់បានមកធ្វើការនៅប្រទេសអារ៉ាប់ អស់រយៈពេល ៣ ឆ្នាំហើយ ដោយមកតាមរយៈក្រុមហ៊ុនមួយឈ្មោះ តាជី ស្រីម៉ាន់ (នៅគីឡូលេខ៧)។

ក្នុងនោះ គាត់បានបញ្ចេញឲ្យដឹងថា ថៅកែរបស់គាត់ធ្វើបាប ដោយអត់ឲ្យដេក ហូបចុកគ្រប់គ្រាន់ទេ និងសូម្បីហាមមិនឲ្យទូរស័ព្ទប្រើ និងប្រើទង្វើដ៏មិនគប្បីផ្សេងៗទៀត ដែលធ្វើឲ្យគាត់មិនអាចទ្រាំតទៅទៀតបាន។ គាត់បន្តថា ថៅកែរបស់គាត់ បានបញ្ជូនគាត់មកដាក់នៅក្រុមមួយឈ្មោះ រីហ្សេត អស់រយៈពេល ៥ ខែហើយ ប៉ុន្តែ បើទោះជាគាត់បានព្យាយាមទាក់ទងខាងក្រុមហ៊ុនខ្មែរឲ្យជួយដោះស្រាយយ៉ាងណា ក៏ខាងក្រុមហ៊ុនខ្មែរខាងលើមិនឆ្លើយតបនោះទេ។ អាស្រ័យហេតុនេះ គាត់ក៏សូមថ្នាក់ដឹកនាំនៃក្រសួងពាក់ព័ន្ធ ជាពិសេស ឯកឧត្តម អូស្មាន ហាស្សាន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស មេត្តាជួយដល់រូបគាត់បានវិលត្រឡប់មកស្រុកវិញផង។ លឹម ហុង

### ឃាត់ខ្លួនមនុស្សឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃជាច្រើនរយនាក់នៅក្នុងព្រៃ

https://kbn.news/ May 6, 2022

**ប្រទេសថៃ៖** នាថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២នេះ អាជ្ញាធរក្នុងប្រទេសថៃបានធ្វើការឃាត់ខ្លួនជនចំណាកស្រុក ព្រមទាំងមេខ្យល់ជនជាតិមីយ៉ាន់ម៉ា ដែលបានព្យាយាមធ្វើការឆ្លងដែនចូលទៅធ្វើការក្នុងប្រទេសថៃដោយខុសច្បាប់។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មាន Thairath។ ទាក់ទងនឹងការឃាត់ខ្លួនពលករខុសច្បាប់ទាំងអស់នោះធ្វើឡើងនៅក្នុងខេត្ត Tak នៃប្រទេសថៃ ដំបូងឡើយមានប្រជាពលរដ្ឋម្នាក់រស់នៅក្នុងស្រុក Wang Chao ខេត្ត Tak បានប្រទះឃើញមានមនុស្សជាច្រើននាក់ស្នាក់នៅក្នុងព្រៃនៃតំបន់នោះ ហើយក៏មានការសង្ស័យថា ពួកគេប្រហែលជាពលករឆ្លងដែនខុសច្បាប់ក៏បានរាយការណ៍ទៅកាន់អាជ្ញាធរភ្លាមៗ ដើម្បីចុះមកត្រួតពិនិត្យ។ ក្នុងនោះលោក Ekasit Wilaisilp ចៅហ្វាយស្រុក Wang Chao ខេត្ត Tak ដឹកនាំជាមួយនឹងកម្លាំងល្បាតព្រមទាំងអាជ្ញាធរមួយចំនួនបានចុះទៅធ្វើអន្តរាគមន៍ និងឆែកឆេរព្រមទាំងបានឃាត់ខ្លួនពលកររួមទាំងមេខ្យល់ខុសច្បាប់សរុបចំនួន១៥៦នាក់ លុះសួរនាំទើបដឹងថាពួកគេ បានធ្វើចំណាកស្រុកពីប្រទេសមីយ៉ាន់ម៉ាឆ្លងដែនអស់រយៈពេល៤ថ្ងៃទើបមកដល់ក្នុងព្រៃនេះក្នុងការលាក់ខ្លួនមុននឹងបន្តដំណើរទៅធ្វើការក្នុងទីក្រុងបាងកកបន្តទៀត។ បន្ទាប់ពីធ្វើការឃាត់ខ្លួនពលករខុសច្បាប់ទាំង១៥៦ នាក់នៅក្នុងព្រៃនោះរួចមក អាជ្ញាធរក៏បានបញ្ជូនពួកគេទៅកាន់មន្ត្រីស៊ើបអង្កេតបន្ត ដើម្បីចាត់ការទៅតាមផ្លូវច្បាប់ចំពោះពលករដែលបានឆ្លងដែនមកកាន់ប្រទេសថៃនេះ។ Thairath

## រយៈពេល១០ថ្ងៃ មន្ត្រីសុខាភិបាលប្រចាំច្រកអន្តរជាតិ
## អូរស្មាច់ ខេត្តឧត្តរមានជ័យ ចាក់វ៉ាក់សាំងជូនពលករមកពីប្រទេសថៃបានជិត៦០០នាក់

http://freshnewsasia.com/ 2022-05-06 07:47pm

**(ឧត្តរមានជ័យ)៖** ពលករ ក្មេង ចាស់ ប្រុស ស្រី ជិត៦០០នាក់ ដែលធ្វើដំណើរមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ ក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ បានទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ពីក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ទីប្រឹក្សាក្រសួងសុខាភិបាល និងជាប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានថ្លែងប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ឱ្យដឹងនៅរសៀលថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ថា ចាប់ពីថ្ងៃទី២៥ ខែមេសា ដល់ថ្ងៃទី៥ ខែឧសភា ពលករដែលវិលត្រឡប់មកពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ចំនួន៥៧២នាក់ ដោយបានទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ មុននឹងអនុញ្ញាតឱ្យបន្តដំណើរទៅស្រុកកំណើតរៀងៗខ្លួន។ លោកប្រធានមន្ទីរបានថ្លែងបញ្ជាក់ទៀតថា ពលករទាំង៥៧២នាក់ ដែលបានទទួលការចាក់វ៉ាក់សាំងនៅច្រកព្រំដែនអូរស្មាច់រួមមាន៖ ពលករបានចាក់ដូសទី១សរុបចំនួន៤៤នាក់ ក្នុងនោះស្រី២៨នាក់, ពលករបានចាក់ដូសទី២ សរុបចំនួន១៥នាក់ ក្នុងនោះស្រី៨នាក់ និងពលករបានចាក់ដូសទី៣សរុបចំនួន៥១៣នាក់ ក្នុងនោះស្រី២៣៣នាក់។ ចំពោះពលករដែលមិនទាន់បានចាក់វ៉ាក់សាំង គឺត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅក្រុងសំរោង ដើម្បីតាមដានសុខភាព បើមិនបញ្ជាក់ពីការឆ្លងជំងឺកូវីដ១៩ទេ យើងចាក់វ៉ាក់សាំងជូនគាត់ ទើបអនុញ្ញាតឱ្យគាត់បន្តដំណើរទៅទៀត។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២ គិតត្រឹមម៉ោង៤ល្ងាច មានប្រជាពលរដ្ឋ និងពលករឆ្លងដែនមកពីប្រទេសថៃ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់និងតាមច្រកទ្វារព្រំដែនជាំ មានចំនួន១៤៣,៣៩៤នាក់ ក្នុងនោះប្រជាពលរដ្ឋ និងពលករក្នុងខេត្តឧត្តរមានជ័យមានចំនួន១៨,២៧១នាក់៕

## ការបង់ប្រាក់លោះសម្រាប់ជនជាតិម៉ាឡេស៊ីដែលគ្រប់គ្រង
## ដោយក្រុមឆបោកនៅក្នុងប្រទេសកម្ពុជា ដើម្បីទទួលបានការដោះលែងរបស់ពួកគេ
## មិនផ្តល់ការធានាណាមួយឡើយ លើការវិលត្រឡប់ប្រកបដោយសុវត្ថិភាពរបស់ពួកគេ

https://www.khmertimeskh.com/ខ្មែរថាមស៍ May 7, 2022

មន្ត្រីនគរបាលកម្ពុជា រួមជាមួយនឹងមន្ត្រីសន្តិសុខរដ្ឋចិន ដែលមានមូលដ្ឋាននៅក្នុងក្រសួងមហាផ្ទៃកម្ពុជា បានប្រាប់កាសែតខ្មែរថាមស៍ថា ការបង់ប្រាក់ ឬផ្តល់ប្រាក់លោះដល់ក្រុមដែលចាប់ជនជាតិម៉ាឡេស៊ីនៅក្នុងដៃរបស់ពួកគេមិនមែនជាដំណោះស្រាយទេ។ ថ្លែងប្រាប់កាសែតខ្មែរថាមស៍ ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះ ពួកគេបាននិយាយថា ការទាមទារប្រាក់លោះនៃចំនួនដ៏ហួសចិត្តគ្រាន់តែជាល្បិចកលរបស់ក្រុមឆបោក ដើម្បីបញ្ឈប់កិច្ចខិតខំប្រឹងប្រែងរបស់ឪពុកម្តាយពីការ 'ទិញ' ការដោះលែងមនុស្សជាទីស្រឡាញ់របស់ពួកគេ ហើយជារឿយៗការដោះលែងមិនកើតឡើងបន្ទាប់ពីប្រាក់លោះត្រូវបានបង់។ «ប្រសិនបើគ្រួសារមានព័ត៌មានលម្អិតអំពីទីកន្លែងលាក់ខ្លួនដែលគេចោទប្រកាន់ថាពួកគេកំពុងត្រូវបានបង្ខាំង ពួកគេគួរតែបញ្ជូនវាទៅអាជ្ញាធរ ហើយបណ្តឹងផ្លូវការរបស់អាជ្ញាធរម៉ាឡេស៊ីគួរតែត្រូវបានប្រគល់ជូនឯកអគ្គរាជទូតកម្ពុជាប្រចាំនៅទីក្រុងកូឡាឡាំពួរ។

មន្ត្រីបាននិយាយថា "នៅពេលដែលរឿងនេះរួចរាល់ ប្រវ៉ាក់នៃព្រឹត្តិការណ៍នឹងត្រូវបានដាក់ចេញ ហើយក្រសួងមហាផ្ទៃ ចាត់វិធានការលើព័ត៌មានរបស់យើង ដោយអាចបើកប្រតិបត្តិការដើម្បីការពារការដោះលែងអ្នក

ដែលគេបង្ខាំង ទោះបីជាអ្នកដែកគេចាប់ខ្លះមិនចង់ត្រឡប់មកផ្ទះវិញក៏ដោយដោយមិនបានប្ដឹងតវ៉ាទេ ហើយគឺជាឪពុកម្ដាយរបស់ពួកគេដែលជំរុញឲ្យមានចំណាត់ការបែបនេះ»។ ពួកគេបានសង្កត់ធ្ងន់ថា ការចរចាដោយផ្ទាល់ ឬតាមរយៈឈ្មួញកណ្ដាលជារឿយៗនាំទៅរកផលវិបាកដ៏មហន្តរាយ ហើយបណ្ដាញផ្លូវការគឺល្អជាង ដោយសារវាជំរុញឱ្យអ្វីៗដំណើរការកាន់តែលឿន។ ពួកគេនិយាយថា ជាញឹកញយ អ្នកនយោបាយធ្វើសកម្មភាពក្នុងនាមបុគ្គលរបស់ពួកគេ ជូនកាលភ្ជាប់ដោយរបាយការណ៍ប៉ូលីស ដែលមិនមានផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជា។

"ដំណើរការដែលយើងបានពិពណ៌នាពីមុនគឺជាផ្លូវដ៏ល្អបំផុត ដើម្បីជានាការដោះលែងជនជាតិម៉ាឡេស៊ីឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយនៅពេលដែលពួកគេពន្យារពេលនេះយូរ ឬធ្វើឱ្យស្ថានភាពចំណាប់ខ្មាំងរបស់កូនពួកគេក្លាយជាសាធារណៈ នោះវាកាន់តែមានគ្រោះថ្នាក់ដោយអ្នកដែលត្រូវបានគេចោទប្រកាន់ថាត្រូវបានគេបង្ខាំង និងកាន់តែពិបាកសម្រាប់មន្ត្រីក្នុងការតាមដានពួកគេ ខណៈដែលពួកគេតែងតែផ្លាស់ប្ដូរទីតាំងជាញឹកញាប់»។ វាត្រូវបានគេជឿថា មានពលរដ្ឋម៉ាឡេស៊ីរហូតដល់១០០នាក់ ឬច្រើនជាងនេះកំពុងធ្វើការនៅក្នុងមជ្ឈមណ្ឌលបោកប្រាស់តាមអ៊ីនធឺណិត និងល្បែងស៊ីសងអនឡាញនៅទូទាំងប្រទេសកម្ពុជា ហើយក្នុងចំណោមទាំងនេះ មិនមែនទាំងអស់គ្នាចង់ត្រឡប់មកវិញទេ ខណៈដែលមនុស្សជាច្រើនត្រូវបានគេនិយាយថាសប្បាយចិត្តនឹងប្រាក់ចំណូលរបស់ពួកគេ។

ក្រុមឧក្រិដ្ឋជនជ្រើសរើសយុវជនមកពីប្រទេសម៉ាឡេស៊ីដោយសន្យាថា ពួកគេទទួលបានការងារជាមួយនឹងប្រាក់ចំណូលខ្ពស់ និងសំបុត្រយន្តហោះឥតគិតថ្លៃ ហើយជារឿយៗ ត្រូវបានជ្រើសរើសដោយអ្នករត់ការអោយក្រុមទាំងនោះ ហើយត្រូវបានផ្ដល់ប្រាក់កម្រៃយ៉ាងសមរម្យសម្រាប់បេក្ខជននីមួយៗ ដែលជ្រើសរើស អាស្រ័យលើអាយុ ភេទ រូបរាង កម្រិតជំនាញ។ល។ អ្នករត់ការអាចរកប្រាក់បានចន្លោះពី ៨,000 RM ទៅ ១០,000RM សម្រាប់បេក្ខជនម្នាក់ ដែលត្រូវបានជ្រើសរើស ហើយការរត់ការទាំងនេះមិនត្រឹមតែនៅក្នុងប្រទេសម៉ាឡេស៊ីប៉ុណ្ណោះទេ ប៉ុន្តែក៏មានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាផងដែរ ក្រោមរូបភាពផ្សេងៗ។

## គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ សរសើរកម្ពុជាចំពោះគោលនយោបាយការពារសិទ្ធិកុមារ

https://www.khmertimeskh.com/ May 7, 2022

គណៈកម្មាធិការស្ដីពីសិទ្ធិកុមារកាលពីថ្ងៃសុក្របានបញ្ចប់ការពិចារណារបស់ខ្លួនលើរបាយការណ៍តាមកាលកំណត់បូកបញ្ចូលគ្នា៤ ដល់ទី៦ របស់ប្រទេសកម្ពុជា ដោយគណៈកម្មាធិការអ្នកជំនាញ ដោយបានសរសើរគោលនយោបាយថ្មី ដើម្បីការពារសិទ្ធិកុមារ និងបានលើកជាសំណួរអំពីកំណើត ដែលមិនទាន់បានចុះឈ្មោះ និងច្បាប់ហាមឃាត់ការពពោះជំនួស។ អ្នកជំនាញនៃគណៈកម្មាធិការ បានស្វាគមន៍ថា រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាច្រើន រួមទាំងផែនការសកម្មភាព ស្ដីពីការការពារ និងការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងផែនការសកម្មភាព ស្ដីពីការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ហើយថា ខ្លួនបានបង្កើតច្បាប់ ស្ដីពីការការពារកុមារដែលបច្ចុប្បន្នស្ថិតនៅក្នុងទម្រង់ព្រាង។ ធនធានមានកម្រិតនៅតែជាបញ្ហាប្រឈមក្នុងការអនុវត្តវា។

អ្នកជំនាញគណៈកម្មាធិការមួយផ្សេងទៀតបាននិយាយថា ការចុះបញ្ជីកំណើតគឺមិនគិតថ្លៃទេ ប៉ុន្តែប្រហែល៣០ភាគរយ នៃកំណើត មិនបានចុះឈ្មោះ ដែលស្មើនឹងកុមារ ១,៦ លាននាក់ដែលមិនមានសំបុត្រកំណើត។ ហេតុអ្វីបានជាមានកំណើតច្រើនម្ល៉េះមិនបានចុះបញ្ជី? តើរដ្ឋាភិបាលបានដឹងពីកម្រៃក្រៅផ្លូវការទាក់ទងនឹងការចុះបញ្ជីកំណើតដែលគិតដោយភ្នាក់ងារអន្តរការី ហើយមានវិធានការណ៍ ដើម្បីទប់ទល់នឹងបញ្ហានេះដែរឬទេ?

អ្នកជំនាញគណៈកម្មាធិការមួយបានសួរថា តើគោលនយោបាយរបស់រដ្ឋាភិបាលមានអ្វីខ្លះលើការពពោះជំនួស។ អ្នកជំនាញបាននិយាយថា មានរបាយការណ៍ពីម្ដាយពពោះជំនួសត្រូវបានចាប់ខ្លួនព្រោះការអនុវត្តនេះខុសនឹងច្បាប់កម្ពុជា។ តើមានអ្វីកើតឡើងចំពោះកុមារដែលកើតមកដោយសារការពពោះជំនួសដោយខុសច្បាប់នៅកម្ពុជា ?

ដោយបានរាយការណ៍ពីរបាយការណ៍នេះ លោកស្រី ជូ ប៊ុន អេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងជាប្រធានគណៈប្រតិភូបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលបានប្ដេជ្ញាចិត្តខ្ពស់ក្នុងការលើកកម្ពស់ការការពារកុមារដោយបន្តអភិវឌ្ឍ និងអនុវត្តគោលនយោបាយជាតិ ច្បាប់ និងបទប្បញ្ញត្តិសមស្រប។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នឹងផ្ដោតលើការអនុវត្តគោលនយោបាយជាតិ និងលើការអនុម័តច្បាប់ស្ដីពីការការពារកុមារ ច្បាប់ស្ដីពីជនមានពិការភាព និងច្បាប់គាំពារសង្គម។ បញ្ហាលើការចុះបញ្ជីកំណើត លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា រាជរដ្ឋាភិបាលបានបង្កលក្ខណៈងាយស្រួល និងមិនគិតថ្លៃក្នុងការចុះបញ្ជីកំណើត ហើយមិនមានការរឹតបន្តឹងលើការចុះឈ្មោះបែបនេះទេ។ គាត់បានមានប្រសាសន៍ថា ការចុះបញ្ជីកំណើតគឺជាឱកាសមួយដើម្បីទទួលបានឯកសារអត្តសញ្ញាណសំខាន់ៗ ប៉ុន្តែឪពុកម្ដាយមួយចំនួនមិនចាប់អារម្មណ៍ក្នុងការទទួលបានឯកសារទាំងនេះទេ។ រដ្ឋាភិបាលកំពុងធ្វើការដើម្បីធ្វើទៅជាប្រព័ន្ធឌីជីថលនៃដំណើរការចុះឈ្មោះនៅឆ្នាំ ២០២៦។ ការចុះបញ្ជីកំណើតត្រូវបានផ្ដល់ជូនដោយមិនគិតពីសញ្ជាតិ ប៉ុន្តែមិនត្រូវបានផ្ដល់ជូនសម្រាប់មនុស្សដែលគ្មានឯកសារអត្តសញ្ញាណនោះទេ។

ទាក់ទងនឹងការពពោះជំនួស គណៈប្រតិភូបានលើកឡើងថា កម្ពុជាប្ដេជ្ញាគោរពសិទ្ធិកុមារ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ នេះមិនមែនជាករណីសុំកូនទេ ប៉ុន្តែជាករណីជួញដូរកុមារដោយសកម្មភាពពពោះជំនួសដោយខុសច្បាប់។ ចាប់តាំងពីឆ្នាំ២០១៦ វាគឺជាបាតុភូតថ្មីមួយ វាត្រូវបានគេរកឃើញថា កុមារត្រូវបានជួញដូរទៅក្រៅប្រទេសដោយគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ។ ស្ត្រីមានសិទ្ធិមានផ្ទៃពោះ ប៉ុន្តែមិនមានសិទ្ធិលក់ជីវិតកូនឡើយ ។ ស្ត្រីទាំងនេះចង់បានតែលុយមិនខ្វល់ពីកូនទេ ដោយព្យាយាមជួញដូរដោយខុសច្បាប់។ កុមារកាន់តែច្រើនកំពុងត្រូវបានជួញដូរ ហើយឪពុកម្ដាយរបស់កុមារដែលត្រូវបានជួញដូរមិនបានរាយការណ៍ខ្លួនឯងទេ។ សេចក្តីព្រាងច្បាប់កំពុងត្រូវបានពិភាក្សា ដើម្បីធានាថាវាឆ្លើយតបទៅនឹងហានិភ័យនៃការជួញដូរកុមារតាមរយៈការពពោះជំនួស។

នៅក្នុងសុន្ទរកថាបិទ លោកស្រី Mikiko Otani ប្រធានគណៈកម្មាធិការ និងអ្នកសម្របសម្រួលនៃក្រុមការងារសម្រាប់កម្ពុជា មានប្រសាសន៍ថា លោកស្រីពិតជារីករាយណាស់ដែលបានជួបពិភាក្សាដោយផ្ទាល់ជាមួយគណៈប្រតិភូកម្ពុជា។ លោកស្រីថា គណៈកម្មាធិការនឹងបង្កើតអនុសាសន៍ដែលខ្លួនសង្ឃឹមថានឹងជួយកម្ពុជាក្នុងការអនុវត្តអនុសញ្ញានេះ។ នៅក្នុងសុន្ទរកថាបញ្ចប់ លោកស្រី ជូ ប៊ុនអេង បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មាធិការសម្រាប់កិច្ចសន្ទនានេះ ដោយលោកស្រីមានប្រសាសន៍ថា គណៈប្រតិភូបានបង្ហាញពីសមិទ្ធិផលរបស់កម្ពុជាក្នុងការការពារសិទ្ធិកុមារ ប៉ុន្តែមានផ្នែកខ្លះដែលត្រូវការការកែលម្អ។

លោកស្រី ជូ ប៊ុនអេង បានរំលឹកឡើងវិញនូវការប្ដេជ្ញាចិត្តបន្តរបស់កម្ពុជាក្នុងការការពារសិទ្ធិកុមារ ហើយទន្ទឹងរង់ចាំបន្តធ្វើការជាមួយគណៈកម្មាធិការឆ្ពោះទៅសម្រេចបានគោលដៅនេះ។ គណៈប្រតិភូកម្ពុជាមានតំណាងមកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការជាតិប្រឆាំងការជួញដូរ ទីស្ដីការគណៈរដ្ឋមន្ត្រី និងបេសកកម្មអចិន្ត្រៃយ៍របស់កម្ពុជាប្រចាំការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ។ គណៈកម្មាធិការនឹងចេញសេចក្ដីសន្និដ្ឋានអង្កេតលើរបាយការណ៍កម្ពុជានៅចុងបញ្ចប់នៃសម័យប្រជុំលើកទីកៅសិបនៅថ្ងៃទី៣ មិថុនា។ *OHCHR.org*

## អ្នកជំនាញចារម្ភថា
## ការខកខានចុះសំបុត្រកំណើតរបស់កុមារអាចប្រឈមមុខនឹងអំពើជួញដូរមនុស្ស

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 07/05/2022 ដោយ៖អ៊ឹង ប៊ុនថន

អ្នកជំនាញខាងសិទ្ធិកុមារបាននិយាយកាលពីម្សិលមិញថា ការខកខានទៅចុះសំបុត្រកំណើតរបស់កុមារនៅកម្ពុជាគឺជាហានិភ័យនៅក្នុងអំពើជួញដូរមនុស្ស គឺតាមរយៈការស៊ីឈ្នួលពពោះជំនួស។ ការព្រមានបែបនេះដោយសារអ្នកជំនាញអះអាងថា នៅកម្ពុជាមានមនុស្ស ៣០% ឬប្រមាណ១.៦ លាននាក់ មិនបានចុះសំបុត្រកំណើត ទោះបីជាការទៅចុះសំបុត្រកំណើតមិនតម្រូវឲ្យបង់ប្រាក់ក៏ដោយ។

ដោយសរសើរប្រទេសកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរៀបចំគោលនយោបាយដើម្បីការពារសិទ្ធិកុមារ ប៉ុន្តែអ្នកជំនាញនៃគណៈកម្មាធិការសិទ្ធិកុមារបានចោទសួរអាជ្ញាធរកម្ពុជា អំពីកុមារដែលកើតមកដែលមិនទាន់បានចុះសំបុត្រកំណើត និងច្បាប់ហាមឃាត់ការពពោះជំនួស។ នេះជាការលើកឡើងនៅក្នុងរបាយការណ៍មួយដែលចេញដោយអ្នកជំនាញសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនៅថ្ងៃទី៦ ឧសភា ២០២២នេះ។ បើតាមអ្នកជំនាញដដែលនេះ នៅកម្ពុជាមានមនុស្ស៣០% ឬប្រមាណ១.៦ លាននាក់មិនបានចុះសំបុត្រកំណើត ទោះបីជាការទៅចុះសំបុត្រកំណើតមិនតម្រូវឲ្យបង់ប្រាក់ក៏ដោយ។ ការខកខានទៅចុះសំបុត្រកំណើតរបស់កុមារនៅកម្ពុជា ត្រូវបានអ្នកជំនាញព្រមានថា គឺជាហានិភ័យនៅក្នុងអំពើជួញដូរមនុស្ស គឺតាមរយៈការស៊ីឈ្នួលពពោះជំនួស។

ទាក់ទងនឹងការពពោះជំនួស គណៈប្រតិភូកម្ពុជាបានលើកឡើងថា កម្ពុជាប្តេជ្ញាគោរពសិទ្ធិកុមារ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ នេះមិនមែនជាករណីសុំកូនទេ ប៉ុន្តែជាករណីជួញដូរកុមារដោយសកម្មភាពពពោះជំនួសដោយខុសច្បាប់។ នេះបើតាមលោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ប្រទេសកម្ពុជា។ ទោះជាយ៉ាងណាតាំងពីឆ្នាំ២០១៦មក ករណីពពោះជំនួសនេះត្រូវបានគេរកឃើញថា កុមារត្រូវបានជួញដូរទៅក្រៅប្រទេសដោយគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ។ «កុមារកាន់តែច្រើនកំពុងត្រូវបានជួញដូរ ហើយឪពុកម្តាយរបស់កុមារដែលត្រូវបានជួញដូរមិនបានរាយការណ៍ដោយខ្លួនឯងទេ»។ នៅចំពោះមុខនេះ សេចក្តីព្រាងច្បាប់កំពុងត្រូវបានពិភាក្សា ដើម្បីធានាថាឆ្លើយតបទៅនឹងហានិភ័យនៃការជួញដូរកុមារតាមរយៈការពពោះជំនួសនេះ។ បើតាមលោកស្រី ជូ ប៊ុនអេង ច្បាប់ជាតិស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទត្រូវបានអនុម័តក្នុងឆ្នាំ២០០៨ ហើយគណៈកម្មាធិការជាតិសម្រាប់ការប្រឆាំងការជួញដូរមនុស្សត្រូវបានបង្កើតឡើង។ គណៈកម្មាធិការនេះបានធ្វើការដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ។ រដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ដ៏អាក្រក់បំផុតនៃពលកម្មកុមារសម្រាប់ឆ្នាំ ២០១៦-២០២៥ ក្នុងគោលបំណងលុបបំបាត់ពលកម្មកុមារ និងពលកម្មដោយបង្ខំ៕

## ថ្ងៃទី៩ឧសភា
## ចាប់ផ្តើមបន្តសុពលភាពប័ណ្ណ និងលិខិតពលករកម្ពុជា ធ្វើការនៅប្រទេសថៃឡើងវិញ

https://kohsantepheapdaily.com.kh/ ភ្នំពេញ០៧ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៩:៥៥

ភ្នំពេញ៖ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅថៃ បានប្រកាសថា បងប្អូនពលករកម្ពុជា ដែលមានប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស ( OCWC ) និងលិខិតធ្វើដំណើរពលករកម្ពុជា ធ្វើការនៅបរទេស ( TD ) ដែលបានផុតសុពលភាព ឬសុពលភាពនៅសល់ក្រោមរយៈពេល

៦ខែ អាចមកបន្តសុពលភាពប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC ) និងលិខិតធ្វើដំណើរពលករកម្ពុជា ធ្វើការនៅបរទេស ( TD ) នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២។ ការស្នើសុំបន្តសុពលភាពប័ណ្ណពលករ និងលិខិតធ្វើដំណើរនេះ ត្រូវធ្វើឡើង នៅក្រសួងការងាររបស់ប្រទេសថៃ ដែលមានអាសយដ្ឋាន Mitmaitri Road, Dindaeng, Bangkok 10400, Thailand។

សេចក្តីប្រកាស លើកឡើងថា តម្លៃបន្តសុពលភាពប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស ( OCWC ) និងលិខិតធ្វើដំណើរពលករកម្ពុជា ធ្វើការនៅបរទេស ( TD ) ថ្លៃ ១៤០០បាត ក្នុងពលករម្នាក់។ ការពិនិត្យពាក្យស្នើសុំបន្តសុពលភាព និងអនុម័ត មានរយៈពេល ៥ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងករណីឯកសារបញ្ជូនមកត្រឹមត្រូវ។ សេចក្តីប្រកាស លើកឡើងថា ករណីបងប្អូនពលករកម្ពុជា/និយោជក មានចម្ងល់ សូមទាក់ទងលេខទូរស័ព្ទរបស់អនុព័ន្ធការងារអមស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ 094 092 5905៕

## ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២

### ប្រតិភូកម្ពុជាទទួលបានការកោតសរសើរពីUN ជុំវិញដំណើរការការពាររបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ

https://news.btv.com.kh/ 2022/05/10 05:17:12 pm

ភ្នំពេញ ៖ កម្ពុជាមានមោទកភាពក្នុងជោគជ័យនាដំណើរការការពាររបាយការណ៍ជាតិស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ នៅប្រទេសស្វីស និងត្រូវបានអង្គការសហប្រជាជាតិកោតសរសើរ ពីការរៀនសូត្រមេរៀនជាច្រើនពីកម្ពុជា។ ក្រោយពីទទួលបានជោគជ័យគួរជាទីមោទកៈ ក្នុងដំណើរការការពាររបាយការណ៍ជាតិលើកទី៤-៥-៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ក្នុងកិច្ចប្រជុំលើកទី៩០ របស់គណកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស កាលពីថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០២២នោះ ប្រតិភូកម្ពុជាចំនួន៦រូប បានធ្វើមាតុភូមិនិវត្តន៍មកដល់កម្ពុជាវិញហើយប្រកបដោយសុវត្ថិភាព នៅរសៀលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២នេះ។

គណៈប្រតិភូមានចំនួន៦រូបរបស់កម្ពុជា បានដឹកនាំដោយលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិដើម្បីកុមារ និងសមាសភាពរួមមាន លោកជំទាវ ញ៉ែប សុភាព អគ្គនាយកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ, លោកជំទាវ សម្បត្តិ សុគន្ធា អគ្គនាយករងនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ, ឯកឧត្តមបណ្ឌិត ឌី ខាំបូលី អគ្គនាយករងនៃក្រសួងអប់រំយុវជន និងកីឡា, លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគជបជ, លោក ណុប ឬទ្ធា ប្រធានផ្នែកការពារកុមារ និងត្រួតពិនិត្យនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងមានការចូលរួមពី ឯកឧត្តម អន សុឃឿន ឯកអគ្គរដ្ឋទូត និងជាតំណាងអចិន្ត្រៃយ៍ និងសហការី បានទទួលឆ្លើយសំណួរចំនួន១០០ ដែលបានចោទសួរពីសំណាក់សមាជិកគណៈកម្មាធិការ ក្នុងរយៈពេលសរុបត្រឹម៤ម៉ោងនិងមានវេលា៤៨ម៉ោងរាយការណ៍បន្ថែមជាលាយលក្ខណ៍អក្សរជុំវិញការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា ។

ការឆ្លើយតបឥតអាក់របស់ប្រតិភូទាំងមូល បានធ្វើឱ្យលោកស្រី Mikiko Otani ប្រធានអង្គប្រជុំ និងសមាជិកគណៈកម្មាធិការទទួលស្គាល់ និងកោតសរសើរនូវរាល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជានៅក្នុងការពារសិទ្ធិកុមារ សមាជិករបស់គណៈកម្មាធិការខ្លះបាននិយាយថា បានរៀនសូត្រមេរៀនជាច្រើនពីកម្ពុជា ៕ អត្ថបទ ៖ វក្សា

## ការពន្យាប័ណ្ណការងារ
## និងប័ណ្ណធ្វើដំណើរសម្រាប់ពលករខ្មែរធ្វើការនៅថៃចាប់ផ្ដើមនៅថ្ងៃចន្ទនេះ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 09/05/2022 - 08:37 ដោយ៖ញ៉ឹម សុផល

នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២នេះ ក្រសួងការងារនៃប្រទេសថៃបានចាប់ផ្ដើមទទួលពាក្យស្នើសុំ និងទទួលឯកសារបន្តសុពលភាពប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស(OCWC) និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស(TD) សម្រាប់ពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ លោក ឌី ថេហូយ៉ា *ប្រធានផ្នែកកម្មវិធីប្រឆាំងអំពើជួញដូរមនុស្ស និងការពារសិទ្ធិពលករចំណាកស្រុកនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) បានថ្លែងថាពលករចំណាកស្រុកខ្មែរ មួយចំនួនមិនសូវទទួលបានព័ត៌មានជុំវិញការពន្យាប័ណ្ណពលករ និងលិខិតធ្វើដំណើររបស់ពួកគេប៉ុន្មានទេ ដោយសារនិយោជកខ្លះ និងពលករធ្វើការលើវិស័យក្រៅប្រព័ន្ធខ្លះ មិនសូវយល់ពីនីតិវិធី។ ទោះយ៉ាងណាលោក ឌី ថេហូយ៉ា កត់សម្គាល់ថាមានសកម្មភាពចេញចូលប្រទេសថៃ-កម្ពុជាច្រើនពីសំណាក់ពលករខ្មែរបន្ទាប់ពីមានការបើកច្រកអន្តរជាតិប៉ោយប៉ែត និងច្រកដូងកាលពីជាង១សប្ដាហ៍មុន។*

## ក្រសួងចាប់ផ្ដើមបន្តសុពលភាពបណ្ណ និងលិខិតពលករធ្វើការនៅប្រទេសថៃនាថ្ងៃនេះ

https://www.postkhmer.com/ អោម ប៊ុនធឿន | Publication date 09 May 2022 | 09:48 ICT

**ភ្នំពេញៈ** ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានឱ្យដឹងថា នៅថ្ងៃទី ៩ ខែឧសភា ឆ្នាំ ២០២២ នេះ ក្រសួងនឹងចាប់ផ្ដើមបន្តសុពលភាពបណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជាបានឱ្យដឹងថា សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាទាំងអស់ដែលមានបណ្ណពលករ-កម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ដែលបានផុតសុពលភាព ឬសុពលភាពនៅសល់ក្រោមរយៈពេល ៦ ខែ អាចមកបន្តសុពលភាពបានដោយដាក់ពាក្យស្នើសុំ និងទទួលឯកសារបន្តសុពលភាព OCWC និង TD តាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់នាយកដ្ឋានមុខរបរនៃក្រសួងការងារនៃព្រះរាជាណាចក្រថៃឡង់ដ៍តាមគេហទំព័រ https://cambodia-doe.com តែមួយគត់។ លិខិតជូនដំណឹងរបស់លោក អ៊ិត សំហេង ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០២២ បានឱ្យដឹងថា ការដាក់ពាក្យស្នើសុំបន្តសុពលភាពទាំងនេះតម្រូវឱ្យភ្ជាប់ឯកសារមួយចំនួនដូចជា៖ ស្កែនរូបថតទំហំ ៤x៦ របស់ពលករកម្ពុជា ស្កែន OCWC ដែលផុតសុពលភាពចូលក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម, ស្កែន TD ដែលបានផុតសុពលភាព ឬសុពលភាពនៅសល់ក្រោមរយៈពេល ៦ ខែ ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម និងផ្ដល់ឯកសារសំណៅដើម OCWC និង TD ដល់មន្ត្រីនាយកដ្ឋានមុខរបរនៃក្រសួងការងារ នៃព្រះរាជាណាចក្រថៃឡង់ដ៍តែមួយគត់ ដែលមានអាសយដ្ឋាន Mitmaitri Road, Dindaeng, Bangkok 10400, Thailand ។

ចំពោះដំណើរការឯកសារ នាយកដ្ឋានមុខរបរនៃក្រសួងការងារនៃព្រះរាជាណាចក្រថៃឡង់ដ៍ នឹងបញ្ជូនទិន្នន័យពាក្យស្នើសុំបន្តសុពលភាពរបស់ពលករកម្ពុជាមកប្រព័ន្ធទិន្នន័យ OCWC និង TD របស់គណៈកម្មការផ្ដល់ភាពស្របច្បាប់តាមរយៈ API។ ជាមួយគ្នានេះ ត្រូវប្រគល់ឯកសារសំណៅដើម OCWC និង TD មកការិយាល័យតំណាងរបស់អនុព័ន្ធការងារកម្ពុជាដែលមានទីតាំងនៅក្នុងនាយកដ្ឋានមុខរបររបស់ថៃ ដើម្បីបញ្ជូនបន្តទៅស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ។ លោករដ្ឋមន្ត្រីក្រសួងការងារបានឱ្យដឹងថា គណៈកម្មការផ្ដល់ភាពស្របច្បាប់នឹងផ្ទៀងផ្ទាត់

ទិន្នន័យ និងអនុម័តបន្តសុពលភាព OCWC និង ID។ រីឯការទទួលឯកសារសំណៅដើម OCWC និង TD ពីនាយកដ្ឋានមុខរបរនៅការិយាល័យតំណាងរបស់អនុព័ន្ធការងារកម្ពុជាដែលមានទីតាំងនៅក្នុងនាយកដ្ឋានមុខរបរនៃក្រសួងការងារនៃព្រះរាជាណាចក្រថៃឡង់ដ៏តែមួយគត់។ លោកបន្តថា គណៈកម្មការផ្ដល់ភាពស្របច្បាប់ និងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃសហការជាមួយនាយកដ្ឋានមុខរបរ និងមន្ទីរការងារនៃក្រសួងការងារថៃដើម្បីចែក OCWC និង TD ដែលបានបន្តសុពលភាពរួចរាល់ជូនពលករកម្ពុជា/និយោជកនៅការិយាល័យតំណាងរបស់អនុព័ន្ធការងារកម្ពុជាដែលមានទីតាំងនៅក្នុងនាយកដ្ឋានមុខរបររបស់ថៃ។

ការពិនិត្យពាក្យស្នើសុំបន្តសុពលភាព និងអនុម័ត OCWC និង TD មានរយៈពេល ៥ ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងករណីឯកសារបញ្ជូនមកត្រឹមត្រូវ។ ចំណែកតម្លៃបន្តសុពលភាព OCWC និង TD ចំនួន ១ ៤០០ (មួយពាន់បួនរយ) បាត ក្នុងពលករម្នាក់។ លោកបញ្ជាក់ថា៖ «បងប្អូនពលករកម្ពុជា/និយោជកអាចមកទទួលឯកសារបន្តសុពលភាព OCWC និង TD ទៅតាមការណាត់ នៅការិយាល័យតំណាងរបស់អនុព័ន្ធការងារកម្ពុជា ដែលមានទីតាំងនៅក្នុងនាយកដ្ឋានមុខរបរនៃក្រសួងការងារ នៃព្រះរាជាណាចក្រថៃឡង់ដែលមានអាសយដ្ឋាន Mitmaitri Road, Dindaeng, Bangkok 10400, Thailand»។

លោក គឹម សេង នាយកក្រុមហ៊ុន SKMM INVESTMENT ដែលនាំពលករ-ខ្មែរ ទៅធ្វើការនៅថៃ ថ្លែងនៅថ្ងៃទី ៨ ខែឧសភាថា ក្រសួងការងារពិតជាបានជួយសម្រួលដល់ពលករដែលទៅធ្វើការងារ និងស្នាក់នៅប្រទេសថៃបានច្រើនក្នុងនោះមានទាំងការផ្ដល់វីសា និងជួយបន្តសុពលភាពបណ្ណពលករ និងលិខិតធ្វើដំណើរពលករកម្ពុជានៅប្រទេសថៃ។ លោកបន្តថា ការជួយសម្រួលក្នុងការបន្តសុពលភាពបណ្ណពលករ និងលិខិតធ្វើដំណើរមានប្រយោជន៍សម្រាប់ពលករដោយមិនចាំបាច់ចំណាយពេលវេលាត្រឡប់មកកម្ពុជាដោយគ្រាន់តែបំពេញបែបបទដាក់តាមប្រព័ន្ធស្វ័យប្រវត្តិ និងប្រគល់ឯកសារសំណៅដើមទៅការិយាល័យតំណាងរបស់អនុព័ន្ធការងារកម្ពុជានៅប្រទេសថៃ។

លោក ឈុំ ពិសី នាយកក្រុមហ៊ុន CPS Best Team Services ថ្លែងនៅថ្ងៃទី ៨ ខែឧសភាថា បន្ទាប់ពីស្ថានភាពជំងឺកូវីដ ១៩ បានធូរស្បើយបានផ្ដល់អំណោយផលដល់ការបញ្ជូនពលករទៅធ្វើការនៅថៃដោយស្របច្បាប់។ ក្រុមហ៊ុនរបស់លោកបាន និងកំពុងប្រកាសជ្រើសរើសពលករស្របតាមច្បាប់នៃកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់គ្នា (MOU) រវាងកម្ពុជា-ថៃជាបន្តបន្ទាប់។ លោកថា ក្រោយកូវីដមានការបន្ធូរបន្ថយជាងមុនដែលមានអំណោយផលដល់ពលករ និងភាគីខាងក្រុមហ៊ុននៅថៃមិនសូវពិបាកក្នុងការចំណាយច្រើនពេលពលករចូលទៅធ្វើការនៅថៃ។ លោកថ្លែងថា៖ «បន្ធូរបន្ថយទី ១ គេអត់ធ្វើចត្តាឡីស័កដូចមុន ហេតុនេះមិនមានការចាំបាច់ក្នុងការចំណាយច្រើនសម្រាប់ការធ្វើចត្តាឡីស័ក ហើយឥឡូវហ្នឹងគេកាត់បន្ថយឯកសារខ្លះៗដែលធ្វើឱ្យពលករងាយស្រួលផងដែរគ្រាន់តែមិនទាន់ទូលាយដូចមុនកូវីដ»៕

## ពលរដ្ឋឆ្លងដែនតាមច្រកប៉ោយប៉ែត កើនឡើង ខណៈអាជ្ញាធរខ្មែរ គ្រោងជួបថៃបើកច្រក ២ទៀត

https://www.btv.com.kh/ 2022/05/10 10:57:46 am

ភ្នំពេញ៖ កំណើនប្រជាពលរដ្ឋ និងពលករខ្មែរ ឆ្លងដែនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយអាជ្ញាធរនៃខេត្តបន្ទាយមានជ័យ បានគ្រោងជួបពិភាក្សាជាមួយអាជ្ញាធរថៃ ដើម្បីបើកច្រកតំបន់ចំនួន ២ទៀត ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ បានមានប្រសាសន៍ថា ចាប់ពីថ្ងៃបើកច្រកទ្វារអន្តរជាតិប៉ោយប៉ែត ការធ្វើដំណើររបស់ពលរដ្ឋឆ្លងដែនទៅមកប្រទេសធម្មតា ប៉ុន្តែនារយៈពេលចុងក្រោយមកនេះមានការកើនឡើង ដោយសារអាជ្ញាធរបានជួយសម្រួលនូវឯកសារគតិយុត្តផ្សេងៗ កាន់តែមានភាពងាយស្រួល ។ ឯកឧត្តមបានបន្តថា សម្រាប់ការធ្វើប័ណ្ណព្រំដែន ក៏មានការកើនឡើង ព្រោះប្រជាពលរដ្ឋមានតម្រូវការឆ្លងទៅខេត្តស្រះកែវ នៃប្រទេសថៃ ពិសេសអ្នកទៅប្រកបរបរនៅក្នុងផ្សារថៃមួយឈ្មោះ "រោងក្លឿ" ហើយអាជ្ញាធរខេត្តបន្ទាយមានជ័យ គ្រោងជួបអាជ្ញាធរនៃប្រទេសថៃ បើកច្រកតំបន់ ២ទៀត គឺច្រកម៉ាឡៃ និងច្រកបឹងត្រកួន ដើម្បីសម្រួលដល់ការងារផ្សេងៗ របស់ពលរដ្ឋនៃប្រទេសទាំងពីរ ។ អភិបាលខេត្តបន្ទាយមានជ័យ បានបញ្ជាក់ថា ទន្ទឹមនេះអាជ្ញាធរតាមបន្ទាត់ព្រំដែន នៅតែបន្តអនុវត្តនូវវិធានការផ្សេងៗ ក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ រួមទាំងធ្វើការផ្សព្វផ្សាយ ដល់ពលករដែលចេញមកពីថៃ មិនទាន់ចាក់វ៉ាក់សាំង ឲ្យពួកគេទៅចាក់ឲ្យបានគ្រប់គ្នា ។

គួរបញ្ជាក់ថា អាជ្ញាធរនៃប្រទេសថៃ បានសម្រេចបើកច្រកទ្វារព្រំដែនមួយចំនួនឡើងវិញ ជាមួយកម្ពុជា ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ ក្នុងនោះមានច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីឲ្យពលរដ្ឋអាចធ្វើដំណើរចេញចូលឡើងវិញ ដោយមានភ្ជាប់ជាមួយនូវលិខិតឆ្លងដែន (Passsport), ប័ណ្ណព្រំដែន (Border Pass) រួមទាំងមានប័ណ្ណបញ្ជាក់ការវ៉ាក់សាំងកូវីដ-១៩ ផងដែរ ៕ អត្ថបទ៖ បាន សុខរិទ្ធិ

# ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

## ក្រសួងវប្បធម៌នឹងចាត់វិធានការចំពោះអ្នកសម្តែងឬផលិតករណាដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គម តម្លៃស្ត្រី និងកុមារ

https://www.information.gov.kh/ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២២ វិទ្យុជាតិកម្ពុជា ៖ លោកចេម ហួត

ភ្នំពេញ៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងចាត់វិធានការមួយចំនួនចំពោះផលិតករ សិល្បករណាដែលធ្វើឱ្យប៉ះ ពាល់ដល់សីលធម៌សង្គម តម្លៃស្ត្រី និងកុមារ តាមរយៈការហៅមកអប់រំ និងចាត់វិធានការផ្លូវច្បាប់ផ្សេងៗទៀតក្នុងករណីមិនរាងចាល។ ថ្លែងក្នុងពិធីបើកសិក្ខាសាលាស្តីពី «តួនាទីផលិតករ សិល្បកររួមចំណែកក្នុងការលើកកម្ពស់សីលធម៌សង្គមនិងទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារ«តាមរយៈវីដេអូខ្លី» នាព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២នៅទីស្តីការក្រសួង លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានផ្តល់ជាអនុសាសន៍ឱ្យ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវតាមដានលើមាតិកា ខ្លឹមសារ រូបភាព និងការសម្តែងតាមកម្មវិធីនានា ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាព និងការសម្តែងផ្ទាល់ ដែលមានលក្ខណៈអាសអាភាស ប៉ះពាល់ដល់សីលធម៌សង្គម និងតម្លៃស្ត្រី ។

ត្រូវចាត់វិធានការរដ្ឋបាលនានា ក្នុងគោលដៅអប់រំណែនាំដល់ក្រុមគោលដៅ ឬបុគ្គលដែលបង្កហេតុ។ លោកជំទាវ សង្កត់ធ្ងន់ថា ក្នុងករណីមិនរាងចាល អង្គភាពឬមន្ទីរ ត្រូវធ្វើរបាយការណ៍បញ្ជូនមកក្រសួង ដើម្បីក្រសួងស្នើសុំកិច្ចសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតចាត់វិធានការបន្ត។ សំឡេង ៖ «ចៀសវាងឱ្យបានច្រើនបំផុតនូវវីដេអូអាសអាភាសនាំឱ្យប៉ះពាល់ដល់សិលធម៌សង្គម តម្លៃស្ត្រីខ្មែរ ។ មុនដំបូងយើងធ្វើការអប់រំ ហើយបើដឹងហើយ ប្រៀនប្រដៅហើយនៅតែធ្វើ យើងនឹងមានវិធានការ ។ កន្លែងខ្លះក្រសួងមិនចង់ ចាត់វិធានការទេ កន្លែងខ្លះបើតាមច្បាប់ធ្ងន់ណាស់គឺទោសព្រហ្មទណ្ឌ តែយើងមិនធ្វើទេយើងនៅតែអប់រំចំពោះសិល្បករសិល្បៈការិនីរបស់យើងជាធំ»។

លោកជំទាវ រដ្ឋមន្ត្រី បានបន្ថែមថា ផលិតករ អ្នកនិពន្ធ សិល្បករ សិល្បការិនី អ្នកផលិតមាតិកាកម្សាន្តលើបណ្តាញសង្គម ត្រូវបញ្ជ្រាបខ្លឹមសារអប់រំក្នុងភាពយន្ត ឬវីដេអូ ដើម្បីចូលរួមទប់ស្កាត់ការប្រើប្រាស់អំពើហិង្សាលើស្ត្រីនិងកុមារ, ត្រូវប្រកាន់ភ្ជាប់នូវសីលធម៌ វិជ្ជាជីវៈរបស់ខ្លួន ក្នុងការផលិតស្នាដៃដើម្បីយកទៅផ្សព្វផ្សាយនៅតាមបណ្តាញសង្គម, ត្រូវបង្កប់ន័យអប់រំដល់ទស្សនិកជន អ្នកគាំទ្រ ជាពិសេសយុវជន និងកុមារ,ត្រូវបញ្ឈប់រាល់ខ្លឹមសារ ឬរូបភាព ដែលបង្កឱ្យមានការប៉ះពាល់ដល់ សីលធម៌សង្គម ប្រពៃណី ទំនៀមទម្លាប់ និងតម្លៃស្ត្រី និងត្រូវបង្កើតស្នាដៃដែលមានផលវិជ្ជមានដល់បុគ្គល ក្រុម សហគមន៍ និងសង្គមជាតិ។

លោកសុវណ្ណ ឫទ្ធី ហៅលោកតា វិចទ័រ ជាផលិតករម្នាក់បានគាំទ្រចំពោះប្រសាសន៍លើកឡើងរបស់លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនេះ ដោយលោកចាត់ទុកថា នេះជាសារមួយដ៏សំខាន់ក្នុងការរម្លឹកឱ្យអ្នកពាក់ព័ន្ធជាពិសេសអ្នកសម្តែង ឬផលិតករបានដឹង និងចូលរួមលើកកម្ពស់សីលធម៌សង្គម និងទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារឱ្យកាន់តែល្អប្រសើរ។

លោក ស៊ុំ សារុន ហៅ សាន់តា ជាអ្នកផលិតវីដូអូខ្លី និងជាតារាសម្តែងបែបកំប្លែងម្នាក់ ក៏បានគាំទ្រចំពោះក្រសួង វប្បធម៌ និងវិចិត្រសិល្បៈផងដែរ ក្នុងការចាត់វិធានការផ្សេងៗចំពោះអ្នកសម្តែង ឬផលិតករណា ដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គម តម្លៃស្ត្រី និងកុមារ ព្រោះថា អ្នកសម្តែង ឬផលិតករជាមនុស្សសាធារណៈមានអ្នកមើលច្រើនបើផ្សាយមិនល្អនឹងជះឥទ្ធិពលមិនល្អមកលើសង្គមជាពិសេសយុវវ័យ និងកុមារ។ សំឡេង៖ «ជាទូទៅការធ្វើវីដេអូរបស់ខ្ញុំបែបកំប្លែង សប្បាយៗតាមទីសាធារណៈ ហើយបន្តទៀតយើងនឹងបង្កើនការបញ្ចូលសារអប់រំឱ្យបានច្រើន ហើយបន្ទាប់ពីបានស្តាប់លោកអ៊ំជំទាវគាត់មានប្រសាសន៍អ៊ីចឹងធ្វើឱ្យយើងកាន់តែនឹកឃើញបង្កើតនូវអ្វីដែលថ្មី និងមានការអប់រំ» ។

ជាមួយគ្នានេះដែរ លោកជំទាវបណ្ឌិត សភាចារ្យ ភឿង សកុណារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏បានវាយតម្លៃខ្ពស់ចំពោះ អ្នកផលិតវីដេអូកម្សាន្តនៅលើបណ្តាញសង្គមនានាជាលក្ខណៈក្រុមឬបុគ្គល គឺពួកគេបានបញ្ចូលនូវសារអប់រំច្រើនដល់មនុស្សគ្រប់វ័យរួចមកហើយ តែក៏នៅមានភាពយន្តនិងវីដេអូមួយចំនួនបានបង្កើតឱ្យមានវប្បធម៌ហិង្សា ការសេងសឹក ការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន និងអំពើហិង្សាក្នុងទម្រង់ធ្ងន់ធ្ងរ ដែលជាវប្បធម៌មួយមិនល្អ នាំឱ្យក្មេងៗជំនាន់ក្រោយយកមកចម្លង និងអនុវត្តតាម៕

## ពលករខ្មែរ១៣នាក់និងមេខ្យល់ថៃម្នាក់ត្រូវយោធាថៃឃាត់ខ្លួន

http://nokorwatnews.com/ 11/05/2022

ប្រទេសថៃ ៖ កម្លាំងសមត្ថកិច្ចតាមព្រំដែនកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ថា កម្លាំងទាហានអង្គភាពចំពោះកិច្ចទី១១១ សហការជាមួយកម្លាំងទាហានប្រាណទី១២ បានចុះល្បាតតាមបន្ទាត់ព្រំដែនស្រះកែវ ជាប់ជាមួយខេត្តបន្ទាយមានជ័យ របស់កម្ពុជា បានប្រទះឃើញពលករខ្មែរឆ្លងដែនតាមច្រករបៀង ចូលមកប្រទេសថៃ

ដោយខុសច្បាប់ចំនួន២លើក និងចាប់ឃុំពលករខ្មែរបានចំនួន១៣នាក់ និងមេខ្យល់ម្នាក់។ សមត្ថកិច្ចបានឲ្យដឹងថា បរិវេណដែលជួបការលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ រួមមាន បរិវេណភូមិ ណងម៉ាំង ឃុំណងវែង ស្រុកគោកយ្យូង ខេត្តស្រះកែវ សមត្ថកិច្ចចាប់ឃុំបាន១០នាក់ ក្នុងនោះប្រុស៦ ស្រី៤ និងមេខ្យល់ជនជាតិថៃម្នាក់ និងរថយន្តមួយគ្រឿងម៉ាកFord ព៌ណស នៅបរិវេណភូមិទព័ធីមសះយ៉ាម៣ ឃុំទ័ពថៃ ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ចាប់ឃុំពលករខ្មែរបានចំនួន៣នាក់ ក្នុងនោះប្រុស២នាក់ និងស្រី១នាក់។ក្រោយការសួរនាំ និងធ្វើកំណត់ហេតុចាប់ឃុំ សមត្ថកិច្ចបានបញ្ជូនពលករខ្មែរទាំងអស់ ប្រគល់ឱ្យជំនាញ ដើម្បីចាត់ការតាមច្បាប់បន្ត៕

# ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២

## សម្ដេច ស ខេង ៖ វិស័យកសិកម្ម ជាចលករជំរុញ បដិវត្តន៍ឧស្សាហកម្ម ព្រមទាំងកាត់បន្ថយ ការចំណាកស្រុក

https://dap-news.com/ ByPH104Posted on May 12, 2022

**ភ្នំពេញ ៖ សម្ដេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងថា វិស័យកសិកម្ម ជាចលករជំរុញ បដិវត្តន៍ឧស្សាហកម្ម ពិសេសកសិឧស្សាហកម្ម ទាំងពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងកាត់បន្ថយចំណាកស្រុក និងបង្កើន ឱកាសសម្រាប់ការនាំចេញ។**

ក្នុងពិធីសម្ពោធរោងចក្រ ផលិតចំណីអាហាររបស់ក្រុមហ៊ុន ស៊ី.ភី ខេមបូឌា ចំកាត់ ស្ថិតនៅឃុំជំពូវន្ត ស្រុកជុំគិរី ខេត្តកំពត នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ សម្ដេច ស ខេង បានឲ្យដឹងថា វិស័យកសិកម្មនៅកម្ពុជា បាន និងកំពុងដើរតួនាទីសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងកាត់បន្ថយភាពក្រីក្រ របស់ប្រជាជន ពិសេសចូលរួមចំណែក ២០ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ សម្ដេច បន្តថា វិស័យកសិកម្ម កាន់តែដើរ តួនាទីសំខាន់នៅក្នុងបរិបទ នៃការប្រឈមមុខនឹងវិបត្តិកូវីដ-១៩ និងការប្រែប្រួល ជាអវិជ្ជមានមួយចំនួន របស់សាកលោក។ សម្ដេច បញ្ជាក់ថា «វិស័យកសិកម្ម ក៏ជាចលករជំរុញបដិវត្តន៍ ឧស្សាហកម្មពិសេសកសិឧស្សាហកម្ម សម្រាប់ ទាំងពេលបច្ចុប្បន្ន និងអនាគត ដែលនាំមកនូវពហុប្រយោជន៍ និងគុណតម្លៃជាច្រើន ដូចជាការបន្ថែមតម្លៃ ការបង្កើនគុណភាព និងរយៈពេលនៃការរក្សាទុកផលិតផល ការពង្រីកទីផ្សារកសិផល ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការបង្កើតការងារក្នុងស្រុក កាត់បន្ថយចំណាកស្រុក និងបង្កើន ឱកាសសម្រាប់ការនាំចេញផលិតផល»។

នាឱកាសនោះ សម្ដេចក្រឡាហោម ស ខេង ក៏បានបង្ហាញការគាំទ្រ និងលើកទឹកចិត្តក្រុមហ៊ុន បន្តខិតខំកសាងរោងចក្រផលិត ចំណីអាហារបែបនេះ បន្ថែមទៀត នៅតាមបណ្ដាខេត្ត ដែលមានសក្ដានុពលនៅកម្ពុជា ។ សម្ដេច ក៏បានស្នើឲ្យក្រុមហ៊ុនជួយផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលបច្ចេកទេស ដល់មន្ត្រីកសិកម្ម និស្សិត សហគមន៍ និង ប្រជាកសិករអំពីបច្ចេកទេសថ្មីៗ៕

## កងទ័ពកម្ពុជា ចូលរួមប្រជុំ ដើម្បីបង្កើនទំនាក់ទំនងជាមួយវៀតណាម និងថៃ

https://kohsantepheapdaily.com.kh/ ភ្នំពេញ១១ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៨:៥៤

ភ្នំពេញ៖ គណៈប្រតិភូកងទ័ពកម្ពុជា ២ក្រុម បានអញ្ជើញទៅចូលរួមកិច្ចប្រជុំដាច់ដោយឡែកពីគ្នា នៅប្រទេសវៀតណាម និងប្រទេសថៃ ដើម្បីពង្រឹងទំនាក់ទំនងរវាងកងទ័ពប្រទេសជាប់ព្រំដែនកម្ពុជា និងវៀតណាម ព្រមទាំងរវាងកងទ័ពកម្ពុជា និងកងទ័ពថៃ។ កាលពីព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នេះ លោកឧត្តមសេនីយ៍

ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ ចូលរួមកិច្ចប្រជុំជាមួយលោកឧត្តមសេនីយ៍ ទោ ឡេ ឌឹកថាយ មេបញ្ជាការ បញ្ជាការដ្ឋានកងទ័ពការពារព្រំដែន ក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ បាវិត-ម៉ុកបាយ ខេត្តតៃនីញ ប្រទេសវៀតណាម ដើម្បីពិភាក្សា និងវាយតម្លៃលើលទ្ធផលកិច្ចសហប្រតិបត្តិការលើការងារគ្រប់គ្រង និងការពារព្រំដែនក្នុងឆ្នាំ២០២១ និងលើកទិសដៅបន្ត សម្រាប់ឆ្នាំ២០២២។

ក្នុងជំនួបនេះ ភាគីទាំងពីរ បានសម្តែងនូវមោទនភាពចំពោះការរីកចម្រើននៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ ជាមួយនឹងបញ្ជាការដ្ឋានកងទ័ពការពារព្រំដែនវៀតណាម ដោយសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើនរាប់ចាប់តាំងពីឆ្នាំ២០០៤ មក ហើយមកដល់ឆ្នាំ២០២១ កន្លងទៅនេះ ក៏បានឈានឡើងដល់កម្រិតមួយទៀត គឺការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការការពារព្រំដែនគោកទ្វេភាគី រវាងកងឯកភាពទាំងពីរ ដែលជាមូលដ្ឋានក្នុងការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការងារ ដើម្បីធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ និងការកសាងព្រំដែនគោកនៃប្រទេសទាំងពីរ ឱ្យទទួលបាននូវសុខសន្តិភាព មិត្តភាព ស្ថិរភាព កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះ ភាគីទាំងពីរ ក៏បានធ្វើការវាយតម្លៃខ្ពស់ចំពោះលទ្ធផលកិច្ចសហប្រតិបត្តិការ ក្នុងរយៈពេលពេញមួយឆ្នាំ២០២១ កន្លងទៅ ដោយក្នុងនេះកងទ័ពការពារព្រំដែននៃប្រទេសទាំងពីរ បានបន្តកិច្ចសហការជាមួយគ្នាយ៉ាងសកម្មលើការចូលរួមចំណែកទប់ស្កាត់អំពើភេរវកម្ម និងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ក៏ដូចជាការសម្រេចបាននូវការដោះស្រាយភារកិច្ចការងារព្រំដែនផ្សេងទៀត ទទួលបានលទ្ធផលល្អប្រសើរ ទោះបីជាប្រទេសទាំងពីរ បានជួបប្រទះនូវបញ្ហាប្រឈមដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩យ៉ាងណាក្តី ហើយមិនត្រឹមតែប៉ុណ្ណោះ ក៏បានផ្តល់ការឧបត្ថម្ភជួយគ្នាទៅវិញទៅមកទាំងស្មារតី និងសម្ភារ ដើម្បីរួមគ្នាទប់ស្កាត់ និងគ្រប់គ្រងការរីករាលដាលនៃជំងឺដ៏កាចសាហាវនេះផងដែរ។

លទ្ធផលសំខាន់ៗ ដែលសម្រេចបានមកនេះ ពិតជាបានចូលរួមចំណែកដល់ការរឹតចំណងមិត្តភាពរវាងប្រទេស និងប្រជាជនទាំងពីរ និងការថែរក្សាបាននូវសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខនៅតាមបណ្តោយព្រំដែន ដែលជាការបង្កលក្ខណៈអំណោយផលដល់ការផ្លាស់ប្តូរពាណិជ្ជកម្ម, ទេសចរណ៍ និងជីវភាពរស់នៅដោយសុខសាន្តរបស់ប្រជាជនទាំងសងខាង ស្របតាមទិសស្លោក "ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងស្ថិរភាពយូរអង្វែង"។

សម្រាប់ទិសដៅឆ្នាំ២០២២ ភាគីទាំងពីរ បានឯកភាពលើការបន្តកិច្ចខិតខំប្រឹងប្រែង សហការអនុវត្តភារកិច្ចស្របតាមផែនការសហប្រតិបត្តិការប្រចាំឆ្នាំ រវាងក្រសួងការពារជាតិនៃប្រទេសទាំងពីរ និងការជំរុញការអនុវត្តអនុស្សារណៈនៃការយោគយល់រវាងកងឯកភាពទាំងពីរឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ សំដៅនាំមកនូវការរីកចម្រើនកាន់តែសកម្មនៃទំនាក់ទំនងរវាងកងទ័ពការពារព្រំដែននៃប្រទេសទាំងពីរ ដើម្បីធានាបាននូវព្រំដែនសន្តិភាព និងការអភិវឌ្ឍរួមគ្នា ដោយផ្តោតលើអាទិភាពមួយចំនួន ដូចជាៈ ការបន្តកិច្ចសហការជួយគ្នាទៅវិញទៅមក ដើម្បីរួមគ្នាទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩, ការចូលរួមបង្កលក្ខណៈដល់ភារកិច្ចខ័ណ្ឌសីមា និងការបោះបង្គោលព្រំដែនឱ្យបានឆាប់ចប់ជាស្ថាពរ ទៅតាមផែនការការងាររបស់រដ្ឋាភិបាលនៃប្រទេសទាំងពីរ, ការជំរុញកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ និងការគាំទ្រលើការហ្វឹកហ្វឺនបណ្តុះបណ្តាលធនធានមនុស្ស។

ដោយឡែក នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នេះ កិច្ចប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគថៃ-កម្ពុជា លើកទី២៨ រវាងយោធភូមិភាគទី៥ (កម្ពុជា) និងកងទ័ពភូមិភាគទី១(ថៃ) បានបិទកិច្ចប្រជុំ ក្រោយពីបាន

ប្រព្រឹត្តធ្វើឡើងអស់ រយៈពេល ៣ថ្ងៃ គឺចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នៅកន្លែងលំហែកាយកងទ័ពជើងគោកថៃ ស្ថិតនៅស្រុកសុនប្រាឌិផាត់ ខេត្តប្រាក់ជួបគីរីខ័ន្ធ ព្រះរាជាណាចក្រថៃ។ កិច្ចប្រជុំ បានប្រព្រឹត្តទៅក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ឯក ឯក សំអួន មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥ ភាគីកម្ពុជា ឯភាគីថៃ ដឹកនាំដោយលោកឧត្តមសេនីយ៍ទោ ស៊ុបសាន់ ណងប៊ួឡាង មេបញ្ជាការកងទ័ពភូមិភាគទី១ ជាសហប្រធាននៃអង្គប្រជុំរួម។

កិច្ចប្រជុំនេះ មានគោលបំណង ដើម្បីពិភាក្សារកទិសដៅដោះស្រាយ និងរំលឹកឡើងវិញនូវភាពរីកចម្រើននៃការអភិវឌ្ឍន៍លើវិស័យផ្សេងៗ ពាក់ព័ន្ធទៅនឹងសម្ព័ន្ធភាពកងទ័ព និងសន្តិសុខតាមព្រំដែន ដោយពិចារណា ក្នុងការកំណត់ទស្សនវិស័យក្នុងក្របខ័ណ្ឌគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ។ អង្គប្រជុំបានរំលឹកឡើងវិញ អំពីលទ្ធផលនៃការប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ ថៃ-កម្ពុជា លើកទី២៧ រវាងយោធភូមិភាគទី៥ និងកងទ័ពភូមិភាគទី១ ដោយនាំលទ្ធផលនៃការប្រជុំដូចបានពោលខាងលើ ដើម្បីយកមកពិចារណា និងរៀបចំធ្វើកំណត់ហេតុរួមក្នុងការប្រជុំលើកនេះ។ ក្នុងរយៈពេលបីថ្ងៃនេះ អង្គប្រជុំមានការពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកពាក់ព័ន្ធនិងបញ្ហាផ្សេងៗ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ(RBC) ក្រៅពីនេះភាគីទាំងពីរបានលើកស្ទួយឲ្យមានការអនុវត្តន៍ ទៅតាមអនុស្សារណៈ នៃការយោគយល់គ្នា ស្តីអំពីការត្រួតពិនិត្យ និងរៀបចំបោះបង្គោលសីមាព្រំដែន ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០ មានប្រសិទ្ធភាពខ្ពស់។

ភាគីទាំងពីរ បានឯកភាពរួមគ្នាឲ្យមានការប្រជុំពិភាក្សា ដើម្បីកំណត់ទិសដៅក្នុងការទប់ស្កាត់ការលបលួចកសាងសំណង់ខុសច្បាប់ និងការចោលសំណល់រឹង បង្ហូរសំណល់រាវចូលអូរព្រំដែន កម្ពុជា-ថៃ ភាគីទាំងពីរ បានឯកភាពគ្នា ស្នើឲ្យមានការដើរល្បាតដោយមានការទំនាក់ទំនងគ្នាតាមបណ្តោយព្រំដែន កិច្ចសហប្រតិបត្តិការល្បាតដើម្បីទប់ស្កាត់ការលបលួចកាប់ឈើខុសច្បាប់ និងការប្រយុទ្ធប្រឆាំងការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន តាមបរិវេណព្រំដែន ទាំងការល្បាតផ្លូវអាកាស តាមបណ្តោយព្រំដែនស្នើឲ្យមានការទំនាក់ទំនងជាមុនសិនមុននឹងមានការហោះហើរ និងទប់ស្កាត់ការរីករាលដាលនូវជំងឺកូវីដ-១៩។ អង្គប្រជុំបានឯកភាពរៀបចំការប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ កម្ពុជា-ថៃ លើកទី២៨ នៅព្រះរាជាណាចក្រកម្ពុជា។ សម្រាប់ការកំណត់ពេលវេលា និងទីកន្លែង នឹងមានការជូនដំណឹងតាមរយៈក្រុមលេខាភាគីទាំងពីរ៕

## ក្រសួងការងារបញ្ជាក់សាជាថ្មីថា កម្ពុជាមិនទាន់បញ្ជូនពលករតាមរដូវកាលទៅធ្វើការនៅក្រៅប្រទេសនៅឡើយទេ សូមពលរដ្ឋកុំភ័ន្តច្រឡំ និងជឿតាមការឃោសនារបស់ជនខិលខូច

http://freshnewsasia.com/ 2022-05-12 04:21pm

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់សាជាថ្មីជូនប្រជាពលរដ្ឋ សាធារណជន ក៏ដូចជាស្ថាប័នពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា បច្ចុប្បន្នកម្ពុជាមិនទាន់មានការបញ្ជូនពលករតាមរដូវកាល ទៅធ្វើការនៅក្រៅប្រទេសនៅឡើយទេ សូមកុំមានការភ័ន្តច្រឡំ និងជឿតាមការឃោសនារបស់ជនខិលខូច ជៀងវាងការខាតបង់ថវិកា និងពេលវេលា។ នេះបើតាមសេចក្តីជូនដំណឹងដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២នេះ។ ការបញ្ជាក់របស់ក្រសួងការងារខាងលើនេះ ក៏ដោយសារកន្លងមកក្រសួងបានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរមូលដ្ឋានដែលបានលើកឡើងថា មានជនខិលខូចមួយចំនួនទាំងជនជាតិខ្មែរ និងជនបរទេស ដែលជ្រកក្រោមស្លាកសាលាភាសា អង្គការ និងសមាគមផ្សេងៗ បានចុះផ្សព្វផ្សាយជ្រើសរើស និងប្រមូលថវិកាពីប្រជាពលរដ្ឋ ដោយធានាអះអាងថា អាចបញ្ជូនទៅធ្វើការតាមរដូវកាលនៅក្រៅប្រទេសដែលមានប្រាក់ចំណូលខ្ពស់។

ក្រសួងការងារបានបញ្ជាក់ទៀតថា កន្លងមកក្រសួងក៏ធ្លាប់ទទួលបានការស្នើសុំឱ្យមានកិច្ចសហការលើការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសតាមរដូវកាលផងដែរ ប៉ុន្តែក្រសួងសង្កេតឃើញថា ការបញ្ជូនពលករទៅធ្វើការតាមរដូវកាលនេះ នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា មិនទាន់មានយន្តការសមស្រប និងច្បាស់លាស់ ការងារមានរយៈពេលខ្លី ខណៈការចំណាយខ្ពស់ មិនសមស្របនឹងប្រាក់ចំណូលដែលទទួលបាន ហើយលក្ខខណ្ឌការងារនៅមិនទាន់ត្រូវបានធានា និងការពារដោយបទដ្ឋានគតិយុត្តនៃប្រទេសទទួលនៅឡើយ។

ឆ្លៀតក្នុងឱកាសនេះ ក្រសួងការងារបានបញ្ជាក់សាជាថ្មីជូនប្រជាពលរដ្ឋ សាធារណជន ក៏ដូចជាស្ថាប័នពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា « **បច្ចុប្បន្នកម្ពុជាមិនទាន់មានការបញ្ជូនពលករតាមរដូវកាលទៅធ្វើការនៅក្រៅប្រទេសនៅឡើយទេ ដោយទាមទារឱ្យមានការសិក្សាស្រាវជ្រាវលើស្ថានភាពសេដ្ឋកិច្ច នៃប្រទេសទទួល លក្ខខណ្ឌការងារ កម្រៃសេវាដែលពលករត្រូវចំណាយ ជាពិសេសលើយន្តការនៃការបញ្ជូន ដើម្បីទទួលបានឱកាសការងារសមរម្យនៅក្រៅប្រទេស**»។ ករណីមានកិច្ចព្រមព្រៀងលើការបញ្ជូនពលករទៅធ្វើការតាមរដូវកាលនៅក្រៅប្រទេសជាមួយប្រទេសណាមួយនោះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនឹងជូនដំណឹងជាសាធារណៈ ដូច្នេះសូមប្រជាពលរដ្ឋ សាធារណជន ក៏ដូចជាស្ថាប័នពាក់ព័ន្ធទាំងអស់កុំមានការភ័ន្តច្រឡំ និងជឿតាមការឃោសនារបស់ជនខិលខូចទាំងនោះ ជៀងវាងការខាតបង់ថវិកា និងពេលវេលា៕

## អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរចំនួន ១៣នាក់ ឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់

https://www.rfa.org/khmer/ ដោយ ថា ថៃ2022.05.11

អាជ្ញាធរថៃ ចាប់ខ្លួនពលករខ្មែរចំនួន ១៣នាក់ ក្នុងនោះមានស្ត្រី ៥នាក់ កាលពីថ្ងៃទី១០ ខែឧសភា។ ហ្វេសប៊ុករបស់ទាហានថៃ ប្រចាំនៅខេត្តស្រះកែវ (Sakeo) ចុះផ្សាយនៅយប់ថ្ងៃទី១០ ថា ពលករខ្មែរទាំងនោះ ត្រូវបានអាជ្ញាធរថៃ ចាប់ខ្លួនក្នុងពេលដែលពួកគេធ្វើដំណើរតាមរថយន្តរបស់មេខ្យល់ជាជនជាតិថៃ នៅតំបន់ព្រំដែនខេត្តស្រះកែវ (Sakeao) ប្រទេសថៃ ដោយខុសច្បាប់។ ពេលសមត្ថកិច្ចថៃសួរនាំនោះ គឺជនជាតិខ្មែរទាំង ១៣នាក់ បានប្រាប់ថា ពួកគេធ្វើដំណើរទៅខេត្តចន្ទបុរី (Chanthaburi) ខេត្ត រ:យ៉ង (Rayong) និងខេត្តនន្ទបុរី (Nonthaburi) ដើម្បីរកការងារធ្វើ ។ ក្រោយពីសួរចម្លើយពលករខ្មែរទាំង ១៣នាក់ និងមេខ្យល់ថៃ ត្រូវបានអាជ្ញាធរថៃបញ្ជូនទៅកាន់កម្លាំងជំនាញ ដើម្បីចាត់ការតាមច្បាប់។

ស្នងការរងទទួលបន្ទុកការពារព្រំដែនខេត្តបន្ទាយមានជ័យ លោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា តាមរយៈសារតេឡេក្រាមថា ពលករទាំងនោះ នឹងបញ្ជូនមកដល់កម្ពុជាវិញនៅល្ងាចថ្ងៃទី១០ ខែឧសភា ។ លោកបញ្ជាក់ថា អាជ្ញាធរថៃតែងចាប់បញ្ជូនពលករខ្មែរ មកឲ្យអាជ្ញាធរកម្ពុជាវិញជារៀងរាល់ថ្ងៃ គ្រាន់តែថ្ងៃខ្លះមានចំនួនច្រើនថ្ងៃខ្លះមានចំនួនតិចប៉ុណ្ណោះ។

ប្រធានផ្នែកប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសក៍ នៃអង្គការសង់ត្រាល់ (Central) លោក ឌី ថេហូយ៉ា កត់សម្គាល់ថា ការបើកច្រកព្រំដែន គឺបើកជាផ្លូវការ ប៉ុន្តែពលករខ្មែរចំណាកស្រុកទាំងនោះ គឺឆ្លងដែនតាមច្រករបៀងជាច្រកមិនផ្លូវការ ទើបមានការចាប់ខ្លួនជាបន្តបន្ទាប់ ។ លោកបន្ថែមថា ពលករគ្មានឯកសារស្របច្បាប់នោះទេ ព្រោះថា បើពួកគេទៅស្របច្បាប់តម្រូវឱ្យដាក់ពាក្យតាមក្រុមហ៊ុនពលករណាមួយ ហើយការរង់ចាំពេលយូរអស់ប្រាក់ច្រើន អ៊ីចឹង គាត់មានតែជម្រើសឆ្លងដែនខុសច្បាប់ គឺលឿន ហើយចង់ទៅពេលណា គឺបានពេលហ្នឹង៖ « គួរតែសម្រួលធ្វើឯកសារប៉ាស្ព័រ (Passport) ហ្នឹង តាមជាយដែនហ្នឹងណា ហើយប្រកាសជាផ្លូវការទៅ ក្នុងតម្លៃដែលមិនថ្លៃ ដែលគាត់អាចធ្វើបាន អីជាដើមចឹង អាហ្នឹងវាជាជម្រើសមួយពាក់ព័ន្ធការផ្ដល់ឯកសាររបស់រដ្ឋាភិបាលទី២ គឺពាក់ព័ន្ធនឹងរឿង ប្រសិនគាត់ហៅថាឆ្លងដែនមិនមានជម្រើសល្អហើយ មានតែមិនស្របច្បាប់អ៊ីចឹង រដ្ឋាភិបា

លកម្ពុជា ក៏ត្រូវតែអន្តរាគមន៍ ជួយពួកគាត់ឱ្យបានជាបន្ទាន់ពាក់ព័ន្ធ និងរឿងការចាប់ខ្លួន ដើម្បីកុំឱ្យគាត់ប្រឈមអំពីការដាក់ទោសទណ្ឌពិន័យជាប្រាក់អីថែមជាដើម»។ លោក ឌីថេ ហូយ៉ា ព្រួយបារម្ភថា ប្រសិនបើបញ្ហាទាំងនេះ មិនត្រូវបានយកចិត្តទុកដាក់ដោះស្រាយទេ នឹងបង្កឲ្យមានបញ្ហាសង្គមធ្ងន់ធ្ងរនៅពេលខាងមុខ។ លោកបន្ថែមទៀតថា ដំណោះស្រាយយូរអង្វែង គឺរដ្ឋាភិបាលត្រូវបង្កើនការងារក្នុងស្រុក ដោយបង្កើនវិនិយោគក្នុងស្រុកច្រើន ពិសេសវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្មកែច្នៃ និងទីផ្សារកសិកម្មដល់ពលរដ្ឋ។

បើគិតត្រឹមថ្ងៃទី១១ ខែឧសភានេះ ពលរដ្ឋខ្មែរ ១០០នាក់ជាងហើយ ត្រូវអាជ្ញាធរថៃចាប់ខ្លួន និងបញ្ជូនមកកាន់កម្ពុជាជាបន្តបន្ទាប់ បើទោះបីជាមានការបើកច្រកអន្តរជាតិរួចរាល់ហើយក៏ដោយ ពលរដ្ឋនៅតែបន្តឆ្លងដែនដោយខុសច្បាប់ដដែល៕

## ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង ៖ កងកម្លាំងនគរបាលជាតិ ត្រូវបន្តបេសកកម្មរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលបណ្តាលមកពីឥទ្ធិពលអសន្តិសុខក្នុងតំបន់ និងសកលលោក , សកម្មភាពនៃបទឧក្រិដ្ឋឆ្លងដែន បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ

https://cen.com.kh/ Posted ByPen Srey Neat May 14, 2022

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្ញើសារលិខិតជូនពរកងកម្លាំងនគរបាលជាតិ ក្នុងទិវារំឭកខួបអនុស្សាវរីយ៍លើកទី ៧៧ ថ្ងៃកំណើតនគរបាលជាតិ។ អង្គប្រតិបត្តិច្បាប់ ដែលត្រូវបានប្រសិទ្ធនាមថា "នគរបាលជាតិ" បានចាប់បដិសន្ធិនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៤៥ ក្រោមស្នាព្រះហស្តរបស់ ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ " បរមរតនកោដ្ឋ " ក្នុងព្រះរាជបំណងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព សង្គម ដែលគិតមកដល់ពេលនេះមានអាយុកាល ៧៧ឆ្នាំហើយ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃខួបអនុស្សាវរីយ៍ជាប្រវត្តិសាស្ត្រនេះ តាងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ សម្តេចក្រឡាហោម ស ខេង បានសម្តែងនូវមនោសញ្ចេតនារំភើបរីករាយ ចូលរួមអបអរសាទរដោយទឹកចិត្តស្មោះសរ និងសូមជូនពរដល់កងកម្លាំងនគរបាលជាតិគ្រប់លំដាប់ថ្នាក់ រួមទាំងនិវត្តន៍ជន និងក្រុមគ្រួសារ សូមមានសុខភាពល្អ កម្លាំងពលំមាំមួន អាយុយឺនយូរ និងសូមរស់នៅប្រកបដោយសុភមង្គល។ ទន្ទឹមគ្នានេះក៏ សូមផ្តាំផ្ញើនូវការសាកសួរសុខទុក្ខដល់បងប្អូននគរបាលជាតិ ដែលកំពុងសម្រាកព្យាបាលជំងឺ-របួស នៅតាម មន្ទីរពេទ្យ ឬគេហដ្ឋាន សូមឆាប់ជាសះស្បើយ មានសុខភាពល្អជាប្រក្រតីឡើងវិញ ដើម្បីវិលត្រឡប់មករួម រស់ជាមួយក្រុមគ្រួសារ និងបានមកបំពេញការងារនៅតាមអង្គភាពនាពេលឆាប់ៗខាងមុខនេះ។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ប្រទេសជាតិមានសន្តិភាព និងមានការអភិវឌ្ឍលើគ្រប់វិស័យ ប្រជាពលរដ្ឋរស់នៅ ប្រកបដោយជីវភាពសមរម្យ និងសុខដុមរមនា។ កម្ពុជាការពារបានយ៉ាងរឹងមាំនូវឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី បញ្ចៀសបាននូវអំពើភេរវកម្ម ទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលានូវឧក្រិដ្ឋកម្មឆ្លងដែន គ្រប់ប្រភេទ រក្សាបាននូវសុខដុមនីយកម្មក្នុងសង្គម ពង្រឹងបាននូវសន្តិសុខផ្ទៃក្នុង គ្មានតំបន់អបគមន៍ និង គ្មានជម្លោះប្រដាប់អាវុធ ព្រមទាំងធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដែល សមិទ្ធផលដ៏ថ្លៃថ្លាទាំងអស់នេះ មិនអាចកាត់ផ្តាច់ចេញពីការរួមចំណែកប្រកបដោយពលិកម្មយ៉ាងធំធេងរបស់កងកម្លាំងនគរបាលជាតិបានឡើយ។

រយៈពេលកន្លងមក កងកម្លាំងនគរបាលជាតិបានកសាងនូវស្នាដៃ និងសមិទ្ធផលធំៗ ដែលមាន គុណប្រយោជន៍ជាច្រើន ជាពិសេសក្នុងដំណាក់កាលប្រទេសជាតិស្ថិតក្នុងបរិបទប្រកបដោយហានិភ័យនៃការ ឆ្លងរាតត្បាតជំងឺកូវីដ-១៩។ នគរបាលជាតិបានទទួលបន្ទុករែកពន់ការងារដ៏ធ្ងន់ធ្ងរក្នុងពេលតែមួយ តាមរយៈ ការបំពេញតួនាទីស្នូលក្នុងការធានាស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមផង និងបានបំពេញកាតព្វកិច្ចចូលរួមចំណែកយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរាតត្បាតជំងឺកូវីដ-១៩ ផង។

ស្នាដៃដែលលេចធ្លោ និងត្រូវបានកត់សម្គាល់នាឆ្នាំ២០២២នេះ គឺការរៀបចំសន្និសីទអាស៊ាន ណាប៉ូលលើកទី៤០ ដែលនគរបាលជាតិកម្ពុជាធ្វើជាម្ចាស់ផ្ទះ។ ភាពជោគជ័យក្នុងការរៀបចំព្រឹត្តិការណ៍ជា ប្រវត្តិសាស្ត្រនេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកស្ទួយកិត្តិយស និងកិត្យានុភាពជាតិ ទាំងក្នុង តំបន់ និងលើឆាកអន្តរជាតិ។ ក្នុងនាមក្រសួងមហាផ្ទៃ ខ្ញុំសូមសម្តែងនូវការពេញចិត្ត អបអរសាទរ និងកោតសរសើរចំពោះសមិទ្ធផលដ៏ឧត្តុង្គឧត្តមនេះ។ រហូតមកដល់បច្ចុប្បន្ននេះ បើទោះបីជាព្រះរាជាណាចក្រកម្ពុជានៅតែរក្សាបានបរិយាកាសសន្តិសុខ ល្អប្រសើរយ៉ាងណាក្តី ក៏ប៉ុន្តែកងកម្លាំងនគរបាលជាតិនៅតែជាកម្លាំងស្នូលឈានមុខ ក្នុងការបំពេញតួនាទីធានារ៉ាប់រងចំពោះភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងការពារខឿនសន្តិសុខជាតិ ដែលជាមូលដ្ឋានគ្រឹះនៃ ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ។

ក្រោមការយកចិត្តទុកដាក់ដឹកនាំ គាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ កងកម្លាំងនគរបាលជាតិបានអភិវឌ្ឍខ្លួនយ៉ាងសមរម្យ ស្របតាមស្ថានភាពជាក់ស្តែងទាំងគុណភាព សមត្ថភាព ជំនាញឯកទេស ទាំងការបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារសម្រាប់កិច្ចប្រតិបត្តិការ និងការកសាងហេដ្ឋ រចនាសម្ព័ន្ធ ក៏ដូចជាការលើកកម្ពស់ជីវភាព និងសុខុមាលភាពផងដែរ។ ការអភិវឌ្ឍប្រកបដោយភាពវិជ្ជមាន គួរឲ្យកត់សម្គាល់នោះគឺការកែប្រែនូវឥរិយាបថបំពេញការងារបម្រើសេវាជូនប្រជាពលរដ្ឋ ប្រកបដោយសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ ដោយទទួលបាននូវការគាំទ្រ កោតសរសើរ ព្រមទាំងបង្កើតបាននូវការជឿជាក់ ពីសំណាក់ប្រជាពលរដ្ឋ ចំពោះនយោបាយដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល។

សម្តេចបានបន្តថា "ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះ កងកម្លាំងនគរបាលជាតិគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងចាត់តាំងអនុវត្តយ៉ាងផុលផុស តាមគោលការណ៍ បទបញ្ជា វិធានការនានារបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ ប្រកបដោយភាពអត់ធ្មត់ទន់ភ្លន់ និងម៉ឺងម៉ាត់ រួមចំណែកធ្វើឲ្យសង្គមកម្ពុជាមានការរីកចម្រើន ប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ"។ ក្នុងឆ្នាំ២០២២នេះ កងកម្លាំងនគរបាលជាតិ ត្រូវបន្តបេសកកម្មរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដែលបណ្តាលមកពីឥទ្ធិពលអសន្តិសុខក្នុងតំបន់ និងសកលលោក ក៏ដូចជាសកម្មភាពនៃបទឧក្រិដ្ឋឆ្លងដែន បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ បទល្មើសគ្រឿងញៀន អំពើជួញដូរមនុស្ស ពិសេសស្ត្រី និង កុមារ បទល្មើសបច្ចេកវិទ្យា។ល។ ដែលនៅតែបន្តកើតឡើងបង្កភាពភ័យខ្លាចដល់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ ព្រឹត្តិការណ៍នយោបាយជាតិ ព្រឹត្តិការណ៍អន្តរជាតិមួយចំនួន នឹងត្រូវរៀបចំនៅកម្ពុជា ហើយកិច្ចការជាអាទិភាពដែលត្រូវបំពេញនៅពេលឆាប់ៗខាងមុខនេះ គឺការធានាសុវត្ថិភាពនៃកិច្ចដំណើរការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ ឲ្យដំណើរទៅប្រកបដោយភាពស្ងប់ស្ងាត់ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង និងគ្មានការបំភិតបំភ័យ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្នុងនាមគណៈបញ្ជាការ សន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត ខ្ញុំសំណូមពរដល់កងកម្លាំងនគរបាលជាតិ ដែលមានតួនាទីជាភ្នាក់ងារ សន្តិសុខបោះឆ្នោត សូមយកចិត្តទុកដាក់ពង្រឹងស្មារតីទទួលខុសត្រូវបំពេញបេសកកម្មរបស់ខ្លួនឲ្យបាន ម៉ឺងម៉ាត់

ហ្មត់ចត់ ដោយគោរពតាមច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា នីតិវិធីសម្រាប់ការបោះឆ្នោត និងអនុវត្ត យ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌ ព្រមទាំងរក្សាបាននូវអព្យាក្រឹតភាពក្នុងនាមជាភ្នាក់ងារសន្តិសុខបោះឆ្នោត។ សម្តេចក្រឡាហោមមានសេចក្តីសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា កងកម្លាំងនគរបាលជាតិ នឹងបន្តលើកកម្ពស់ សក្តានុពល និងមានភាពរីកចម្រើនប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ឈរយ៉ាងរឹងមាំជាសសរស្តម្ភន សន្តិសុខ សណ្តាប់ធ្នាប់សង្គមបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ និងប្រទេសជាតិគ្រប់កាលៈទេសៈ។

សូមឧទ្ទិសនូវទឹកចិត្តកតញ្ញូកតវេទីជូនចំពោះវិញ្ញាណក្ខន្ធបុព្វបុរសនៃកងកម្លាំង នគរបាលជាតិគ្រប់ជំនាន់ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង ក្នុងការបំពេញកាតព្វកិច្ចបម្រើសេចក្តីសុខ ក្សេមក្សាន្តជូនប្រជាពលរដ្ឋ និងសង្គមជាតិ ព្រមទាំងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រជាពលរដ្ឋ ទូទាំងប្រទេសដែលបានលះបង់កូនចៅ ស្វាមី ភរិយា សាច់ញាតិ ឲ្យចូលបម្រើក្នុងជួរកងកម្លាំងនគរបាលជាតិ និងបានជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងដល់បេសកកម្មរបស់នគរបាលជាតិតាំងពីដើមរៀងរហូតមក។ ទន្ទឹមនេះ ក៏សូមសំណូមពរយ៉ាងទទូចឲ្យបងប្អូនកងកម្លាំងនគរបាលជាតិ បន្តការប្រុងប្រយ័ត្នខ្ពស់ចំពោះសុខភាពផ្ទាល់ ខ្លួន និងក្រុមគ្រួសារ ដោយត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមវិធានសុខាភិបាល និងវិធានការ " ការពារ ៣កុំ " ឲ្យបានគ្រប់ៗគ្នា៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០២២

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០២២

នៅព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២នេះ លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំប្រចាំខែឧសភា ក្រោមកិច្ចដឹកនាំរបស់ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពីមន្ទីរ អង្គភាពពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធផងដែរ។ អង្គប្រជុំក៏បានពិនិត្យទៅលើកំណត់ហេតុ និងត្រួតពិនិត្យលើផែនការដែលអង្គប្រជុំបានដាក់ចេញកាលពីលើកកិច្ចប្រជុំកន្លងទៅ និងបានពិភាក្សាលើបញ្ហាប្រឈមមួយចំនួន ដែលក្រុមការងារបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាព ដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានក្រុង ស្រុក ភូមិ ឃុំ ដូចជាធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធនានា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព វេទិកាសាធារណៈ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ កិច្ចការពារជនរងគ្រោះ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ។

កិច្ចប្រជុំ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា សម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរំលោភបំពានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ក្នុងកិច្ចប្រជុំនោះដែរ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប បានមានប្រសាសន៍លើកឡើងថា សូមឲ្យក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ទាំងអស់ ត្រូវបង្កើនការផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស និងវិធីសាស្ត្រធ្វើចំណាកស្រុកដោយសុវត្ថិភាព ដើម្បីធ្វើការអប់រំដល់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ឲ្យបានញឹកញាប់ និងបញ្ជ្រាបឲ្យពួកគាត់មានការយល់ដឹងអំពីនិតិវិធី និងបញ្ហាផ្សេងៗ ក្នុងការចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស គឺបងប្អូនត្រូវមានឯកសារគ្រប់គ្រាន់ និងទៅតាមរយៈក្រុមហ៊ុន ដែលមានអាជ្ញាប័ណ្ណទទួលស្គាល់ពីរាជរដ្ឋាភិបាល ។

នៅក្នុងកិច្ចប្រជុំពិភាក្សា និងការត្រួតពិនិត្យលើបញ្ហាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ គឺអង្គប្រជុំបានដាក់នូវរបៀបវរៈសម្រាប់អនុវត្ត និងដោះស្រាយ មួយចំនួនដូចជា៖

១. មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើការផ្សព្វផ្សាយអំពីកម្រងប្រកាសពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរពលកម្មកុមារ ជូនមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងអង្គការដៃគូ ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ។

២.មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរសង្គមកិច្ច ស្នងការនគរបាលខេត្ត កងរាជអាវុធ ហត្ថខេត្ត ធ្វើការចុះអធិការកិច្ចជាលក្ខណៈបែបទស្សនកិច្ចរួមគ្នា ដើម្បីធ្វើការសំយោគ និងកំណត់អំពីនីតិវិធី លើការទប់ស្កាត់ និងដកហូតកុមារ ឱ្យស្របតាមកម្រងប្រកាសរបស់ក្រសួងការងារ និងគោលនយោបាយកាត់បន្ថយកុមារស្នាក់នៅក្នុងមណ្ឌល។

៣. រដ្ឋបាលស្រុកពួក ពិនិត្យ និងជួយសម្រួលដល់ពលករ ដែលបាត់ដំណឹងលើសពី ៣ឆ្នាំ ក្នុងការដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ ឬអធិការ និងការបញ្ជូនមកការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្ត ។

៤. រដ្ឋបាលស្រុកសូទ្រនិគម ពិនិត្យលើបញ្ហារបស់កម្មករ ដែលមិនទទួលបានប្រាក់ឈ្នួល ថាតើពួក គាត់មិនទទួលបានពីមេការ អ្នកម៉ៅការ ឬពីក្រុមហ៊ុនសាងសង់ប្រលានយន្តហោះអន្តរជាតិថ្មីផ្ទាល់ និងត្រូវធ្វើកិច្ចសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើការដោះស្រាយបញ្ហារបស់កម្មករ ដោយត្រូវជំរុញឱ្យកម្មករដាក់ពាក្យបណ្តឹងនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។

៥. រដ្ឋបាលស្រុកស្វាយលើ ត្រូវសហការជាមួយមន្ទីរកិច្ចការនារី និងអធិការស្រុក ដោយប្រើយន្តការ តាមនីតិវិធីរបស់សមត្ថកិច្ច ក្នុងការអញ្ជើញភាគីខាងពាក់ព័ន្ធ ដើម្បីចូលមកធ្វើការដោះស្រាយនៅក្រៅប្រព័ន្ធ តុលាការទៅតាមបែបបទនីតិវិធី (ករណីព្រមព្រៀងបែបអនីតិសង្វា)។

៦. រដ្ឋបាលស្រុកអង្គរធំ ពិនិត្យ និងកែសម្រួលសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សឡើងវិញ និងធ្វើការរៀបចំផែនការសកម្មភាព និងថវិកា ដោយប្រើប្រាស់ថវិកា នៅក្នុងកញ្ចប់ថវិកាសេវា សង្គមសម្រាប់ដំណើរការកិច្ចប្រជុំ និងសកម្មភាពផ្សព្វផ្សាយក្នុងការទប់ស្កាត់ពើជួញដូរមនុស្ស ៕

## អង្គការសង់ត្រាល់សម្ពោធមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ដើម្បីប្រឹក្សាយោបល់ពីសុវត្ថិភាពចំណាកស្រុក

https://www.postkhmer.com/ ម៉ុំ គន្ធា | Publication date 15 May 2022 | 18:57 ICT

**បន្ទាយមានជ័យៈ** មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) បានសម្ពោធនូវមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ហៅកាត់ថា MRC ក្នុងក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី១៣ ខែឧសភា ដើម្បីបម្រើសេវាប្រឹក្សាយោបល់ពីសុវត្ថិភាពចំណាកស្រុកដល់ប្រជាពលរដ្ឋ ជាពលករដែលចង់ស្វែងយល់ពីព័ត៌មានទាក់ទងនឹងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សបានលើកឡើងថា អង្គការសង់ត្រាល់បានបើកមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (MRC) នេះឡើងក្នុងគោលបំណងសំខាន់ៗ ចំនួន ៥ ក្នុងការជួយដល់ប្រជាពលរដ្ឋ ពលករ ស្វែងយល់ពីការចំណាកស្រុក។

លោកបានថ្លែងថា ៖ «ទី ១ MRCជាទីតាំងដែលផ្តល់ព័ត៌មាន ស្តីពីសុវត្ថិភាពចំណាកស្រុក ជួយផ្តល់សេវាដោយឥតគិតថ្លៃដល់ពលករចំណាកស្រុក និងអតីតពលករចំណាកស្រុកឬជនរងគ្រោះដោយសារការជួញដូរមនុស្ស និង ជួញដូរកម្លាំងពលកម្ម»។ លោក មឿន តុលា បានបន្តថា ទី ២ គឺ MRC ជាទីតាំងធនធាន បណ្ណាល័យ

សម្រាប់ពលករចំណាកស្រុក ពលរដ្ឋ និងសិស្សនិស្សិតសម្រាប់ការស្រាវជ្រាវ ទាក់ទង នឹងវិស័យការងារ ទី ៣ គឺជាកន្លែងផ្តល់វគ្គបណ្តុះបណ្តាល ឬ ជាកន្លែងសម្រាប់រៀបចំបណ្តុះបណ្តាល ដល់ពលករ ពីសិទ្ធិពលករ ឬសុវត្ថិភាពចំណាកស្រុក។ ចំណែកគោលបំណងទី ៤ គឺជាកន្លែង សម្រាប់ពលករចំណាកស្រុក និងក្រុមអ្នកប្រឹក្សាយោបល់សុវត្ថិភាពចំណាកស្រុក ឬហៅថា SMA ជួបជុំគ្នា ពិភាក្សា ពីបទពិសោធ និងមេរៀនសម្រាប់ផ្សព្វផ្សាយដល់ពលរដ្ឋតាមសហគមន៍ហើយទី ៥ គឺជាកន្លែង សម្រាប់ទំនាក់ទំនងគ្នា ចងបណ្តាញរវាងវិស័យផ្សេងទៀត។

លោក មឿន តុលា បានលើកឡើងទៀតថា៖ «ខ្ញុំសង្ឃឹមថាមជ្ឈមណ្ឌលថ្មីនេះនឹងអាចចូលរួមចំណែកជាមួយនឹងអាជ្ញាធរមូលដ្ឋានក៏ដូចជា រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការជួញដូរនានាក្នុងខេត្តបន្ទាយមានជ័យនេះនឹងទទួលបានព័ត៌មានច្បាស់អំពីសុវត្ថិភាពចំណាកស្រុកមុនពេលសម្រេចចិត្តធ្វើចំណាកស្រុក និងអាចឈានដល់ការកាត់បន្ថយនូវហានិភ័យនានាផងដែរ»។

អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ លោក ហុង ប្រកប បានលើកឡើងថា ការផ្តល់ការប្រឹក្សា និងការផ្តល់ព័ត៌មានជាក់លាក់មួយពាក់ព័ន្ធនឹងសុវត្ថិភាពការងារចំណាកស្រុកទៅដល់ពលករពិតជាមានសារៈសំខាន់ណាស់ហើយរាជរដ្ឋាភិបាលបានខិតខំក្នុងការបង្កើតនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីការពារសិទ្ធិពលករ។ លោកបានមានប្រសាសន៍ថា៖ «ចាប់ពីពេលនេះទៅ យើងមានមជ្ឈមណ្ឌលមួយដើម្បីសម្រាប់ពលករយើងទទួលព័ត៌មានជាក់លាក់មួយសម្រាប់ពលករយើង ឬប្រជាពលរដ្ឋយើងចង់ទៅធ្វើការនៅក្រៅប្រទេស។ ពលករយើងនឹងទទួលបានព័ត៌មានគ្រប់គ្រាន់សម្រាប់ការទៅធ្វើការនៅក្រៅប្រទេស»។

ជាមួយគ្នានោះដែរ លោកស្រី រស់ សុផានី អភិបាលរងខេត្តបន្ទាយមានជ័យបានអំពាវនាវទៅដល់ប្រជាពលរដ្ឋក៏ដូចជា ពលករខ្មែរ កុំជឿលើមេខ្យល់ក្នុងការនាំទៅធ្វើការនៅក្រៅប្រទេសដោយខុសច្បាប់ ដោយសារកិច្ចការងារអ្វីក៏ដោយត្រូវតែធ្វើដោយស្របច្បាប់ត្រឹមត្រូវ។ លោកស្រីមានប្រសាសន៍ថា៖ «គ្រាន់តែមេខ្យល់ក្នុងមួយរដូវនៃបរិបទកូវីដនេះយើងបានចាប់គាត់បានរហូតដល់ជាង១០០នាក់។ ខ្ញុំបានសម្ភាសផ្ទាល់ជាមួយបងប្អូនពលរដ្ឋយើងមួយចំនួននៅក្នុងមណ្ឌលចត្តាឡីស័ក គឺពួកគាត់ចាញ់បោកគេដោយបានចំណាយលុយឱ្យមេខ្យល់តែត្រូវបានគេយកទៅទម្លាក់ចោលមិនមានការងារឱ្យ។ នេះដោយសារតែពួកគាត់មិនទទួលបានព័ត៌មានគ្រប់គ្រាន់ក្នុងការធ្វើចំណាកស្រុក»។ លោកស្រី ក៏បានស្នើទៅដល់ពលករដែលមានបទពិសោច្រើនមានចំណេះដឹងច្រើនទាក់ទងនឹងការធ្វើចំណាកស្រុកនេះ ជួយធ្វើការផ្សព្វផ្សាយដល់យុវជនប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងក្រុមគ្រួសារដើម្បីឱ្យពួកគាត់បានយល់ច្បាស់អំពីបញ្ហាទាំងអស់នេះ ដើម្បីចៀសវាងការចាញ់បោកមេខ្យល់ក្នុងការធ្វើចំណាកស្រុកនេះ៕

# ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

## កម្ពុជាត្រូវបានដាក់បញ្ចូលក្នុងក្រុមប្រទេសជើងឯកដែលអនុវត្តកតិកាសញ្ញាពិភពលោកស្តីពីការធ្វើចំណាកស្រុកបានល្អ

https://eacnews.asia/home/ ចុះផ្សាយថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ដោយ Hun Sirivadh

ភ្នំពេញ៖ ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសចំនួន ៣៦ប្រទេសនៅក្នុងពិភពលោក ដែលត្រូវបានអង្គការសហប្រជាជាតិចាត់ជាប្រទេស ដែលអនុវត្តកតិកាសញ្ញា ស្តីពីទេសន្តរប្រវេសន៍ (ការធ្វើចំណាកស្រុក) ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់បានល្អបំផុត។ អង្គការពិភពលោកមួយនេះក៏បានអញ្ជើញប្រតិភូកម្ពុជាទៅចែករំលែកពីបទពិសោធន៍ និងទទួលយោបល់បន្ថែមសម្រាប់ដាក់បញ្ចូលក្នុងកតិកាសញ្ញាអន្តរជាតិនេះផងដែរ។

គណៈប្រតិភូដែលដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកស្រី ជូ ប៊ុនអេង និងរដ្ឋលេខាធិការក្រសួងសង្គមកិច្ច លោក ញឹក វណ្ណារ៉ា រួមទាំងតំណាងក្រសួង ស្ថាប័ន ៤ទៀត នឹងធ្វើដំណើរចេញពីកម្ពុជាឆ្ពោះទៅទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិកនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២នេះ។

ថ្លែងប្រាប់សារព័ត៌មាន EAC News នៅរសៀលថ្ងៃទី១៤ ខែឧសភានេះ លោកស្រី ជូ ប៊ុនអេង បានឱ្យដឹងថា នេះជាកិត្តិយសរបស់ប្រទេសកម្ពុជាដែលបានចែករំលែកនូវការងារ និងកិច្ចខិតខំរបស់ក្នុងការអនុវត្តន៍កតិកាសញ្ញាស្តីពីទេសន្តរប្រវេសន៍បន្ទាប់ពីខ្លួនបានចូលរួមក្នុងឆ្នាំ២០១៨។ លោកស្រីថា៖ «គេបានជ្រើសរើសកម្ពុជាហ្នឹងដូចជាមាន២ ឬ៣ប្រទេសទេឱ្យធ្វើជា Panelist ដើម្បីចែករំលែកបទពិសោធន៍ថាគេធ្វើយ៉ាងមិចទើបបានជោគជ័យហើយអ្វីខ្លះជាសមិទ្ធផល តទៅទៀតគួរធ្វើអីទៀត ហើយនឹងឱ្យយើងវាយតម្លៃលើ Declaration ថ្មីហ្នឹងថាយើងគួរកែលំអរកតិកាសញ្ញាហ្នឹងយ៉ាងមិចពីព្រោះឥឡូវនេះវាក្រោយ [វិបត្តិ] កូវីដ ឬក៏ក្នុងដំណាក់កាលដែលយើងរស់នៅជាមួយកូវីដ»។

សញ្ញាស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់បានល្អបំផុត ត្រូវបានប្រកាសដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃ១៩ ខែធ្នូ ឆ្នាំ២០១៨។ Global Compact នេះត្រូវបានរចនាឡើងដើម្បី គាំទ្រកិច្ចសហប្រតិបត្តិការអន្តរជាតិលើអភិបាលកិច្ចនៃការធ្វើចំណាកស្រុកអន្តរជាតិ ផ្តល់ជម្រើសទូលំទូលាយសម្រាប់រដ្ឋដែលពួកគេអាចជ្រើសរើសជម្រើសគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗមួយចំនួនជុំវិញការធ្វើចំណាកស្រុកអន្តរជាតិនិងផ្តល់ឱ្យរដ្ឋនូវលំហរ និងភាពបត់បែនដើម្បីបន្តការអនុវត្តដោយផ្អែកលើការពិត និងសមត្ថភាពនៃការធ្វើចំណាកស្រុករបស់ពួកគេ។

បើតាមលោកស្រី ជូ ប៊ុនអេង បច្ចុប្បន្នកម្ពុជាបានធ្វើការឆ្លើយតបនឹងកតិកាសញ្ញានេះច្រើនដោយបានបង្ក្រាបការជួញដូរពលករ បានរៀបចំគោលនយោបាយ គោលការណ៍ជាច្រើន រួមទាំងដាក់បញ្ចូលក្នុងប្រព័ន្ធអប់រំការគិតគូរពីសុខភាពទេសន្តរប្រវេសន៍ ការរៀបចំ SOP ដោយក្រសួងសង្គមកិច្ចដើម្បីគិតគូរដល់ពលករចំណាកស្រុកនៅក្រៅប្រទេស និងកំពុងរៀបចំផែនការ ១០ឆ្នាំសម្រាប់អនុវត្តន៍ការងារទាក់ទងនឹងទេសន្តប្រវេសន៍នេះផងដែរ។ កម្ពុជាត្រូវបានក្រសួងការបរទេសអាមេរិកដាក់ចូលក្នុងចំណាត់ថ្នាក់មិនល្អ ៣ឆ្នាំជាប់គ្នាតាំងពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២១ ក្នុងបញ្ជីតាមដានការប្រឆាំងការជួញដូរមនុស្ស។ ក្នុងរបាយការណ៍ដែលចេញផ្សាយកាលពីខែកក្កដា ឆ្នាំ២០២១ ក្រសួងការបរទេសបានចាត់ថ្នាក់កម្ពុជាក្នុងកម្រិតពីរតាមដាន «Tier 2 Watchlist» ដោយថារដ្ឋាភិបាលកម្ពុជាគ្មានគណនេយ្យភាព គ្មានឆន្ទៈនយោបាយក្នុងការស្រាវជ្រាវតាមដាន រើកមុខ និងផ្តន្ទាទោសឧក្រិដ្ឋជនជួញដូរមនុស្សនោះទេ រួមនឹងកង្វះប្រព័ន្ធបង្ការបទល្មើសជាដើម។

លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ថាការវាយតម្លៃរបស់អ្នកឱ្យពិន្ទុ តែអ្វីដែលរដ្ឋាភិបាលធ្វើគឺគិតពីលទ្ធផលជាជាងគិតពីពិន្ទុពីអ្នកវាយតម្លៃ។ លោកស្រីបញ្ជាក់ថា រដ្ឋាភិបាលបានធ្វើការរួចហើយនូវការការពារនូវសន្តិសុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋភាគច្រើនដាច់ខាត និងមានការងារជាច្រើនបន្តទៀតដើម្បីលុបបំបាត់បញ្ហាទាំងនេះ។ លោកស្រីថា៖ «អ្នកដែលធ្វើការជាមួយយើងទើបគាត់ដឹងថាយើងកំពុងធ្វើអី? ចំណែកអ្នករិះគន់គឺប្រហែលជាគាត់មិនដែលចូលប្រឡូកទេគឺគាត់អង្គុយចាំមើលតែកំហុសអញ្ចឹងពាក់ថាការខុសឆ្គងបើអង្គុយមើលឃើញ។ ប៉ុន្តែបើចូលឱ្យជ្រៅគេនឹងដឹងថាយើងកំពុងធ្វើអីខ្លះ? យើងក៏ចង់អំពាវនាវដែរថាបើពួកគាត់ចង់ដឹងច្បាស់ចូលឱ្យជិតកុំថាពីឆ្ងាយ ពីព្រោះនៅពីចម្ងាយមើលមិនច្បាស់ទេ»៕

# លោកនេត សាវឿន ៖ បទល្មើសឧក្រិដ្ឋឆ្លងដែន ព្រហ្មទណ្ឌ គ្រឿងញៀន ជួញដូរមនុស្ស ពិសេសស្ត្រីកុមារនៅតែកើតមាន

https://kohsantepheapdaily.com.kh/ ភ្នំពេញ១៦ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ០៩:២៦

រាជធានីភ្នំពេញ ៖ នាយកឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានលើកឡើងថា ករណីបទល្មើសឧក្រិដ្ឋឆ្លងដែនប ទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ មានបទល្មើសគ្រឿងញៀន ជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ និងបទល្មើសផ្សេងទៀតនៅតែកើតមាន ដូច្នេះកងកម្លាំងនគរបាលជាតិបន្តលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នខិតខំប្រឹងប្រែងអនុវត្តឲ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ នូវរាល់ផែនការវិធានការ ។

យោងតាមសាលិខិតជូនពររបស់ឯកឧត្តមនាយកឧត្តមសេនីយ៍នេត សាវឿន ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៧៧ ថ្ងៃកំណើតនគរបាលជាតិ (ថ្ងៃ១៦ ឧសភា ឆ្នាំ២០២២) បានឲ្យដឹងថា ក្នុងអំឡុងឆ្នាំ២០២២ សភាពការណ៍ សន្តិសុខសកលលោក នៅតែបន្តប្រែប្រួលប្រកបដោយភាពស្មុគស្មាញ ដែលហេតុការណ៍មួយចំនួនអាចជះឥទ្ធិពលដោយផ្ទាល់ និងប្រយោលដល់ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងអំឡុងពេលដូចគ្នានេះផងដែរ ព្រឹត្តិការណ៍នយោបាយជាតិនិងព្រឹត្តិការណ៍អន្តរជាតិមួយចំនួននឹងត្រូវរៀបចំប្រព្រឹត្តទៅនៅព្រះរាជាណាចក្រកម្ពុជាទៀតផង ។ ឯកឧត្តមលើកឡើងថា បញ្ហាប្រឈមមួយចំនួននៅតែបន្តកើតមានឡើងដូចជា បទឧក្រិដ្ឋឆ្លងដែន – បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ បទល្មើសគ្រឿងញៀន អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ បទល្មើសបច្ចេកវិទ្យា ។ល។ ដែលព្រឹត្តិការណ៍ និងហេតុការណ៍ទាំងអស់នេះទាមទារចាំបាច់ឲ្យកងកម្លាំងនគរបាលជាតិបន្តលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នខិតខំប្រឹងប្រែងអនុវត្តឲ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ នូវរាល់ផែនការ វិធានការ ក៏ដូចជា យុទ្ធនាការសំខាន់ៗរបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ ដើម្បីធ្វើឲ្យបរិយាកាសសង្គមមានភាពកក់ក្តៅ មានលក្ខណៈសម្បត្តិល្អប្រសើរ បម្រើឲ្យព្រឹត្តិការណ៍នយោបាយជាតិ និងព្រឹត្តិការណ៍អន្តរជាតិទាំងនេះ ។

ឯកឧត្តមថា ក្នុងនាមថ្នាក់ដឹកនាំកងកម្លាំងនគរបាលជាតិ ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមគ្រាំទ្រលើកទឹកចិត្តដល់បងប្អូនកងកម្លាំងនគរបាលជាតិទាំងអស់ឲ្យបន្តកិច្ចខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ ប្តេជ្ញាការ ពាររាជរដ្ឋាភិបាលស្របច្បាប់ និងបម្រើប្រជាពលរដ្ឋដោយភាពអត់ធ្មត់ ប្រកាន់ខ្ជាប់នូវវិន័យ សីលធម៌ អាកប្បកិរិយាថ្លៃថ្នូរ ម៉ឺងម៉ាត់ និងមានមនសិការវិជ្ជាជីវៈខ្ពស់ ។ ទន្ទឹមនេះ ក៏ត្រូវបន្តការប្រុងប្រយ័ត្នខ្ពស់ចំពោះសុខភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារដោយអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានសុខាភិបាល និង វិធានការ « ៣ ការពារ៣កុំ » ឲ្យបានគ្រប់ៗគ្នា ដើម្បីធ្វើជាគំរូល្អដល់សាធារណជន ។

ក្នុងលិខិតនោះដែរ ឯកឧត្តមអគ្គស្នងការនគបាលជាតិក៏បានលើកឡើងថា ឆ្នាំ២០២១ កន្លងទៅគ្រប់គោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ និងព្រះរាជបេសកកម្មរបស់ព្រះមហាក្សត្រ ព្រះមហាក្សត្រីយានី ព្រះវររាជមាតាជាតិខ្មែរបេសកកម្មរបស់ឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិសំខាន់ៗប្រមាណ១២.១៨០លើក ត្រូវបានធានាសុវត្ថិភាពទាំងស្រុង ។ ស្ថានភាពសន្តិសុខ សណ្តាប់ធ្នាប់សង្គមកាន់តែមានភាពល្អប្រសើរជាលំដាប់ដោយបានកាត់បន្ថយបទល្មើសព្រហ្មទណ្ឌជារួមប្រមាណ ៦% ជាពិសេសលទ្ធផលបង្ក្រាបមានកម្រិតខ្ពស់រហូតដល់ ៩៣% ស្របពេលដែលហេតុការណ៍ គ្រោះថ្នាក់ចរាចរណ៍ថយចុះ ១៧% អ្នកស្លាប់ថយចុះ ៩% និងអ្នករបួសថយចុះ ២៣%។

ចំពោះយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ពិសេសស្ត្រី និងកុមារ ការលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យល្បែងស៊ីសងគ្រប់ប្រភេទក្មេង ទំនើងយុទ្ធនាការការពារធនធានធម្មជាតិ ការបង្ក្រាបបទល្មើសព្រៃឈើ និងជលផលត្រូវបានសហការចាត់តាំងអនុវត្តយ៉ាងសកម្មផុលផុសទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ ។ ឯកឧត្តមថា ការងារដែលកំពុងតែទទួលបាននូវជំនឿទុកចិត្ត និង

ការកោតសរសើរពីសំណាក់ប្រជាពលរដ្ឋនៅតាមសហគមន៍នោះ គឺការបម្រើសេវាចាំបាច់របស់នគរបាលប៉ុស្ដិ៍រដ្ឋបាលដែលបានផ្សាភ្ជាប់ទំនាក់ទំនងផ្ទាល់ជាមួយពលរដ្ឋក្នុងនាមសេវាករ និងក្នុងនាមជាកម្លាំងស្នូលក្នុងការជំរុញចលនាអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ដែលជាគោលនយោបាយជាតិដ៏មានអាទិភាព និងសក្ដានុពលបំផុត ។ ស្នាដៃលេចធ្លោនាឆ្នាំ២០២២ នេះគឺ ភាពជោគជ័យក្នុងការបំពេញតួនាទីក្នុងនាមជាម្ចាស់ផ្ទះសន្និសីទអាស៊ានណាប៉ូល លើកទី៤០ ដែលការសម្រេចបាននូវលទ្ធផលដ៏ត្រចះត្រចង់នៃបេសកកម្មជា ប្រវត្តិសាស្រ្តនេះ បានឆ្លុះបញ្ចាំងអំពីសមត្ថភាពពោរពេញ ដោយបទពិសោធន៍របស់នគរបាលជាតិកម្ពុជា និងជាចំណែកយ៉ាងសំខាន់ក្នុងការលើកស្ទួយកិត្តិយសកិត្យានុភាពជាតិក្នុងតំបន់ និងលើឆាកអន្តរជាតិ ។

ក្រៅពីកិច្ចប្រតិបត្តិការលើមុខជំនាញប្រចាំថ្ងៃ កងកម្លាំងនគរបាលជាតិក៏បានចូល រួមគ្រប់សកម្មភាពជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយសារគ្រោះធម្មជាតិ និងមហន្តរាយនានា ពិសេសក្នុងអំឡុងពេលអនុវត្តយុទ្ធនាការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ដោយបានចូលរួមសហការយ៉ាងសកម្មជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈកម្មការប្រឆាំងជំងឺកូវីដ-១៩ គ្រប់ថ្នាក់ ដើម្បីអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរដែនដីសំដៅការពារសុខភាពសាធារណៈ ក៏ដូចជា អាយុជីវិតរបស់ប្រជាពលរដ្ឋ និងសង្គមជាតិ ៕

## លោក អ៊ិត សំហេង អំពាវនាវកុំឱ្យពលរដ្ឋចាញ់បោកករណីថា មានការនាំពលករទៅធ្វើការតាមរដូវកាលនៅក្រៅប្រទេស

https://www.postkhmer.com/ មុំ គន្ធា | Publication date 16 May 2022 | 10:28 ICT

**ភ្នំពេញៈ** រដ្ឋមន្រ្តីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានអំពាវនាវដល់ពលរដ្ឋកម្ពុជាកុំឱ្យជឿលើការញុះញង់ ឬការផ្សព្វផ្សាយរបស់ជនខិលខូចមួយចំនួនទាក់ទងនឹងការបញ្ជូនទៅធ្វើការងារនៅក្រៅប្រទេស ដោយលោកបានអះអាងថា បច្ចុប្បន្ននេះកម្ពុជាមិនទាន់មានការបញ្ជូនពលករតាមរដូវកាលទៅធ្វើការនៅបរទេសឡើយ។ លោក អ៊ិត សំហេង បានលើកឡើងដូចនេះ បន្ទាប់ពីមានជនខិលខូចមួយចំនួនបានធានាអះអាងថា ពួកគេអាចបញ្ជូនពលករទៅធ្វើការតាមរដូវកាលនៅក្រៅប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈកាលពីថ្ងៃទី ១២ ខែឧសភាថា ក្រសួងបានទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋក៏ដូចជា អាជ្ញាធរមូលដ្ឋានថា មានជនខិលខូចមួយចំនួនទាំងជនជាតិខ្មែរ និងបរទេសជ្រកក្រោមស្លាកសាលាភាសា អង្គការ និងសមាគមផ្សេងៗ បានចុះផ្សព្វផ្សាយជ្រើសរើស និងប្រមូលថវិកាពីប្រជាពលរដ្ឋដោយធានាអះអាងថា អាចបញ្ជូនទៅធ្វើការតាមរដូវកាលនៅក្រៅប្រទេសដែលមានប្រាក់ចំណូលខ្ពស់។

លោក អ៊ិត សំហេង បានឱ្យដឹងតាមរយៈសេចក្ដីប្រកាសព័ត៌មាននេះថា កន្លងមកក្រសួងក៏ធ្លាប់ទទួលបានការស្នើសុំឱ្យមានកិច្ចសហការលើការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសតាមរដូវកាលផងដែរ ប៉ុន្តែក្រសួងសង្កេតឃើញថា ការបញ្ជូនពលករទៅធ្វើការតាមរដូវកាលនេះ នៅមានបញ្ហាប្រឈមមួយចំនួន។ លោកបានបញ្ជាក់ថា៖ «បញ្ហាប្រឈមទាំងនោះ មានដូចជា មិនទាន់មានយន្តការសមស្រប និងច្បាស់លាស់ ការងារមានរយៈពេលខ្លី ខណៈការចំណាយខ្ពស់មិនសមស្របនឹងប្រាក់ចំណូលដែលទទួលបាន ហើយលក្ខខណ្ឌការងារនៅមិនទាន់ត្រូវបានធានា និងការពារដោយបទដ្ឋានគតិយុត្តនៃប្រទេសទទួលនៅឡើយ»។ ឆ្លៀតក្នុងឱកាសនេះក្រសួងក៏បានបញ្ជាក់សាជាថ្មីដល់ប្រជាពលរដ្ឋ សាធារណជន ក៏ដូចជាស្ថាប័នពាក់ព័ន្ធផងដែរថា បច្ចុប្បន្នកម្ពុជាមិនទាន់មានការបញ្ជូនពលករតាមរដូវកាលទៅធ្វើការនៅក្រៅប្រទេសនៅឡើយទេ ដោយទាមទារឱ្យមានការសិក្សាស្រាវជ្រាវលើស្ថានភាពសេដ្ឋកិច្ចប្រទេសទទួល លក្ខខណ្ឌការងារ កម្រៃសេវាដែលពលករត្រូវចំណាយ និងជាពិសេសលើយន្តការនៃការបញ្ជូន ដើម្បីទទួលបានឱកាសការងារសមរម្យនៅក្រៅប្រទេស។

លោក អ៊ិត សំហេង ថា៖ «ករណីមានកិច្ចព្រមព្រៀងលើការបញ្ជូនពលករទៅធ្វើការតាមរដូវកាលនៅក្រៅប្រទេសជាមួយប្រទេសណាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងជូនដំណឹងជាសាធារណៈ។ សូមបងប្អូនប្រជាពលរដ្ឋ សាធារណជន និងស្ថាប័នពាក់ព័ន្ធទាំងអស់បង្កើនការប្រុងប្រយ័ត្នខ្ពស់ចៀសវាងការចាញ់បោកជនឆ្លៀតឱកាស និងចូលរួមផ្សព្វផ្សាយបន្ត»។

គួរបញ្ជាក់ផងដែរថា មកទល់ពេលនេះ ពលករកម្ពុជាដែលធ្វើការងារនៅក្រៅប្រទេស ដោយស្របច្បាប់សរុបមានចំនួនជាង ១,៣ លាននាក់ ក្នុងនោះនៅប្រទេសថៃចំនួនជាង ១,២២ លាននាក់, កូរ៉េជិត ៤៦ ម៉ឺននាក់, ម៉ាឡេស៊ីជាង ២៣ ម៉ឺននាក់,ជប៉ុនជាង ១១ ម៉ឺននាក់, សិង្ហបុរី ៨២១ នាក់, ហុងកុង ២០២ នាក់ និងអារ៉ាប៊ីសាអ៊ូឌីត ៤៣ នាក់។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានលើកឡើងក្នុងថ្ងៃខួបលើកទី ១៣៦ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភាថា តាមការប៉ាន់ប្រមាណពីប្រាក់បញ្ញើដែលពលករកម្ពុជាធ្វើការនៅក្រៅប្រទេសបានផ្ញើជូនក្រុមគ្រួសារក្នុង ១ ឆ្នាំៗ មានជាច្រើនពាន់លានដុល្លារអាមេរិកដែលតាមរយៈទឹកប្រាក់ទាំងនេះបានចូលរួមចំណែកជំរុញដល់កំណើនសេដ្ឋកិច្ច ហើយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករកាន់តែប្រសើរឡើងផងដែរ។ លោក ហ៊ុន សែន បានថ្លែងថា៖ «ត្រូវបន្តពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូ រួមមាន ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន ហុងកុង សិង្ហបុរី និងប្រទេសមួយចំនួនទៀត ដើម្បីផ្តល់ឱកាសការងារជូនពលករ ការពារសិទ្ធិ និងផលប្រយោជន៍ពលករដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណសម្បត្តិឱ្យបងប្អូនទទួលបានរបបគាំពារសង្គមទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ»៕

## កម្ពុជានឹងបង្ហាញបទពិសោធន៍
## មួយចំនួនពាក់ព័ន្ធការគ្រប់គ្រងពលករចំណាកស្រុកប្រាប់ទៅ UN

https://news.btv.com.kh/ 2022/05/16 02:13:07 pm

ភ្នំពេញ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស(គ.ជ.ប.ជ.) លោកជំទាវ ជូ ប៊ុនអេង បានដឹកនាំគណៈប្រតិភូទៅកាន់សហរដ្ឋអាម៉េរិក ដើម្បីចូលរួមនៅក្នុងវេទិកាត្រួតពិនិត្យទេសសន្តប្រវេសន៍អន្តរជាតិលើកទី១ នៅស្នាក់ការអង្គការសហប្រជាជាតិUN នៅទីក្រុងញូវយ៉ក រយៈពេល៤ថ្ងៃគឺចាប់ពីថ្ងៃទី១៧ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២នេះ ។ ថ្លែងប្រាប់ទូរទស្សន៍BTV មុននឹងចេញដំណើរទៅកាន់ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២នេះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា បន្ទាប់ពីប្រទេសកម្ពុជាត្រូវបានចាត់បញ្ចូលក្នុងក្រុមនៃប្រទេសជើងឯក ឬ ជ័យលាភី (Champion Country) ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោកនេះ ដោយកម្ពុជា បានអនុវត្តន៍គ្រប់លក្ខខណ្ឌ ស្តីពីទេសសន្តប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់នោះ កម្ពុជាត្រូវបានអនុញ្ញាតឲ្យបង្ហាញអំពី ភាពវិជ្ជមានរបស់ខ្លួនទាក់ទងនឹងការគ្រប់គ្រងពលករចំណាកស្រុក ក្នុងអំឡុងពេលកម្ពុជាជួបនឹងវិបត្តិកូវីដ១៩ នាពេលកន្លងទៅ។

បើតាមលោកជំទាវ ជូ ប៊ុនអេង បានឲ្យដឹងថា កិច្ចប្រជុំខាងលើនេះ គឺមានប្រទេសជាង៣០បាន ចូលរួម ប៉ុន្តែដោយឡែកប្រទេសកម្ពុជាត្រូវបានចាត់ទុកជាប្រទេសប្រទេសជើងឯក ឬជ័យលាភីដែលនឹងត្រូវធ្វើបទបង្ហាញពីបទពិសោធន៍មួយចំនួនដែលកម្ពុជាទទួលបាននាពេលកន្លងមកប្រាប់ដល់កិច្ចប្រជុំនៅអង្គការ សហប្រជាជាតិមួយនេះ៕ អត្ថបទ៖ បាន ចក់

# ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

## កម្ពុជាចូលរួមក្នុងវេទិកាត្រួតពិនិត្យទេសន្តរប្រវេសន៍អន្តរជាតិ លើកទី១ នៅទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក

http://freshnewsasia.com/ 2022-05-17 05:24pm

**(ញូវយ៉ក-ភ្នំពេញ)៖** ដោយមានការអនុញ្ញាតពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា, លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងឲ្យរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានអញ្ជើញដោយប្រធានមហាសន្និបាត អង្គការសហប្រជាជាតិ (UN) ដើម្បីទៅចូលរួម នៅក្នុងវេទិកាត្រួតពិនិត្យទេសន្តប្រវេសន៍អន្តរជាតិ (International Migration Review Forum) ឬIMRF លើកទី១ នៅទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក (New York) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។ ការអញ្ជើញកម្ពុជាទៅ គឺដើម្បីចែករំលែកបទពិសោធន៍ការអនុវត្តកតិកាសញ្ញា ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (GCM) ក្នុងវេទិកាវាយតម្លៃការងារអភិបាលកិច្ចទេសន្តរប្រវេសន៍អន្តរជាតិ (IMRF) លើកទី១ របស់អង្គការសហប្រជាជាតិ (UN) នេះតែម្តង។

លោកស្រី ជូ ប៊ុនអេង បានឲ្យដឹងថា ចាប់តាំងពីបានអនុម័តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និង ស្របច្បាប់ (Global Compact for Safe, Ordery and Regular Migration) ឬ GCM នាទីក្រុងម៉ារ៉ាកិច ប្រទេសម៉ារ៉ុក នាខែធ្នូ ឆ្នាំ២០១៨ មក អង្គការសហប្រជាជាតិ ដែលមានអង្គការអន្តរជាតិទេសន្តរប្រវេសន៍ជាតំណាង បានរៀបចំឱ្យមានកិច្ចប្រជុំពិភាក្សាជាបន្តបន្ទាប់ ជាថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ស្របតាមស្ថានភាពជាក់ស្តែង នៃការរាតត្បាតដោយជំងឺកូវីដ-១៩ ។ ដោយឡែកព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់បញ្ចូល ក្នុងក្រុមនៃប្រទេសជើងឯក ឬជ័យលាភី (Champion Country) ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោកនេះ ដោយកម្ពុជាបានអនុវត្តគ្រប់លក្ខខណ្ឌ និងបានប្រឹងប្រែងឆ្លើយតបទៅនឹងគោលបំណងជាអាទិភាព ដែលបានកំណត់ដោយកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (GCM) និងបានចូលរួមគ្រប់ដំណើរការនៃការរៀបចំ និងអនុវត្តន៍ ដើម្បីធ្វើឲ្យសម្រេចគោលដៅទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ថា បញ្ហាចំណាកស្រុក នូវតែជាបញ្ហាប្រឈម ដែលត្រូវដោះស្រាយជាសមូហភាព និងប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថា ការធ្វើចំណាកស្រុកគឺជាជម្រើស ជាជាងភាពចាំបាច់។

សូមជម្រាបថា កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (GCM) គឺជាប្រកខណ្ឌទូលំទូលាយទីមួយរបស់ UN ដែលត្រូវបានអនុម័ត តាមរយៈកិច្ចការពិភាក្សា អន្តររដ្ឋាភិបាល ដើម្បីធ្វើឱ្យកិច្ចសហការអន្តរជាតិមានភាពល្អប្រសើរ ក្នុងអភិបាលកិច្ចទេសន្តរប្រវេសន៍ជាសកល និងត្រូវបានឯកភាពគាំទ្រដោយមហាសន្និបាត UN ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងញូយ៉ក ដែលមានសមាជិកចូលរួមចំនួន ១៩២ប្រទេស។ UN បានផ្តល់ជ័យលាភីដល់កម្ពុជា (Champion Country) ក្នុងការអនុវត្ត GCM នៅឆ្នាំ២០២០ ដែលមានន័យថា កម្ពុជាទទួលបានជំនួយពី UN ក្នុងការគ្រប់គ្រងការងារទេសន្តរប្រវេសន៍។ នេះបើតាមលោកស្រី ជូ ប៊ុនអេង៕

## ទោះជាបើកច្រកទ្វារអន្តរជាតិប៉ោយប៉ែតឡើងវិញ តែពលករខ្មែរ នៅតែបន្តចូលមកកម្ពុជា តាមច្រករបៀង ១ថ្ងៃ ជាង ៦០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៧ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៨:៣៦

បន្ទាយមានជ័យ៖ ទោះជាបើកអោយប្រជាពលរដ្ឋចេញ.ចូលតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតក៏ដោយ ក៏គេឃើញមានពលករខ្មែរ នៅតែបន្តចូលមកកម្ពុជាវិញ តាមច្រករបៀង ក្នុង ១ថ្ងៃ ជាង ៦០នាក់ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២។

លោកវរៈសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារទទួលពលករខ្មែរត្រឡប់ពីថៃ ចូលមកកម្ពុជា នៅច្រកអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ បានទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញ តាមច្រកអូរបីជាន់ស្រុកអូរជ្រៅ ដែលក្រុមការងារទទួលមានចំនួន ៦៣នាក់ (ស្រី ២៥នាក់ និងកុមារ ១១នាក់) ក្នុងនោះ មានអ្នក ដែលមានឯកសារចាក់វ៉ាក់សាំងការពារកូវីដ.១៩ដូសទី២និងទី៣។ រីឯនៅច្រកបឹងត្រកួន ក្នុងស្រុកថ្មពួក បានទទួលពលករខ្មែរ ៥នាក់ ( ស្រី ៤នាក់ ដោយមានកុមារី ២នាក់)។

គួររំលឹកថា កាលពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ ភាគីថៃ បានបើកច្រកទ្វារឱ្យប្រជាពលរដ្ឋចេញ.ចូលតាមច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលឈមច្រកខ្លងលឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ។ ការចេញចូលឆ្លងដែនតាមច្រកព្រំដែនប៉ោយប៉ែត អាជ្ញាធរសមត្ថកិច្ច តម្រូវឱ្យប្រជាពលរដ្ឋចេញ.ចូល ត្រូវប្រើប្រាស់ប៉ាស្ព័រ រឺលិខិតឆ្លងដែន (Pass Port) និងប័ណ្ណព្រំដែន (Border Pass)។ ភាគីថៃតម្រូវអោយអ្នកប្រើប្រាស់ប៉ាស្ព័រ រឺលិខិតឆ្លងដែន(Pass Port) ត្រូវទិញ (Thailand Pass)និងកញ្ចប់ធានារ៉ាប់រងចំនួន ១ម៉ឺនដុល្លារ ក្នុងតំលៃ ៥០ដុល្លារ កញ្ចប់ធានារ៉ាប់រងចំនួន ២ម៉ឺនដុល្លារ តំលៃ ៧០ដុល្លារ ដែលមានសុពលភាពចំនួន ១ខែ ហើយអ្នកដែលប្រើប្រាស់ប័ណ្ណព្រំដែន (Border Pass) កាលពីមុនភាគីថៃ តម្រូវអោយស្នាក់នៅក្នុងទឹកដីថៃ រយៈពេល ១សប្តាហ៍ តែពេលនេះ ភាគីថៃតម្រូវបានស្នាក់នៅរយៈពេល ៣ថ្ងៃប៉ុណ្ណោះ។

កម្លាំងនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានឱ្យដឹងថា ក្រោយភាគីថៃ បើកឱ្យប្រជាពលរដ្ឋចេញ.ចូលរយៈពេលកន្លះខែ នៅខែឧសភា ឆ្នាំ២០២២នេះ គឺភាគច្រើនប្រជាពលរដ្ឋខ្មែរ ដែលចេញ.ចូលប្រទេសថៃ ដោយប្រើប្រាស់ប័ណ្ណព្រំដែន (Border Pass) និងប៉ាស្ព័រ រឺលិខិតឆ្លងដែន (Pass Port) មានភាគតិច ៕ ប៊ុន ធឿន

## នៅព្រឹកថ្ងៃអង្គារ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ចំនួន៤លើក

https://gdlf-kh.com/ 17/05/2022 Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែ

បន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៤លើក សរុបចំនួន៤៩នាក់ ស្រី២៤នាក់ ក្មេង១០នាក់ ក្មេងស្រី៤នាក់។

ក្រោយពីទទួលបានកម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូនទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការត្រួតពិនិត្យសុខភាព និងស្កែនប័ណ្ណចាក់វ៉ាក់សាំងនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ។

# ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

## តៃប៉ិ ព្រមានពីការការខារបោកប្រាស់ នៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times May 18, 2022

ក្រសួងការបរទេស ត្រូវបានដកស្រង់សម្ដីដោយកាសែត Taipei Times ដែលបាននិយាយថា ទីក្រុងតៃប៉ិបានព្រមានប្រជាជនរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាត្រូវបានគេរាយការណ៍ថា ត្រូវបានគេបោកបញ្ឆោតឱ្យចុះហត្ថលេខាលើកិច្ចសន្យាការងារខុសច្បាប់ ដោយបានយកឯកសាររបស់ពួកគេ ហើយថែមទាំងត្រូវបានលក់ក្នុងចំណោមក្រុមហ៊ុននានា ហើយត្រូវបានគេវាយដំផងដែរ។ ក្រសួងបាននិយាយនៅក្នុងសេចក្ដីថ្លែងការណ៍មួយថា ចាប់តាំងពីខែកុម្ភៈមក ការិយាល័យសេដ្ឋកិច្ច និងវប្បធម៌តៃវ៉ាន់ក្នុងប្រទេសវៀតណាមបានរាយការណ៍ថា បានទទួលពាក្យបណ្ដឹងប្រហែល ៤០ ទាក់ទងនឹងជនជាតិតៃវ៉ាន់ ដែលត្រូវបានចោទប្រកាន់ថា បានបោកបញ្ឆោតឱ្យធ្វើការដោយខុសច្បាប់នៅក្នុងប្រទេសកម្ពុជា។ សេចក្ដីថ្លែងការណ៍នេះបន្តថា ជនជាតិតៃវ៉ាន់ត្រូវបានបោកបញ្ឆោតឱ្យទៅធ្វើការខុសច្បាប់ ឬមិនបានបំពេញតាមការរំពឹងទុករបស់ពួកគេ។ ក្រសួងបាននិយាយថា នៅក្នុងករណីមួយចំនួន អ្នកខ្លះត្រូវបានគេយកលិខិតឆ្លងដែនរបស់ពួកគេ ហើយការដើរហើរត្រូវបានរឹតបន្តឹង ដោយបន្ថែមថា អ្នកខ្លះរាយការណ៍ថាពួកគេត្រូវបានគេវាយដំនៅពេលដែលពួកគេមិនព្រមធ្វើតាម។ ក្នុងករណីផ្សេងទៀត កម្មករត្រូវបាន "លក់" ទៅឱ្យក្រុមហ៊ុនផ្សេងទៀតដែលមិនបានចុះបញ្ជី។

ក្រសួងបាននិយាយថា របាយការណ៍បង្ហាញថា អង្គការដែលមិនបានចុះបញ្ជីនៅតៃវ៉ាន់ កំពុងធ្វើការជាមួយប្រជាជនកម្ពុជា ដើម្បីទាក់ទាញយុវជនតៃវ៉ាន់ឱ្យមកធ្វើការក្នុងប្រទេសកម្ពុជា តាមរយៈការផ្សាយពាណិជ្ជកម្មនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជារឿយៗផ្ដល់ការលើកទឹកចិត្តដូចជា ប្រាក់ឈ្នួលខ្ពស់ មិនមានការថែមម៉ោង គ្មានតម្រូវការជាមុនសម្រាប់សមត្ថភាពភាសាអង់គ្លេស ហើយក្រុមហ៊ុននឹងចេញសំបុត្រយន្តហោះអោយ។ មនុស្សមួយចំនួនបានចុះហត្ថលេខាលើកិច្ចសន្យាមុនពេលចាកចេញពីតៃវ៉ាន់ ហើយពេលមកដល់ប្រទេសកម្ពុជា ត្រូវបានរឹបអូសលិខិតឆ្លងដែន ហើយការធ្វើដំណើររបស់ពួកគេត្រូវបានរឹតបន្តឹង។ ក្រសួងបានបន្តថា លក្ខណៈខុសច្បាប់នៃការងារបានរារាំងពួកគេមិនឱ្យទៅរកអាជ្ញាធរមូលដ្ឋាន។ ក្រសួងបន្ថែមថា ប្រសិនបើពួកគេឈប់ពីការងារ និយោជកនឹងចោទប្រកាន់ពួកគេពីបទរំលោភកិច្ចសន្យា ហើយទាមទារឱ្យពួកគេបង់ប្រាក់សម្រាប់សំបុត្រយន្តហោះ និងកន្លែងស្នាក់នៅ ដោយទាមទារចាប់ពី ១០,០០០ ដុល្លារ ដល់ ១០ ម៉ឺនដុល្លារ។

ក្រសួងផ្ដល់ជំនួយសង្គ្រោះបន្ទាន់ភ្លាមៗនៅពេលដែលខ្លួនទទួលបានរបាយការណ៍មួយ ដោយបន្ថែមថាខ្លួនកំពុងចងក្រងព័ត៌មានសម្រាប់អាជ្ញាធរតៃវ៉ាន់ ដើម្បីពិនិត្យ ព្រោះមានករណីបែបនេះមានការកើនឡើង។ ក្រសួងបាននិយាយថា អ្នកធ្វើដំណើរមួយចំនួនបានត្រឡប់ទៅតៃវ៉ាន់វិញ ដោយមានជំនួយពីការិយាល័យនៅទីក្រុងហូជីមិញ ដោយបន្ថែមថា បទពិសោធន៍នេះពិតជាធ្វើឱ្យអ្នករងគ្រោះឈឺចាប់ណាស់។ ក្រសួងបានបន្តថា អ្នកដែលចង់

ទៅធ្វើការនៅបរទេស គួរពិនិត្យមើលពីប្រវត្តិក្រុមហ៊ុន លក្ខណៈនៃការងារ និងគោលការណ៍កិច្ចសន្យាក្រុមហ៊ុន។ ឧប្បត្តិហេតុនៃការឆបោកការងារនៅក្នុងប្រទេសកម្ពុជាមិនត្រូវបានគេទុកចោលនោះទេ ដោយបានរាយការណ៍ប្រាប់នៅក្នុងប្រទេសហ្វីលីពីន មីយ៉ាន់ម៉ា និងឡាវ។ *Taipei Times*

## នារីខ្មែរដែលត្រូវបានគេជួញដូរទៅប្រទេសចិនដើម្បីរៀបការមានចំនួនកើនឡើង

https://www.khmertimeskh.com/ Khmer Times May 19, 2022

យោងតាមរបាយការណ៍ថ្មីរបស់អង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (GI-TOC) ស្ត្រីខ្មែរកំពុងត្រូវបានជួញដូរទៅប្រទេសចិន ដើម្បីក្លាយជាកូនក្រមុំមានចំនួនកើនឡើង។ GI-TOC បានពន្យល់ថា "ចំនួនស្ត្រី និងកុមារីដែលធ្វើដំណើរពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិនសម្រាប់ការរៀបការដោយបង្ខំ ឬរៀបចំមានចំនួនការកើនឡើងចាប់តាំងពីឆ្នាំ២០១៦ ហើយបានកើនឡើងបន្ថែមទៀតចាប់តាំងពីការចាប់ផ្តើមនៃជំងឺរាតត្បាតកូវីដ-១៩ នៅត្រីមាសទីមួយនៃឆ្នាំ២០២០"។ របាយការណ៍បានរកឃើញថា ទោះបីជាស្ត្រីមួយចំនួនបានទៅដោយមានការយល់ព្រមក៏ដោយ ប៉ុន្តែពួកគេត្រូវបានរំលោភបំពាន ឬស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ពេលទៅដល់ប្រទេសចិន។ GI-TOC បាននិយាយថា "ដូចទៅនឹងបរិបទនៃការជួញដូរទាំងអស់ ការជួញដូរស្ត្រីទៅប្រទេសចិនត្រូវបានជំរុញដោយតម្រូវការ" ។ នៅប្រទេសចិន តម្រូវការកូនក្រមុំត្រូវបានកើនឡើងដែលបណ្តាលមកពីគោលនយោបាយកូនតែមួយដែលមានរយៈពេលពីឆ្នាំ១៩៧៩-២០១៥ ។

GI-TOC បាននិយាយថា "គោលនយោបាយនេះបាននាំឱ្យមានការរំលូតកូនដោយជ្រើសរើសភេទដោយគ្រួសារជាច្រើនចង់បានកូនប្រុសជំនួសឱ្យកូនស្រីដែលនេះបង្កើតអោយអតុល្យភាពយេនឌ័រដ៏ខ្លាំង និងកង្វះស្ត្រីជាបន្តបន្ទាប់ដើម្បីរៀបការនៅក្នុងប្រទេសចិន"។ ដូចនេះ ជំនួញរបៀបនេះបានបន្តតាំងពីទសវត្សរ៍ឆ្នាំ១៩៨០ ប៉ុន្តែមានការកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០០០ ខណៈដែលមនុស្សជំនាន់ទី១ ដែលកើតនៅក្រោមគោលនយោបាយនេះបានធំឡើង។ សព្វថ្ងៃនេះ អ្នកជួញដូរកូនក្រមុំរកលុយបានយ៉ាងច្រើនក្នុងទីផ្សារប្រទេសចិន ដោយអាចរកបានចន្លោះពី ២០,០០០ ទៅ ៤០,០០០ ដុល្លារ។ ទោះបីជាសេវាអាពាហ៍ពិពាហ៍ជាឧស្សាហកម្មសកល និងស្របច្បាប់ក្នុងបរិបទជាច្រើនក៏ដោយ នៅក្នុងប្រទេសកម្ពុជា ឈ្មួញកណ្តាលរៀបចំអាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់ វាបណ្តាលអោយកើនឡើងកាន់តែខ្លាំងក្នុងការជួញដូរមនុស្ស។ GI-TOC បានរកឃើញថា "ស្ត្រី និងកុមារីកម្ពុជាត្រូវបានបង្ខិតបង្ខំ និងរៀបចំអោយរៀបការតាមមធ្យោបាយផ្សេងៗ" ។

"អ្នកខ្លះត្រូវបានគេបោកបញ្ឆោត ហើយសន្យាថា នឹងរកការងារធ្វើនៅប្រទេសចិន។ អ្នកផ្សេងទៀតត្រូវបានគេប្រាប់ថាពួកគេត្រូវការសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីមានសិទ្ធិទទួលបានការងារដែលមានប្រាក់ខែល្អ (ដែលនេះមិនមែនជាករណីនោះទេ); អ្នកខ្លះត្រូវបានបោកបញ្ឆោត និងលក់ដោយសមាជិកគ្រួសារ សាច់ញាតិ និងអ្នកស្គាល់គ្នារបស់ពួកគេ ដើម្បីទទួលបានប្រាក់ ឬការសន្យាអោយមានអាពាហ៍ពិពាហ៍ដ៏ល្អ និងជីវិតកាន់តែប្រសើរនៅក្នុងប្រទេសចិន។ ក្នុងចំណោមអនុសាសន៍ជាច្រើនដែល GI-TOC ត្រូវកាត់បន្ថយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម គឺការធ្វើឱ្យអាជីវកម្មឈ្មួញកណ្តាលរៀបការស្របច្បាប់ក្នុងប្រទេសកម្ពុជា ដើម្បីឱ្យការត្រួតពិនិត្យ និងបទប្បញ្ញត្តិត្រឹមត្រូវអាចត្រូវបានអនុវត្ត។ GI-TOC បាននិយាយថា "ប្រសិនបើសេវាកម្មបែបនេះត្រូវបានធ្វើឱ្យស្របច្បាប់ ការចុះបញ្ជីជាតិនៃទីភ្នាក់ងារកូនក្រមុំ និងឈ្មួញកណ្តាលដែលចូលរួមក្នុងអាពាហ៍ពិពាហ៍ដែលបានរៀបចំអាចត្រូវបានបង្កើតឡើង រួមជាមួយនឹងស្ថាប័នគ្រប់គ្រង ឬការិយាល័យដើម្បីត្រួតពិនិត្យប្រតិបត្តិការ និងធានានូវការការពារគ្រប់គ្រាន់សម្រាប់ស្ត្រី"។ *Organized Crime and Corruption Reporting Project (OCCRP)*

# ពលរដ្ឋមួយចំនួននៅបន្ទាយមានជ័យ
# បង្ខំចិត្តចំណាកស្រុកទៅថៃខុសច្បាប់ដោយសារជីវភាពក្រីក្រ

https://www.rfa.org/ 2022.05.19

ប្រជាពលរដ្ឋមួយចំនួននៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បង្ខំចិត្តចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ដោយសារតែជីវភាពក្រីក្រ ក្រោយពីពួកគេមិនមានការងារធ្វើនៅក្នុងស្រុក។ ពលរដ្ឋទាំងនោះស្នើឱ្យរដ្ឋាភិបាលជួយសម្រួលធ្វើលិខិតឆ្លងដែនឱ្យមានភាពងាយស្រួលជាងសព្វថ្ងៃ និងលុបបំបាត់អំពើពុករលួយ។ ពលរដ្ឋទាំងនោះលើកឡើងថា អ្នកដែលធ្វើចំណាកស្រុកភាគច្រើនជាប្រជាពលរដ្ឋនៅស្រុកស្វាយចេកបានបង្ខំចិត្ត ស្វែងរកការងារធ្វើយកលុយមកផ្គត់ផ្គង់ជីវភាព ប៉ុន្តែមានពេលខ្លះត្រូវបានថៅកែថៃបោកប្រាស់កម្លាំងពលកម្ម ដោយធ្វើការមិនបានប្រាក់ឈ្នួល។

លោកស្រី បុណ្ណ ផល្លា រស់នៅភូមិថ្មគោល ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យប្រាប់វិទ្យុអាស៊ីសេរីនៅនៅថ្ងៃទី១៨ ឧសភា ថា អ្នកស្រីបានសម្រេចចិត្តមកធ្វើការនៅប្រទេសថៃទាំងខុសច្បាប់ ដោយសារតែជីវភាពគ្រួសារខ្វះខាត ហើយជំពាក់លុយធនាគារក៏កាន់តែច្រើន។ អ្នកស្រីបន្តថា កន្លងមកគ្រួសារលោកស្រីបានយកលុយធនាគារដើម្បីធ្វើស្រែចម្ការ ប៉ុន្តែខាតអស់ដើមទុន។ អ្នកស្រីដែលកំពុងរស់នៅប្រទេសថៃបានរៀបរាប់ដោយសម្តីមួយៗថា ពេលនេះអ្នកស្រីមិនទាន់បានចូលធ្វើការនោះទេ ដោយសារតែសម្រាលកូនទើបតែបាន៤ខែ។ ចំណែកប្តីអ្នកស្រី ទៅធ្វើការតែម្នាក់ឯង ដើម្បីយកថវិកាមកផ្គត់ផ្គង់ជីវភាព និងបង់ការប្រាក់មីក្រូហិរញ្ញវត្ថុដែលបានខ្ចីគេជាង៣ម៉ឺនបាត ៣ម៉ឺនបាត ឬស្មើជាង៩០០ដុល្លារ។ លោកស្រីអះអាងថា ការដែលលោកស្រីមកធ្វើការដោយខុសច្បាប់គឺពិបាកគ្រប់យ៉ាង ដែលជាញឹកញយត្រូវបានថៅកែថៃបោកប្រាស់កម្លាំងពលកម្ម៖ «ធ្វើនៅទីនេះពិបាក ជួនកាលធ្វើការហើយគេបោក មិនបើកលុយឱ្យ ធ្វើការចោល។ ពេលខ្លះគេស្រណោះយើង គេបើកឱ្យ ជួនកាល គេធ្វើការគេបោកយើងប្រើចោល»។ អ្នកស្រីបន្តថា ការធ្វើដំណើរមកតាមផ្លូវទាំងខុសច្បាប់មកធ្វើការនៅប្រទេសថៃប្រឈមនឹងគ្រោះថ្នាក់ជាច្រើនព្រោះត្រូវនាំកូនធ្វើដំណើរឆ្លងដែនពេលយប់។ អ្នកស្រីបន្ថែមថា អ្នកដែលធ្វើដំណើរទៅប្រទេសថៃជាមួយគ្នានោះ មានជាង៣០នាក់ ដែលមានទាំងស្ត្រី និងបុរស ភាគច្រើនជាអ្នកដែលមានជីវភាពខ្វះខាត។ អ្នកស្រីបន្តថា ពួកគាត់មិនចង់ទៅធ្វើនៅស្រុកថៃដោយខុសច្បាប់បែបនេះទេ ប៉ុន្តែដោយសារជីវភាពក្រីក្រទើបបង្ខំចិត្តឱ្យពួកគាត់ចាកចេញពីផ្ទះសម្បែង ទៅរកការងារធ្វើនៅស្រុកថៃ។ លោកស្រីស្នើឱ្យរដ្ឋាភិបាលជួយសម្រួលឱ្យប្រជាពលរដ្ឋធ្វើដំណើរឱ្យបានស្រួល និងកុំយកថ្លៃឯកសារឆ្លងដែនផ្សេងៗច្រើនពេក ព្រោះពួកគេមិនមានលទ្ធភាពនោះទេ៖ «គ្នាមកតាមផ្លូវពិបាកណាស់ កាត់ដុបកាត់ព្រៃ កាត់ទឹកកាត់ភក់ ឡើងភ្នំ។ ចង់ឱ្យផ្លូវឡើងមកស្រួលល្អ។ ចង់ដើរផ្លូវស្រួលៗ មកក៏ស្រួល ចុះក៏ស្រួល ឱ្យគ្នារត់លូនចេះពិបាក។ គ្នាមានកូនតូចៗចេះ គ្នាឡើងមកពិបាកណាស់ ចង់តែទៅហើយមិនចង់មកវិញ»។

ស្រដៀងគ្នានេះដែរពលករម្នាក់ទៀត រស់នៅភូមិផ្គាំ ស្រុកស្វាយចេក ដែលកំពុងធ្វើការនៅប្រទេសថៃ អ្នកស្រី គិន សុភា បានលើកឡើងថា ការធ្វើចំណាកស្រុកដោយខុសច្បាប់ ដោយសារនៅកម្ពុជាគ្មានការងារធ្វើ ស្របពេលដែលផលដំណាំដែលពួកគាត់ដាំដុះលក់បានតម្លៃថោក ហើយខាតអស់ដើមទុន៖ «កត្តាទី១ដែលធ្វើឱ្យខ្ញុំធ្វើការចំណាកស្រុកដោយខុសច្បាប់ដោយសារតែមានជីវភាពខ្វះខាត ស្រូវស្រែបានផលតិច ដំឡូងមានការចុះថោក ប្រេងម៉ាស៊ូតឡើងថ្លៃ ជីឡើងថ្លៃ ថ្នាំស្រូវដំណាំអ្វីឡើងថ្លៃទាំងអស់ ធ្វើបានផលតិចទើបខ្ញុំចំណាកស្រុកមកប្រទេសគេ»។

ចំណែកពលរដ្ឋម្នាក់ទៀត គឺ អ្នកស្រី ឈឿន នាង រស់នៅភូមិថ្មី ស្រុកស្វាយចេក លើកឡើងថា បើទោះបីជារដ្ឋាភិបាលបានប្រកាសឱ្យបើកច្រកចូលប្រទេសថៃហើយក៏ដោយ ប៉ុន្តែនៅតែមានប្រជាពលរដ្ឋខ្លះបានឆ្លងដែនទៅ

រកការងារធ្វើ ដោយខុសច្បាប់ដដែល ដោយសារតែពួកគេធ្វើលិខិតឆ្លងដែន និងឯកសារថ្លៃពេក ដែលធ្វើឱ្យពួកគេកាន់តែលំបាក ខណៈដែលពួកគេកំពុងជំពាក់លុយធនាគារ។ អ្នកស្រីបន្តថា ការធ្វើលិខិតឆ្លងដែនត្រូវចំណាយក្នុងម្នាក់ ជាង១ម៉ឺនបាត ឬស្មើប្រមាណ៣០០ដុល្លារ ទើបអាចធ្វើការបាន៖ «ស្នើឱ្យរដ្ឋាភិបាលគេបើកច្រកចុះឡើងស្រួល។ ព្រោះអីមានប័ណ្ណPassport អ៊ីចឹងបើកឱ្យយើងឡើងមកតម្លៃដូចយើងចុះឡើងបីរយ(បាត)ដូចពីមុខអ៊ីចឹងឱ្យបើកច្រកឡើងស្រួលចុះស្រួល»។ អ្នកស្រីបន្តថា បើសិនជារដ្ឋាភិបាលមិនសម្រួលពីតម្លៃធ្វើលិខិតឆ្លងដែន និងឯកសារមួយចំនួនឱ្យមានភាពងាយស្រួល និងតម្លៃថោកជាងបច្ចុប្បន្ននេះទេ ពលរដ្ឋនៅតែបន្តខុសច្បាប់ដដែល។ អ្នកស្រីថា ពលរដ្ឋភាគច្រើនដែលធ្វើការនៅប្រទេសថៃ បានលុយមកវិញបង់តែថ្លៃធនាគារ និងលិខិតឆ្លងដែន ខណៈដែលពលរដ្ឋខ្លះត្រូវបានមេខ្យល់បោកយកទម្លាក់ចោលតាមព្រំដែនហើយត្រូវបានអាជ្ញាធរថៃចាប់ខ្លួនក៏មានដែរ។

ជុំវិញរឿងនេះ មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) លោក ឌីថេ ហូយ៉ា បានលើកឡើងថា បញ្ហាចំណាកស្រុកដោយខុសច្បាប់នេះជារឿងមួយដែលរដ្ឋាភិបាលត្រូវតែយកចិត្តទុកដាក់ខ្ពស់ដោះស្រាយជូនដល់ប្រជាពលរដ្ឋ។ លោកបន្តថា កន្លងមករដ្ឋាភិបាលហាក់មិនសូវយកចិត្តទុកដាក់ដំណោះស្រាយនោះទេ ដែលធ្វើឱ្យពលរដ្ឋនៅតែបន្តឆ្លងដែនដោយខុសច្បាប់។ លោកមើលឃើញថា បញ្ហាចម្បងគឺដោយសារតែពលរដ្ឋមានបញ្ហាជីវភាពខ្វះខាត ខណៈដែលតម្លៃឯកសារផ្សេងៗ និងលិខិតឆ្លងដែនមានតម្លៃខ្ពស់ហួសពីលទ្ធភាពរបស់ពលរដ្ឋ៖ «យើងសូមអំពាវនាវដល់រដ្ឋាភិបាលគិតគូរធ្វើយ៉ាងណាបង្កើតយន្តការឱ្យសមស្របណាមួយដើម្បីឱ្យពលរដ្ឋយើងទទួលបានឯកសារស្របច្បាប់ដោយអាចធ្វើនៅក្នុងមូលដ្ឋានខេត្ត ឬស្រុកអីជាដើម។ ទី២ តម្លៃវាពាក់ព័ន្ធនឹងតម្លៃការធ្វើឯកសារក៏មិនត្រូវថ្លៃហួសហេតុពេក ហួសពីលទ្ធភាពដែលគាត់ធ្វើកើត...»។

របាយការណ៍ក្រសួងការងារ ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរទៅធ្វើការ ស្របច្បាប់ និងមិនស្របច្បាប់នៅប្រទេសថៃ មានប្រមាណ ១លាន១សែននាក់ ប៉ុន្តែ របាយការណ៍របស់អង្គការសង់ត្រាល់ បានឱ្យដឹងថា មានពលករខ្មែរធ្វើការងារស្របច្បាប់ និងខុសច្បាប់ មានជិត២លាននាក់ ធ្វើការនៅប្រទេសថៃ៕

## ពលករ២៤នាក់(ចិន៧នាក់)ត្រូវទាហានថៃឃាត់ ពេលលួចឆ្លងដែន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២០ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ០៩:៥១

ខេត្តបន្ទាយមានជ័យ ៖ ទាហានឈុតខ្មៅថៃបានឃាត់ពលករចំនួន២៤នាក់ ដែលលួចឆ្លងដែនដោយខុសច្បាប់ ដើម្បីរកការងារធ្វើ ។ ការឃាត់ខ្លួនធ្វើឡើងកាលពីថ្ងៃទី១៨ ឧសភា ឆ្នាំ២០២២ តាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រ ស្រុកអារញ្ញប្រថេត ខេត្តស្រះកែវ ប្រទេសថៃ ។

មន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃបានប្រាប់ថា បានទទួលព័ត៌មានកម្លាំងយោធាឈុតខ្មៅថៃដែលឈរជើងនៅតាមបន្ទាត់ព្រំដែន បានឃាត់ពលករខ្មែរចំនួន២៤នាក់ ក្នុងនោះ មានជនជាតិចិន៧នាក់ និងមេខ្យល់ថៃចំនួន២នាក់ ដែលឃាត់នៅតាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រ ស្រុកអារញ្ញ ប្រថេត ខេត្តស្រះកែវ ។ មន្ត្រីរូបនោះបានបញ្ជាក់ថា ពលករខ្មែរដែលត្រូវបានទាហានឈុតខ្មៅថៃឃាត់ក្នុងចំណោម២៤នាក់ ត្រូវបានលួចឆ្លងដែនទៅប្រទេសថៃតាមរយៈមេខ្យល់ខ្មែរនាំលួចឆ្លងដែនចូលក្នុងទឹកដីថៃហើយមេខ្យល់ថៃចាំទទួលអូរព្រំដែន ត្រូវបានកម្លាំងយោធាថៃឃាត់ ហើយបានធ្វើការពិនិត្យសុខភាពទើបប្រគល់ជូនកម្លាំងប៉ូលិសស្រុកអារញ្ញដើម្បីចាត់ការតាមច្បាប់ ។ មន្ត្រីទំនាក់ទំនងកម្ពុជា-ថៃបានបញ្ជាក់ថា ក្នុងចំណោមពលករខ្មែរដែលត្រូវកម្លាំងទាហានថៃឃាត់បានប្រាប់ថា ខ្លួនបានលួចឆ្លងដែនតាមរយៈមេខ្យល់ខ្មែរ ដើម្បីជូនទៅរកការងារធ្វើនៅប្រទេសថៃក្នុងម្នាក់ តម្លៃ៦.០០០ពាន់បាត ហើយទទួលជូនទៅរកការងារធ្វើដល់កន្លែងនៅពេលដែលជូនដល់មេខ្យល់ថៃទទួលជូនបន្តដើម្បីឡើងរថយន្ត តែត្រូវបានទាហានឈុតខ្មៅថៃឃាត់តែម្តង ។

# ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

## ប្រទេសថៃមានគម្រោងធ្វើឲ្យពលករចំណាកស្រុកកម្ពុជាស្របច្បាប់ព្រមទាំងអ្នកមកពីបីប្រទេសផ្សេងទៀត

https://www.khmertimeskh.com/ May 22, 2022

ក្រសួងការងារថៃ កំពុងស្វែងរកការធ្វើឱ្យស្របច្បាប់ចំពោះជនចំណាកស្រុក ដែលគ្មានឯកសារដែលធ្វើការក្នុងវិស័យសេវាកម្មរបស់ព្រះរាជាណាចក្រ ចំពេលមានតម្រូវការខ្ពស់សម្រាប់ការងារនាំចូល។ ប្រសិនបើផែនការនេះត្រូវបានអនុម័ត ពលករខុសច្បាប់មួយចំនួនមកពីប្រទេសជិតខាង កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម នឹងត្រូវបានផ្តល់ឱកាសឱ្យចុះឈ្មោះធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃ។

លោក Pairoj Chotikasathien អគ្គនាយក នៃនាយកដ្ឋានការងារ បាននិយាយថា ការចុះឈ្មោះពិសេសដែលគេជឿថា នឹងទទួលបានអត្ថប្រយោជន៍ពី ៥០,០០០ ទៅ ៦០,០០០ នាក់ដែលកំពុងធ្វើការនៅក្នុងប្រទេសនេះ នឹងចាប់ផ្តើមពីសប្តាហ៍បន្ទាប់ពីគណៈរដ្ឋមន្ត្រីបានអនុម័ត លើសេចក្តីសម្រេចលើបញ្ហានេះដោយគណៈកម្មាធិការគ្រប់គ្រងពលករចំណាកស្រុករបស់ក្រសួងការងារ។ លោក Pairoj ថ្លែងបន្ទាប់ពីកិច្ចប្រជុំគណៈកម្មាធិការដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin។ លោក Pairoj បាននិយាយថា ក្រុមពិភាក្សានេះកំពុងផ្តោតលើកម្មករខុសច្បាប់នៅក្នុងឧស្សាហកម្មសេវាកម្ម រួមទាំងអ្នកដែលធ្វើការនៅក្នុងភោជនីយដ្ឋានផងដែរ។ វានៅតែមិនច្បាស់ថា តើសំណើនេះនឹងត្រូវបញ្ជូនទៅគណៈរដ្ឋមន្ត្រី ដើម្បីអនុម័តនៅពេលណា។

Poj Aramwattananont អនុប្រធានសភាពាណិជ្ជកម្មថៃ និងជាសមាជិកនៃគណៈកម្មាធិការបាននិយាយថា ចំណាត់ការនេះនឹងផ្តល់អត្ថប្រយោជន៍ដល់និយោជកដែលកំពុងស្វែងរកការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពស្របច្បាប់របស់ពលករចំណាកស្រុករបស់ពួកគេ។ លោក Poj បាននិយាយថា "នៅពេលដែលបានចុះឈ្មោះ ពលករទាំងនេះនឹងអាចធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃរហូតដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំក្រោយ ហើយត្រូវបានអនុញ្ញាតឱ្យបន្តប័ណ្ណការងាររបស់ពួកគេជារៀងរាល់ឆ្នាំរហូតដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥"។ លោកបន្តថា បន្ថែមពីលើនេះ ដើម្បីសម្រួលដល់ការចុះបញ្ជីជនចំណាកស្រុក ក្រសួងមហាផ្ទៃ និងការិយាល័យអន្តោប្រវេសន៍ នឹងធ្វើការរួមគ្នាដើម្បីបញ្ចុះថ្លៃទិដ្ឋាការសម្រាប់ពលករទាំងនេះពី ២០០០បាត ទៅ ៥០០បាត។

ឆ្លើយតបទៅនឹងរបាយការណ៍ស្តីពីភាពអត់ការងារធ្វើរបស់យុវជន លោក Pairoj បាននិយាយថា ៨៥% នៃប្រជាជនប្រហែល ៧៩៥,៥០០នាក់ ដែលបានបញ្ចប់ការសិក្សានៅចន្លោះឆ្នាំ២០២០ និងឆ្នាំមុន ឥឡូវនេះត្រូវបានចុះឈ្មោះក្រោមប្រព័ន្ធសន្តិសុខសង្គមរបស់ព្រះរាជាណាចក្រ ដែលមានន័យថាពួកគេឥឡូវនេះត្រូវបានជួលដោយក្រុមហ៊ុនឯកជន។ លោកបន្តថា ទន្ទឹមនឹងនេះ ប្រហែល ១៤% ត្រូវបានរដ្ឋផ្តល់ការងារធ្វើ ហើយក្រៅពីនោះ មានទាំងអ្នកធ្វើការសេរី ឬអ្នកអត់ការងារធ្វើ។

## ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បង្ហាញលទ្ធផលក្រោយចូលរួម «វេទិកាពិនិត្យឡើងវិញទេសន្តរប្រវេសន៍អន្តរជាតិ» នៅទីក្រុងញូវយ៉ក

http://m.freshnewsasia.com/ 2022-05-23 06:45pm

**(ភ្នំពេញ)៖** កិច្ចប្រជុំអង្គការសហប្រជាជាតិ ស្ដីពី «វេទិកាពិនិត្យឡើងវិញនូវទេសន្តរប្រវេសន៍អន្តរជាតិ» (International Migration Review Forum: IMRF) បានប្រព្រឹត្តទៅនៅទីក្រុងញូវយ៉ក ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដោយមានប្រទេសចំនួន១៩៥ លើពិភពលោកចូលរួម។ កម្ពុជា ក្នុងនាមជាប្រទេសជ័យលាភី មួយក្នុងចំណោម ប្រទេស៣៣ក្នុងពិភពលោក នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ បានចូលរួមយ៉ាងសកម្ម ក្នុងដំណើរការនៃកិច្ចប្រជុំនេះ និងបានត្រឡប់មកវិញដោយសុវត្ថិភាព។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលការចាត់តាំងពីសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដឹកនាំគណៈប្រតិភូអន្តរក្រសួងមួយក្រុម ដែលមានតំណាងពី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ និងមានការសម្របសម្រួល និងចូលរួមយ៉ាងសកម្មពីលោក កែ សុវណ្ណ ឯកអគ្គរាជទូត ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ផងដែរ។

ក្នុងសេចក្ដីប្រកាសព័ត៌មាន ដែលបណ្ដាញព័ត៌មាន Fresh News ទទួលបាននៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២នេះ បានបញ្ជាក់ថា មានកិច្ចប្រជុំដែលហៅថា ជាព្រឹត្តិការណ៍អម ចំនួន២៣ផ្សេងទៀត ដែលក្រុមនៃប្រទេស ឬជាកិច្ចសហការរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ ឬអង្គការឯកទេស ជាមួយប្រទេសមួយចំនួន ត្រូវបានរៀបចំឡើងទន្ទឹមនឹងកិច្ចប្រជុំរួមនេះ។ ក្នុងនោះបានផ្ដោតលើប្រធានបទពាក់ព័ន្ធ ជុំវិញការអនុវត្ត គោលបំណងអាទិភាពទាំង២៣ របស់កតិកាសញ្ញាពិភពលោក ដែលរួមទាំងបទពិសោធន៍ល្អ ភាពប្រឈម ដំណោះស្រាយ និងអនុសាសន៍ឬសំណូមពរផ្សេងៗ ដែលអាចធ្វើឲ្យដំណើរការ នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ ប្រព្រឹត្តិទៅបានជោគជ័យក្នុងការការពារ សិទ្ធិ និងផលប្រយោជន៍ជនទេសន្តរប្រវេសន៍។

គណៈប្រតិភូកម្ពុជា បានចូលរួមក្នុងកិច្ចពិភាក្សាមួយចំនួន ដែលពាក់ព័ន្ធនឹងជម្រើសជាអាទិភាពរបស់កម្ពុជា និងបានចូលរួមផ្ដល់បទពិសោធន៍ និងធ្វើសេចក្ដីថ្លែងការណ៍បញ្ជាក់ពីការប្ដេជ្ញាចិត្តដោយឥតងាករេ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមគាំទ្រដំណើការ នៃការអនុវត្តកាតិការណ៍សញ្ញាពិភពលោក ដើម្បីការពារពលករទេសន្តរប្រវេសន៍ ដែលបាននិងកំពុងរងនូវការកេងប្រវ័ញ្ច អំពើហិង្សា អំពើជួញដូរមនុស្ស ការងារដោយបង្ខំ និងរហូតដល់ជាទាសភាពជាដើម។បទពិសោធន៍របស់កម្ពុជាបានធ្វើឲ្យបណ្ដាប្រទេសអបអរសាទរនិងកោតសរសើរជាខ្លាំង។ ទន្ទឹមនឹងនោះ គណៈប្រតិភូនៃប្រទេស ក្រូអាត បង់ក្លាដេស កាណាដា ព្រុយណេដារូសាឡឹម បានស្នើសុំជួបជាទ្វេភាគី ដើយបានសម្ដែងនូវការអបអរសាទរចំពោះកម្ពុជា ក្រោមការដឹកនាំដោយសម្ដេចតេជោ ហ៊ុន សែន ក្នុងការដឹកនាំប្រទេសឲ្យរួចផុតពីគ្រោះមហន្តរាយដោយកូវីដ១៩ បានឆាប់រហ័ស និងធ្វើឲ្យដំណើការសេដ្ឋកិច្ចសង្គម ប្រព្រឹត្តទៅបានដោយរលូនជាថ្មី។ ទន្ទឹមនឹងនោះ ភាពជាអ្នកដឹកនាំអាស៊ានរបស់កម្ពុជា ក៏ជាឱកាសដ៏សំខាន់ក្នុងការដោះ

ស្រាយបញ្ហាតំបន់ ហើយប្រទេសទាំងនោះ មានបំណងពង្រឹងកិច្ចសហការក្នុងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងសិក្សាធិការផងដែរ៕

## កម្ពុជាប្តេជ្ញាឥតងាករេ អនុវត្តកាតិកាសញ្ញាពិភពលោក ដើម្បីការពារពលករទេសន្តរប្រវេសន៍ទេការកេងប្រវ័ញ្ច

https://news.btv.com.kh/ 2022/05/23 08:00:15 pm

ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តដោយឥតងាករេ ក្នុងការចូលរួមគាំទ្រដំណើរការ នៃការអនុវត្តកាតិកាសញ្ញាពិភពលោក ដើម្បីការពារពលករទេសន្តរប្រវេសន៍ ដែលបាននិងកំពុងរងនូវការកេងប្រវ័ញ្ចនៅលើពិភពលោក។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ បានឲ្យដឹងថា កិច្ចប្រជុំអង្គការសហប្រជាជាតិ "ស្តីពីវេទិកាពិនិត្យឡើងវិញនូវទេសន្តរប្រវេសនន៍អន្តរជាតិ" (IMRF) បានប្រព្រឹត្តទៅនៅទីក្រុងញូវយ៉ក ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដោយមានប្រទេសចំនួន១៩៥ លើពិភពលោកចូលរួម ហើយកម្ពុជាក្នុងនាមជាប្រទេសជ័យលាភីមួយ នៅក្នុងចំណោមប្រទេស៣៣ ក្នុងពិភពលោក នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ បានចូលរួមយ៉ាងសកម្ម ក្នុងដំណើរការនៃកិច្ចប្រជុំនេះ និងបានត្រឡប់មកវិញដោយសុវត្ថិភាព។

សេចក្តីប្រកាសព័ត៌មានបន្តថា ភាគីកម្ពុជា លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹក នាំគណៈប្រតិភូអន្តរក្រសួង មួយក្រុមទៅចូលរួមប្រជុំ ក្រៅពីកិច្ចប្រជុំអង្គការសហប្រជាជាតិ បានប្រជុំព្រឹត្តិការណ៍អមចំនួន២៣ផ្សេងទៀត ដែលក្រុមនៃប្រទេស ឬជាកិច្ចសហការរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ ឬអង្គការឯកទេស ជាមួយប្រទេសមួយចំនួនត្រូវបានរៀបចំឡើង ។ ប្រភពបន្ថែមថា ទន្ទឹមនឹងកិច្ចប្រជុំរួមនេះ ដោយផ្តោតលើប្រធានបទពាក់ព័ន្ធជុំវិញការអនុវត្តគោលបំណងអាទិភាពទាំង២៣ របស់កតិការសញ្ញាពិភពលោក ដែលរួមទាំងបទពិសោធន៍ល្អ ភាពប្រឈមដំណោះស្រាយ និងអនុសាសន៍ឬសំណូមពរផ្សេងៗ ដែលអាចធ្វើឲ្យដំណើរការនៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ប្រព្រឹត្តិទៅបានជោគជ័យ ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ជនទេសន្តរប្រវេសន៍ ។

សេចក្តីប្រកាសព័ត៌មាន បានបញ្ជាក់ថា គណៈប្រតិភូកម្ពុជា បានចូលរួមក្នុងកិច្ចពិភាក្សាមួយចំនួន ដែលពាក់ព័ន្ធនឹងជម្រើសជាអាទិភាពរបស់កម្ពុជា និងបានចូលរួមផ្តល់បទពិសោធន៍ និងធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់ពីការប្តេជ្ញាចិត្តដោយឥតងាករេ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមគាំទ្រដំណើការ នៃការអនុវត្តកាតិការណ៍សញ្ញាពិភពលោក ដើម្បីការពារពលករទេសន្តរប្រវេសន៍ ដែលបាននិងកំពុងរងនូវការកេងប្រវ័ញ្ច អំពើហិង្សា អំពើជួញដូរមនុស្ស ការងារដោយបង្ខំ និងរហូតដល់ជាទាសភាពជាដើម ហើយបទពិសោធន៍របស់កម្ពុជា បានធ្វើឲ្យបណ្តាប្រទេសអបអរសាទរ និងកោតសរសើរជាខ្លាំង៕ អត្ថបទ: បាន សុខរិទ្ធិ

## រថយន្តថៃ៥គ្រឿងដឹកពលករចេញពីព្រំដែន ត្រូវស្ទាក់ចាប់ពលករខ្មែរជាង៣០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៣ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៤:៥៤

ខេត្តបន្ទាយមានជ័យ ៖ រថយន្តថៃចំនួន៥គ្រឿង ដែលលួចដឹកពលករខ្មែរចេញពីចំណុចព្រំដែន ត្រូវសមត្ថកិច្ចថៃស្ទាក់ចាប់បានពលករខ្មែរចំនួន៣៥នាក់ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២កន្លងទៅ នៅក្នុងភូមិសាស្រ្តស្រុកអារញ្ញ ខេត្តស្រះកែវ ។

មន្រ្តីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ បានឲ្យដឹងថា កម្លាំងយោធាថៃឈរជើងតាមបន្ទាត់ព្រំដែន ពិតជាបានឃាត់រថយន្តចំនួន៥គ្រឿង ដែលដឹកពលករខ្មែរប្រុស-ស្រីចំនួន៣៥នាក់ ក្នុងនោះមានជនជាតិថៃ៥នាក់ ដោយចាប់បញ្ជូនទៅប្រគល់ឱ្យកម្លាំងប៉ូលិសនៅស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ចាត់ការតាមច្បាប់ ។ ប្រភពដដែលឲ្យដឹងទៀតថា ក្រោយពីត្រូវឃាត់ខ្លួន ពលករខ្មែរទាំងនោះត្រូវបាននាំយកទៅសាកសួរនៅស្នាក់ការប៉ូលិសស្រុកអារញ្ញ ហើយពួកគាត់ឆ្លើយថា បានលួចឆ្លងចូលមកទឹកដីថៃតាមរយៈមេខ្យល់ខ្មែរ ដែលយកលុយក្នុងម្នាក់៥.០០០បាត ។ នៅពេលជូនចូលដល់ក្នុងទឹកដីថៃ មានមេខ្យល់ថៃបន្តជូនទៅជិះរថយន្ត ក្នុងគោលបំណងទៅរកការងារធ្វើនៅប្រទេសថៃ ។ ប៉ុន្តែ នៅពេលជិះរថយន្តចេញពីព្រំដែន ក៏ត្រូវសមត្ថកិច្ចថៃឃាត់រថយន្តទាំង៥គ្រឿង ដែលដឹកពួកគាត់សរុបចំនួន៣៥នាក់នេះ ។ តាមចម្លើយម្ចាស់រថយន្តថា ពួកខ្លួនគ្រាន់តែស៊ីឈ្នួលដឹកពីព្រំដែនទៅដល់កន្លែងធ្វើការនៅក្រុងបាងកកប៉ុណ្ណោះ ដោយក្នុងម្នាក់យកថ្លៃឈ្នួល៩០០បាត ៕

## ពលរដ្ឋខ្មែរចំនួន១៩នាក់ ប៉ុនប៉ងខ្លួនចេញពីទឹកដីខ្មែរ ចូលដល់ទឹកដីថៃប៉ុនប៉ងមិនជិតត្រូវថៃឃាត់ខ្លួនបាន

https://gdlf-kh.com/ 2022/05/23/ Noun Vanny បន្ទាយមានជ័យ

បន្ទាយមានជ័យ ៖ នៅថ្ងៃចន្ទ ៨ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ប្រជាពលរដ្ឋខ្មែរប្រុស ស្រី ចំនួន១៩នាក់ ត្រូវបានទាហាន (ព្រាន) ឈុតខ្មៅថៃអនុសេនាធំ ១៣.០៥ ដែលប្រចាំការទល់មុខភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ បានឃាត់ខ្លួន នៅវេលាម៉ោង០៥ទាបភ្លឺ ពីបទលួចឆ្លងដែនខុសច្បាប់ត្រង់ចំណុចភូមិឃុតហ៊ីន ឃុំក្លូងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា ៖ តាមការឲ្យដឹងពីសមត្ថកិច្ចថៃ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានទទួលព័ត៌មានពីសមត្ថកិច្ចថៃ នៅវេលាម៉ោង០៥ទាបភ្លឺ ឈានចូលថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ទាហាន (ព្រាន) ឈុតខ្មៅថៃអនុសេនាធំ ១៣.០៥ ដែលប្រចាំការទល់មុខភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរដែលលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃចំនួន ១៩នាក់ (ស្រី០៩នាក់ កុមារ០៤នាក់) ត្រង់ចំណុចភូមិឃុតហ៊ីន ឃុំក្លូងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវប្រទេសថៃ ទល់មុខភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ លោកមេបញ្ជាការបានបញ្ជាក់ថា ៖ ប្រជាពលរដ្ឋខ្មែរទាំង១៩នាក់នោះ បន្ទាប់ពីសួរនាំនិងពិនិត្យកំដៅរួចទាហាន (ព្រាន) ឈុតខ្មៅថៃ បានបញ្ជូនពួកគាត់ ទៅអធិការដ្ឋាននគរបាលក្លូងណាំសៃ ដើម្បីចាត់ការបន្តតាមនីតិវិធី ៕

## នៅព្រឹកថ្ងៃចន្ទ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/05/23/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង ០៦ និង០០នាទី នាថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹម សាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១៣នាក់ ស្រី៥នាក់ ក្មេងប្រុស១នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើការពិនិត្យ និងស្តែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២

## កម្ពុជាបន្តប្តេជ្ញាក្នុងការចូលរួមគាំទ្រការអនុវត្តកតិកាសញ្ញាពិភពលោក ដើម្បីការពារពលករទេសន្តរប្រវេសន៍

https://www.postkhmer.com/ ឡាយ សាមាន | Publication date 24 May 2022 | 20:33 ICT

**ភ្នំពេញ**៖រាជរដ្ឋាភិបាលកម្ពុជា បន្តប្តេជ្ញាក្នុងការចូលរួមគាំទ្រដំណើរការនៃការអនុវត្ត កតិកាសញ្ញាពិភពលោក ដើម្បីការពារពលករទេសន្តរប្រវេសន៍ ដែលបាននិងកំពុងរងនូវការកេងប្រវ័ញ្ច ទទួលរងនូវអំពើហិង្សា អំពើជួញដូរមនុស្ស និងរហូតដល់ជាទាសភាពជាដើម។ ការបញ្ជាក់ជំហរនេះ ធ្វើឡើងក្នុងអំឡុងពេលដែលលោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានដឹកនាំគណៈប្រតិភូកម្ពុជាពីស្ថាប័នមួយចំនួន រួមមាន អគ្គនាយកដ្ឋានអន្តោប្រវេសន៍ តំណាងពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល អញ្ជើញទៅចូលរួមក្នុងវេទិកាអន្តរជាតិលើកទី១ ស្តីពីការពិនិត្យឡើងវិញ នូវទេសន្តរប្រវេសន៍អន្តរជាតិ នៅអង្គការសហប្រជាជាតិ ទីក្រុងញូវយ៉ក ដែលមានរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២២។

បន្ទាប់ពីដឹកនាំគណៈប្រតិភូមាតុភូមិនិវត្តន៍មកវិញកាលពីថ្ងៃទី២៣ ខែឧសភា លោកស្រី ជូ ប៊ុនអេង បានគូសបញ្ជាក់អំពីសកម្មភាព ដែលសម្រេចបាន ក្រោយចូលរួមវេទិកានេះថា ក្នុងនាមកម្ពុជា ជាប្រទេសជយលាភីមួយក្នុងចំណោម ប្រទេស ៣៣ ក្នុងពិភពលោក នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ គឺបានចូលរួមយ៉ាងសកម្ម ក្នុងដំណើរការនៃកិច្ចប្រជុំនេះ។ ក្នុងវេទិកាអន្តរជាតិនោះ ក៏មានកិច្ចប្រជុំអង្គការសហប្រជាជាតិដែលហៅថា ជាព្រឹត្តិការណ៍អម ចំនួន២៣ផ្សេងទៀត ដែលក្រុមនៃ

ប្រទេស ឬជាកិច្ចសហការរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ ឬអង្គការឯកទេសជាមួយប្រទេសមួយចំនួន ត្រូវបានរៀបចំឡើងទន្ទឹមនឹងកិច្ចប្រជុំរួមនេះ។ លោកស្រីបន្តថា ក្នុងនោះបានផ្តោតលើប្រធានបទពាក់ព័ន្ធ ជុំវិញការអនុវត្ត គោលបំណងអាទិភាពទាំង២៣ របស់កតិកាសញ្ញាពិភពលោក ដែលចូលរួមចែករំលែកទាំងបទពិសោធល្អៗ ភាពប្រឈម ដំណោះស្រាយ និងអនុសាសន៍ឬសំណូមពរផ្សេងៗ ដែលអាចធ្វើឱ្យដំណើរការ នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពី "ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់" ប្រព្រឹត្តិទៅបានជោគជ័យក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ជនទេសន្តរប្រវេសន៍ ។

លោកស្រីមានប្រសាសន៍ថា៖« គណៈប្រតិភូកម្ពុជា បានចូលរួមក្នុងកិច្ចពិភាក្សាមួយចំនួន ដែលពាក់ព័ន្ធនឹងជម្រើសជាអាទិភាពរបស់កម្ពុជា និងបានចូលរួមផ្តល់បទពិសោធ និងធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់ពីការប្តេជ្ញាចិត្តដោយឥតងាករេ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមគាំទ្រដំណើការ នៃការអនុវត្តកតិកាសញ្ញាពិភពលោក ដើម្បីការពារពលករទេសន្តរប្រវេសន៍ ដែលបាននិងកំពុងរងនូវការកេងប្រវ័ញ្ច អំពើហិង្សា អំពើជួញដូរមនុស្ស ការងារដោយបង្ខំ និងរហូតដល់ជាទាសភាពជាដើម»។ លោកស្រីបានឱ្យដឹងទៀតថា បទពិសោធរបស់កម្ពុជាដែលត្រូវបានចែករំលែកនៅក្នុងវេទិកានោះ បានធ្វើឱ្យបណ្តាប្រទេសនានាអបអរសាទរ និងកោតសរសើរជាខ្លាំង។ ទន្ទឹមនឹងនោះ គណៈប្រតិភូនៃប្រទេស ក្រូអាត បង់ក្លាដែស កាណាដា ព្រុយណេដារូសាឡឹម បានស្នើសុំជួបជាទ្វេភាគី ដើម្បីបានសម្តែងនូវការអបអរសាទរចំពោះកម្ពុជា ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្រ្តី ហ៊ុន សែន ក្នុងការដឹកនាំប្រទេសឱ្យរួចផុតពីគ្រោះមហន្តរាយដោយជំងឺកូវីដ១៩ បានឆាប់រហ័ស និងធ្វើឱ្យដំណើការសេដ្ឋកិច្ចសង្គមប្រព្រឹត្តទៅបានដោយរលូនជាថ្មី។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្សលោក មឿន តុលា ថ្លែងថា ការចូលរួមក្នុងការផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមកជារឿងល្អ ដែលអាចជួយឱ្យកម្ពុជាមានបណ្តាញកាន់តែធំបន្ថែមទៀត ពាក់ព័ន្ធការជួញដូរពលករទេសន្តរប្រវេសន៍ដោយខុសច្បាប់ ព្រោះ របៀបនៃការជួញដូរ ល្បិចកល របស់ជនល្មើសមានភាពផ្សេងៗគ្នា។ ប៉ុន្តែលោកថា អ្វីដែលសំខាន់នោះ គឺការអនុវត្តន៍ច្បាប់នៅក្នុងស្រុកឱ្យមានប្រសិទ្ធភាពដែលជាកិច្ចការដ៏សំខាន់ ក្នុងចំណោមការងារអាទិភាពផ្សេងទៀត។ លោកថា៖«ព្រោះកម្ពុជាយើងក៏ធ្លាប់បានចូលរួមវគ្គផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមកច្រើនដែលទោះបីក្នុងបរិបទកូវីដ១៩ ប៉ុន្តែរឿងដែលសំខាន់បំផុត គឺការអនុវត្តន៍ច្បាប់នៅក្នុងស្រុកជារឿងសំខាន់ ថាតើយើងមានច្បាប់ហើយ តើការអនុវត្តនោះមានប្រសិទ្ធភាពប៉ុណ្ណា ថាតើប្រព័ន្ធយុត្តិធម៌នៅយើងមានភាពឯករាជ្យ ហានចាត់ការទៅលើមេខ្យល់ដែលមានបណ្តាញជាមួយអ្នកមានអំណាចដែរឬទេ»។

សូមជម្រាបថា កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ គឺជាប្រកខណ្ឌទូលំទូលាយទីមួយរបស់ UN ដែលត្រូវបានអនុម័ត តាមរយៈកិច្ចពិភាក្សា អន្តររដ្ឋាភិបាល ដើម្បីធ្វើឱ្យកិច្ចសហការអន្តរជាតិ ឱ្យមានភាពល្អប្រសើរ ក្នុងអភិបាលកិច្ចទេសន្តរប្រវេសន៍ជាសកល។ កតិកាសញ្ញាពិភពលោកនេះ ត្រូវបានឯកភាពគាំទ្រដោយមហាសន្និបាត UN ដែលបានប្រារព្ធធ្វើឡើងកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៨ នៅទីក្រុងញ៉ូយ៉ក ដែលមានសមាជិកចូលរួមចំនួន ១៥២ប្រទេស៕

## ស្ត្រីម្នាក់ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ក្រោយប្រើហិង្សាលើក្មេងស្រីម្នាក់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៤ ឧសភា ២០២២ដោយ Sokhom Khon

កម្លាំងនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌទួលគោក បានស្រាវជ្រាវឃាត់ខ្លួនស្ត្រីសង្ស័យដែលប្រើអំពើហិង្សាលើក្មេងស្រីម្នាក់បណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ បន្ទាប់ពីស្ត្រីសង្ស័យរូបនោះ សុំក្មេងស្រីរងគ្រោះពីម្តាយយកមកនៅជាមួយអស់រយះពេលជាង១ឆ្នាំមកហើយ។ ការឃាត់ខ្លួនស្ត្រីរូបនេះ បានធ្វើឡើងនៅចំណុចមុខផ្ទះលេខ១៣Eo

ផ្លូវលេខ២១៩ ក្រុមទី២២ ភូមិ០៣ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីវេលាម៉ោងប្រហែល២៣និង៣០នាទីយប់ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២។

នគរបាលបានឲ្យដឹងថា ស្ត្រីសង្ស័យមានឈ្មោះ ចាន់ ធីតា ហៅ ធីតា ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់កាហ្វេ ស្នាក់នៅផ្ទះលេខ១៣Eo ផ្លូវលេខ២១៩ ក្រុមទី២២ ភូមិ០៣ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ចំណែកក្មេងស្រីរងគ្រោះឈ្មោះ កេង ស្រីកា ភេទស្រី អាយុ៦ឆ្នាំ ជនជាតិខ្មែរ ស្នាក់នៅផ្ទះជាមួយជនសង្ស័យឈ្មោះ ចាន់ ធីតា ហៅ ធីតា នៅផ្ទះកើតហេតុ។ តាមប្រភពព័ត៌មានបានឲ្យដឹងថា កាលពីកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រហែល២១និង០០នាទី ស្ត្រីសង្ស័យបានប្រើដៃវាយលើផ្ទៃមុខ និងប្រើដែកទំពួកសំរាប់ព្យួរខោអាវវាយលើក្មេងស្រីរងគ្រោះបណ្តាលឲ្យរបួសធ្ងន់ធ្ងរ។

បច្ចុប្បន្នក្មេងស្រីរងគ្រោះសមត្ថកិច្ចបានប្រគល់ជូនមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ និងបានបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញក្រោមការថែទាំជាបណ្តោះសន្នរបស់អង្គការមិត្តសំឡាញ់។ ចំណែកស្ត្រីជនសង្ស័យ បានបញ្ជូនទៅកាន់អធិការដ្ឋាននគរបាលខណ្ឌទួលគោក ដើម្បីធ្វើការសាកសួរ និងចាត់ការបន្តតាមនីតិវិធី ៕

## UNODC **សម្ពោធយុទ្ធនាការបង្កើនការយល់ដឹងពីផលវិបាកនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ**

http://freshnewsasia.com/ 2022-05-24 11:21am

**(ភ្នំពេញ)៖** ដើម្បីចូលរួមដោះស្រាយឧបសគ្គចម្បងមួយចំនួន ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក ក្រោមការគាំទ្ររបស់ការិយាល័យកិច្ចការបរទេស នៃសហព័ន្ធអាល្លឺម៉ង់ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ បានបើកយុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈ ដែលនឹងដំណើរការក្នុងរយៈពេល៦ខែ ក្នុងគោលបំណងពង្រឹងទំនាក់ទំនងរវាងសហគមន៍ និងមន្ត្រីនគរបាល ព្រមទាំងជូនដំណឹងដល់សាធារណជន អំពីសកម្មគាំទ្រនានាដែលមានស្រាប់ ដើម្បីដោះស្រាយឧក្រិដ្ឋកម្មនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ បើទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដូចជាការពង្រឹងសមត្ថភាព និងជំនាញដល់មន្ត្រីនរគបាល ក្នុងការបង្ការ ទប់ស្កាត់ និងឆ្លើយតបចំពោះជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

លោក Felipe De La Torre អ្នកសម្របសម្រួលប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក ន UNODC បានថ្លែងថា «**UNODC មានសេចក្តីសោមនស្សរីករាយណាស់ ដែលបានចូលរួមចំណែកដល់ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ២០១៩-២០២៣ តាមរយៈយុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈនេះ។ យើងមានគោលបំណងបញ្ជ្រាបចំណេះដឹង អំពីផលប៉ះពាល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រកើតឡើងនៅក្នុងទីក្រុងភ្នំពេញ និងដើម្បីឱ្យប្រជាជនបានយល់ដឹងអំពីសេវាកម្ម ដែលមានសម្រាប់ជនរងគ្រោះ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ មិនត្រឹមតែប៉ះពាល់ដល់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងសង្គមរបស់សហគមន៍ផងដែរ**»។ លោកបានបន្ថែមថា យុទ្ធនាការនេះ គឺជាផ្នែកមួយនៃសកម្មភាពទាក់ទាញការគាំទ្រមតិ និងបង្កើនការយល់ដឹងនៃគម្រោងរបស់ UNODC ដែលផ្តោតលើវិធីសាស្ត្រនគរបាលសហគមន៍ក្នុងការកាត់បន្ថយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់ក្នុងរាជធានីភ្នំពេញ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយនគរបាលជាតិកម្ពុជា គម្រោងនេះផ្តោតទៅលើការកសាងសមត្ថភាពមន្ត្រីនគរបាលជួរមុខទាំងបុរស និងស្ត្រី

ដោយផ្តោតលើការពង្រឹងជំនាញកំណត់អត្តសញ្ញាណ ជំនាញរាយការណ៍ និងសរសេររបាយការណ៍អំពីឧប្បត្តិហេតុនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ក្រោមកិច្ចសហការជាមួយមន្ទីរកិច្ចការនារី រាជធានីភ្នំពេញ និងការិយាល័យសង្គមកិច្ច និងសុខុមាលភាពខណ្ឌសហគមន៍ចំនួន៦ ស្ថិតនៅក្នុងខណ្ឌចំនួន៣ នៅក្នុងរាជធានីភ្នំពេញ រួមមាន៖ ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ ត្រូវបានរកឃើញថា ជាសហគមន៍កំពុងប្រឈមហានិភ័យខ្ពស់ នឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ យុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈនេះ ផ្តោតលើក្រុមគោលដៅជាច្រើន ជាពិសេសស្ត្រីដែលមានអាយុចន្លោះពី១៥ ទៅ ៤៩ឆ្នាំ។ យុទ្ធនាការនេះនឹងបានទៅដល់សាធារណជន តាមរយៈការផ្សព្វផ្សាយសារផ្សេងៗតាមប្រព័ន្ធអនឡាញ និងការបោះពុម្ព។ ក្នុងនោះក៏មានសារចែករំលែក ដោយបុគ្គលសាធាណៈមកពីវិស័យផ្សេងៗគ្នាផងដែរ។ ជាមួយនឹងការប្រើប្រាស់ hashtag # ឈប់ទ្រាំនឹងអំពើហិង្សា និងសារគន្លឹះ **«មានអាជ្ញាធរ និងអ្នកជំនាញចាំជួយអ្នកជានិច្ច»** យុទ្ធនាការនេះមានគោលបំណងលើកទឹកចិត្តដល់ជនរងគ្រោះ និងសាក្សីត្រូវហ៊ានជំនះគំនាបវប្បធម៌ និងសង្គមពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ហើយត្រូវហ៊ាននិយាយតាមរយៈការបណ្តុះមតិ និងអារម្មណ៍វិជ្ជមានចំពោះការស្វែងរកជំនួយនៅពេលចាំបាច់។

ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងលោកស្រី ស ស៊ីណែត អគ្គនាយិការង នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម នៃក្រសួងកិច្ចការនារី ដែលទទួលស្គាល់ថា ជាជើងឯកប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានមានប្រសាសន៍ ក្នុងពិធីសម្ពោធនេះដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការគ្របដណ្តប់ ទៅលើសហគមន៍ដែលងាយរងគ្រោះបំផុត។

ថ្លែងក្នុងសន្ទរកថាបិទកម្មវិធី លោកស្រី Dr Angelika Stauder លេខាទី១ និងជាអនុប្រធានផ្នែកសហប្រតិបត្តិការ នៃស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំកម្ពុជា បានលើកឡើងថា៖ «មន្ត្រីនគរបាលតែម្នាក់ឯង មិនអាចដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីបានទេ។ នេះជាបញ្ហាសង្គមដែលទាមទារឱ្យមានការឆ្លើយតបពីសង្គមទាំងមូល។ ប៉ុន្តែកម្លាំងនគរបាល គឺមានអំណាច និងការទទួលខុសត្រូវជាពិសេស នោះគឺជាការការពារជនរងគ្រោះពីហានិភ័យបន្ថែមទៀតការតាមចាប់ជនល្មើស និងការទប់ស្កាត់ឧក្រិដ្ឋកម្មនានា។ លោកស្រី Dr Angelika Stauder បានបង្ហាញការសង្ឃឹមយុទ្ធនាការផ្សព្វផ្សាយផ្សព្វផ្សាយសាធារណៈនេះ គឺជាជំហានដ៏សំខាន់មួយក្នុងការដឹកនាំជនរងគ្រោះឆ្ពោះទៅរក និងប្រើប្រាស់សេវាផ្តល់ដោយនគរបាល និងសេវាជានាសុវត្ថិភាពដែលមានស្រាប់ដទៃទៀត៕

## លោក ជីវ ផល្លី ៖ មន្ត្រីអនុវត្តច្បាប់មិនលើកលែងទេ ចំពោះជនណាប្រើអំពើហិង្សា

https://dap-news.com/national/ BySS107Posted on May 24, 2022

ភ្នំពេញ ៖ លោកឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា បានថ្លែងថា មន្ត្រីអនុវត្តច្បាប់មិនលើកលែងទេ នឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់បំផុត ចំពោះអ្នកប្រព្រឹត្តអំពើហិង្សាចូលដល់បទល្មើសព្រហ្មទណ្ឌ ។ ក្នុងឱកាសសម្ពោធយុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈ ដើម្បីបង្កើនការយល់ដឹងអំពីផលវិបាកនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងរាជធានីភ្នំពេញ រៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក ក្រោមការគាំទ្ររបស់ការិយាល័យកិច្ចការបរទេសនៃសហព័ន្ធអាល្លឺម៉ង់ នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ លោកឧត្តមសេនីយ៍ឯក ជីវ ផល្លី បានអំពាវនាវដល់ពលរដ្ឋទាំងអស់ដែលទទួលរង

អំពើហិង្សា ចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចផ្តល់ព័ត៌មានក៏ដូចជារាយការណ៍ ដល់មន្ត្រីអនុវត្តច្បាប់ ដើម្បីមានចំណាត់ការតាមនីតិវិធី។

លោកបន្តថា ករណីបង្កអំពើហិង្សាក្នុងគ្រួសារភាគច្រើនកើតឡើងពីការប្រចណ្ឌ , ការប្រើប្រាស់គ្រឿងញៀន , សេពគ្រឿងស្រវឹង និងមួយចំនួនទៀតបណ្តាលមកពីភាពអត់ការងារធ្វើឈានដល់ការលេងល្បែងស៊ីសងខុសច្បាប់ ។ លោកឧត្តមសេនីយ៍ឯក ជីវ ផល្លី បញ្ជាក់ថា "អំពាវនាវដល់ពលរដ្ឋទាំងអស់ចូលរួមគោរពច្បាប់ទាំងអស់គ្នា។ ហើយមន្ត្រីអនុវត្តច្បាប់មិនលើកលែងទេ យើងត្រូវចាត់វិធានការម៉ឺងម៉ាត់ចំពោះអ្នកដែលប្រព្រឹត្តហិង្សាចូលដល់បទល្មើសព្រហ្មទណ្ឌ ហ្នឹងយើងមិនលើកលែងទេ។ សូមឲ្យគាត់ចូលរួមទាំងអស់ក្នុងការអនុវត្តច្បាប់"។

ជាមួយគ្នានោះលោក Felipe De La Torre អ្នកសម្របសម្រួលប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក នៃ UNODC ឲ្យដឹងដែរថា តាមរយៈយុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈនេះ មានគោលបំណងបញ្ជៀបចំណេះដឹង អំពីផលប៉ះពាល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រកើតឡើងក្នុងទីក្រុងភ្នំពេញ និងដើម្បីឲ្យប្រជាជនបានយល់ដឹងអំពីសេវាកម្មដែលមានសម្រាប់ជនរងគ្រោះ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ មិនត្រឹមតែប៉ះពាល់ដល់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងសង្គមរបស់សហគមន៍ផងដែរ។

លោកស្រី ស ស៊ីណែត អគ្គនាយិការងនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមនៃក្រសួងកិច្ចការនារី ឲ្យដឹងដែរថា អំពើហិង្សាលើស្ត្រី ក៏ជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានផលប៉ះពាល់ខ្លាំង ហើយច្រើនប៉ះពាល់ដល់អ្នកជុំវិញខ្លួន។ នៅពេលឪពុកម្តាយបង្កអំពើហិង្សាក្នុងក្រុមគ្រួសារ អ្នករងផលប៉ះពាល់មិនត្រឹមតែជនរងគ្រោះប៉ុណ្ណោះទេ គឺទៅដល់កូនៗរបស់គាត់ ។ នេះជារឿងមួយត្រូវយកចិត្តទុកដាក់។ លោកស្រីបន្តថា អំពើហិង្សាលើស្ត្រី ក៏ជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ មាន៤ប្រភេទ គឺហិង្សាផ្លូវកាយ , ផ្លូវចិត្ត , ផ្នែកជីវភាពសេដ្ឋកិច្ច ក៏ដូចជាអំពើហិង្សាលើផ្លូវភេទផងដែរ។ លោកស្រីថា "អំពើហិង្សាផ្លូវចិត្ត គឺជាឃាតកលាក់មុខមួយដែលធ្វើឲ្យជនរងគ្រោះស្លាប់ ដោយមិនបានបញ្ចេញភាពទុក្ខសោកយ៉ាងម៉េច" ។

បន្ថែមពីលើនេះ Dr Angelika Stauder លេខាទី១ និងជាអនុប្រធានផ្នែកសហប្រតិបត្តិការនៃស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំប្រទេសកម្ពុជា បានលើកឡើងថា មន្ត្រីនគរបាលតែម្នាក់ឯង មិនអាចដោះស្រាយអំពើហិង្សាលើស្ត្រី និងក្មេងស្រីបានទេ។ នេះជាបញ្ហាសង្គមដែលទាមទារឲ្យមានការឆ្លើយតបពីសង្គមទាំងមូល។ ប៉ុន្តែកម្លាំងនគរបាល គឺមានអំណាច និងការទទួលខុសត្រូវជាពិសេស នោះគឺជាការការពារជនរងគ្រោះពីហានិភ័យបន្ថែមទៀត ការតាមចាប់ជនល្មើស និងការទប់ស្កាត់ឧក្រិដ្ឋកម្មនានា។

ក្រោមកិច្ចសហការជាមួយមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ និងការិយាល័យសង្គមកិច្ច និងសុខុមាលភាពខណ្ឌ សហគមន៍ចំនួនប្រាំមួយ ស្ថិតក្នុងខណ្ឌចំនួន៣ក្នុងរាជធានីភ្នំពេញរួមមាន ៖ ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ ត្រូវបានរកឃើញថា ជាសហគមន៍កំពុងប្រឈមហានិភ័យខ្ពស់នឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ យុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈនេះ ផ្តោតលើក្រុមគោលដៅជាច្រើន ជាពិសេសស្ត្រីមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ។ យុទ្ធនាការនេះនឹងបានទៅដល់សាធារណៈជនតាមរយៈការផ្សព្វផ្សាយសារផ្សេងៗតាមប្រព័ន្ធអនឡាញ និងការបោះពុម្ព។

សូមជម្រាបថា លទ្ធផលបង្ក្រាបអំពើហិង្សាក្នុងគ្រួសារឆ្នាំ២០២១ មានចំនួន២៨៤ ករណី ឃាត់ខ្លួន ២៨៤ នាក់ (ស្រី១នាក់) កសាងសំណុំរឿងបញ្ជូនទៅតុលាការ សង្គ្រោះជនរងគ្រោះ ៣០១នាក់ បញ្ជូនទៅក្រុមគ្រួសារ៕

## ប្រុសស្រីជិត២០នាក់លួចចេញពីទឹកដីខ្មែរ ចូលដល់ទឹកដីថៃ ស្រាប់តែត្រូវទាហានថៃចាប់ខ្លួន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៤ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៣:៤៩

ខេត្តបន្ទាយមានជ័យ ៖ ប្រជាពលរដ្ឋខ្មែរប្រុស-ស្រីចំនួន១៩នាក់ ត្រូវបានទាហាន (ព្រាន) ឈុតខ្មៅថៃអនុសេនាធំ ១៣.០៥ ដែលប្រចាំការទល់មុខភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ បានឃាត់ខ្លួននៅវេលាម៉ោង០៥ទៀបភ្លឺ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ពីបទលួចឆ្លងដែនខុសច្បាប់ នៅត្រង់ចំណុចភូមិយុតហ៊ីន ឃុំក្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា តាមការឲ្យដឹងពីសមត្ថកិច្ចថៃ បានឲ្យដឹងថា កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានទទួលព័ត៌មានពីសមត្ថកិច្ចថៃ នៅវេលាម៉ោង០៥ទៀបភ្លឺឈានចូលថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ហើយទាហាន (ព្រាន) ឈុតខ្មៅថៃអនុសេនាធំ ១៣.០៥ ដែលប្រចាំការទល់មុខភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរដែលលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃចំនួន១៩នាក់ (ក្នុងនោះស្រី០៩នាក់ និងកុមារ០៤នាក់) នៅត្រង់ចំណុចភូមិយុតហ៊ីន ឃុំក្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ទល់មុខនឹងភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ លោកមេបញ្ជាការបានបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរទាំង១៩នាក់ខាងលើនោះ បន្ទាប់ពីសួរនាំ និងពិនិត្យកំដៅរួច ទាហាន (ព្រាន) ឈុតខ្មៅថៃ បានបញ្ជូនពួកគាត់ទៅអធិការដ្ឋាននគរបាលក្លងណាំសៃ ដើម្បីចាត់ការបន្តតាមនីតិវិធី ៕

## លោកឧត្តមសេនីយ៍ត្រី តេង ច័ន្ទណាត អញ្ជើញចូលរួមកម្មវិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ក្នុងតំបន់ស្តីពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ

(Children sexual Exploitation Regional Dialogue

https://gdlf-kh.com/ 2022/05/24/ Pich Ponlue សៀមរាប

សៀមរាប ៖ ព្រឹកថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹង ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ នៅសណ្ឋាគារសូហ្វីតែលអង្គរ ខេត្តសៀមរាប លោកឧត្តមសេនីយ៍ត្រី តេង ច័ន្ទណាត ស្នងការនគរបាលខេត្ត សៀមរាបបានអញ្ជើញចូលរួមកម្មវិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ក្នុងតំបន់ ស្តីពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ(Children sexual Exploitation Regional Dialogue) ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិលោកជំទាវ លីសា ហ្គេល អេភីអិម ឧបការីស្នងការនគរបាលសហព័ន្ធអូស្រ្តាលី លោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារ។ ក្នុងនោះដែរក៏មានការចូលរួមពីមន្ត្រីជាន់ខ្ពស់នៃនគរបាលអូស្រ្តាលី និងពីបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់៕

## ពលរដ្ឋខ្មែរសម្រុកទៅធ្វើបណ្ណចូលទៅធ្វើការលក់ដូរនៅថៃ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 24 May 2022 | 09:16 ICT

**បន្ទាយមានជ័យៈ** ក្នុងមួយថ្ងៃៗមានប្រជាពលរដ្ឋនៅតាមព្រំដែន ជាពិសេសពលករខ្មែរពី ៤០០ ទៅ ៥០០ នាក់បានទៅស្នើសុំធ្វើបណ្ណឆ្លងដែន ដើម្បីបានចូលទៅធ្វើការ ឬលក់ដូរស្របច្បាប់ នៅក្នុងប្រទេសថៃ បន្ទាប់ពីភាគីទាំង ២ បានឯកភាពគ្នាបើកច្រកព្រំដែនឡើងវិញ កាលពីថ្ងៃទី ១ ខែឧសភា ក្នុងកម្រិតថ្នាក់តំបន់។

អ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យលោក សេក សុខុម បានថ្លែងថា ពលករបានសម្រុកមកធ្វើបណ្ណឆ្លងដែនជាបន្តបន្ទាប់ ដោយក្នុងមួយថ្ងៃមានប្រហែល៥០០នាក់ ខណៈបណ្ណនេះធ្វើក្នុងតម្លៃប្រហែល ២ ម៉ឺនរៀល។ លោកថា៖ «ក្នុង ១ ថ្ងៃ ពលរដ្ឋគាត់សម្រុកមកធ្វើបណ្ណព្រំដែនកម្ពុជា-ថៃ ប្រហែលពី ៤០០ ទៅ ៥០០ បណ្ណ ជាពិសេសបងប្អូនពលករ និងអាជីវករ គាត់សម្រុកធ្វើបណ្ណនេះ ព្រោះបណ្ណនេះជាតម្រូវការចាំបាច់សម្រាប់ទៅធ្វើការ និងលក់ដូរក្នុងទឹកដីថៃ»។ បណ្ណនេះប្រើបានសម្រាប់តែអ្នកខេត្តជាប់ព្រំដែនប៉ុណ្ណោះ ដូចជាខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ ហើយខេត្តប៉ៃលិន និងខេត្តត្រាត ជាដើម ដើម្បីស្រួលដល់ការចេញចូលរវាងតំបន់ទាំង ២ នៅតាមខ្សែបន្ទាត់ព្រំដែន។ ពលរដ្ឋដែលមានបណ្ណនេះអាចមានសិទ្ធិចេញចូលនិងធ្វើការនៅប្រទេសថៃក្នុងកាលបរិច្ឆេទកំណត់មួយ ប៉ុន្តែក្នុងករណីពលករខ្មែរដែលទៅធ្វើការហួសថ្ងៃកំណត់នោះ ថៅកែជនជាតិថៃអាចបន្តពន្យារពេលសុពលភាពបណ្ណព្រំដែននោះបានទៅតាមតម្រូវការជាក់ស្តែង។ លោកឱ្យដឹងដែរថា ក្រោយពេលភាគីថ្នាក់ខេត្តបើកច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតឡើងវិញ ពលករលួចឆ្លងដែននៅតាមច្រករបៀងនៅតែមាន ប៉ុន្តែមិនច្រើនដូចកាលពីសម័យផ្ទុះជំងឺកូវីដ ១៩ ខ្លាំងនោះទេ។ លោកថា៖ «ច្រកព្រំដែនប៉ោយប៉ែតចេញចូលតែពលករដែលស្របច្បាប់ទេ ចំណែកពលករដែលគាត់រកទទួលទានដោយខុសច្បាប់គាត់នៅតែលួចចេញទៅតាមច្រករបៀងដដែល»។

ចំណែកអភិបាលស្រុកកំរៀង ខេត្តបាត់ដំបង លោក គឿន សត្យា ឱ្យដឹងដែរថា នាពេលបច្ចុប្បន្នថ្នាក់ខេត្តនៅបន្តអនុវត្តគោលការណ៍ចាស់ ដោយក្នុង ១ អាទិត្យ ថៃបើកឱ្យពលករយើងចូល ២ ថ្ងៃ ហើយមិនបើកជាចំហពេកទេ ទាល់តែមានលក្ខខណ្ឌដូចដែលខាងខេត្តបាត់ដំបង និងខេត្តចន្ទបុរីបានចុះអនុស្សរណៈជាមួយគ្នា។ លោកថា៖ «គឺទាល់តែមានបណ្ណចាក់វ៉ាក់សាំងយ៉ាងតិច ២ ដង ហើយមានបណ្ណព្រំដែន ហើយត្រូវមានថៅកែថៃមកទទួលពលករខ្មែរ ឧទាហរណ៍ ១ អាទិត្យថៅកែមកយកម្តងពី ១០០ ទៅ ២០០ នាក់»។ លោកបន្តថា ក្រៅពីនោះក្នុង ១ អាទិត្យ ថៅកៅថៃត្រូវយកបណ្ណព្រំដែននោះទៅពន្យារពេលនៅព្រំដែនដើម្បីបន្តសុពលភាព ខណៈលោកថាបើកាលពីមុនកូវីដ ១៩ បណ្ណព្រំដែនក្នុង ១ ក្បាលអាចពន្យារបាន ២ ឆ្នាំ ប៉ុន្តែឥឡូវនេះអាចពន្យារបានត្រឹម ១ ឆ្នាំប៉ុណ្ណោះ។ មួយវិញទៀត ក្រោយពីបើកព្រំដែនជិត ១ ខែមកនេះ ប្រជាពលរដ្ឋដែលរស់នៅតាមព្រំដែនអាចចេញ-ចូលបានធម្មតាដោយភ្ជាប់មកជាមួយបណ្ណព្រំដែន៕

# ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២

## រដ្ឋាភិបាលត្រូវធានាសុខុមាលភាពពលរដ្ឋខ្មែរធ្វើការនៅបរទេស

https://www.khmertimeskh.com/ ទិត្យ គង់នៅ / ខ្មែរថាមស៍ May 25, 2022

មន្ត្រីជាន់ខ្ពស់នៃគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស មានប្រសាសន៍ថា កម្ពុជាចាំបាច់ត្រូវដោះស្រាយបញ្ហាចំនួន៣ ដើម្បីធានាសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាដែលកំពុងធ្វើការនៅក្រៅប្រទេស។ ថ្លែងនៅក្នុងវេទិកាត្រួតពិនិត្យការធ្វើចំណាកស្រុកអន្តរជាតិរបស់អង្គការសហប្រជាជាតិ ដែលធ្វើឡើងនៅទីក្រុងញូវយ៉ក ពីថ្ងៃទី ១៧ ដល់ ២០ ឧសភា ដោយមានការចូលរួមពីប្រទេសចំនួន ១៩៥ មកពីជុំវិញពិភពលោក លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស បានអះអាងសារជាថ្មីនូវការប្តេជ្ញាចិត្តឥតងាករេរបស់រដ្ឋាភិបាលក្នុងការគាំទ្រការអនុវត្តកតិកាសញ្ញាសកល ដើម្បីការពារពលករចំណាកស្រុកពីការទទួលរងនូវការកេងប្រវ័ញ្ច អំពើហិង្សា ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ និងសូម្បីតែទាសភាព។

លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា កម្ពុជាជាប្រទេសដែលមានពលករចំណាកស្រុកជាងមួយលាននាក់ ដែលកំពុងធ្វើការនៅក្រៅប្រទេស។ អ៊ីចឹង បើយើងមិនការពារកម្មករ តើឲ្យការពារនរណាទៅ? លោកស្រីបន្ថែមថា ជនចំណាកស្រុកខ្មែរសព្វថ្ងៃ គឺជាជនដែលទៅធ្វើការដោយស្របច្បាប់ មិនមែនជាជនអន្តោប្រវេសន៍ទេ។ ឥឡូវនេះ មានបញ្ហា៣ដែលកម្ពុជាត្រូវធ្វើក្នុងនាមជាសមាជិកនៃវេទិកាត្រួតពិនិត្យការធ្វើចំណាកស្រុកអន្តរជាតិរបស់អង្គការសហប្រជាជាតិ។ ទី១ ការអនុវត្តគោលនយោបាយជាតិស្តីពីអន្តោប្រវេសន៍ដែលកម្ពុជាកំពុងធ្វើរួចហើយដឹកនាំដោយក្រសួងការងារ និងសុខាភិបាល។ ទី២ ការប្តេជ្ញាចិត្តដើម្បីផ្តល់អាទិភាពដល់ការប្រមូល និងការចងក្រងទិន្នន័យទាក់ទងនឹងការធ្វើចំណាកស្រុក។ ជាញឹកញាប់ទិន្នន័យដែលបានចងក្រង និង ទទួលបានពីបរទេសមិនមានភាពត្រឹមត្រូវទេ។ ប្រទេសគោលដៅជារឿយៗមិនមានទិន្នន័យរបស់កម្មករដែលចាកចេញ និងអ្នកដែលធ្វើការខុសច្បាប់។ លោកស្រីបានស្នើថា ការគ្រប់គ្រងព្រំដែនរួម និង កិច្ចសហប្រតិបត្តិការរវាងប្រទេសដែលពាក់ព័ន្ធនឹងជួយក្នុងបញ្ហានេះ។ អ្នកស្រីបន្តថា ទី៣ ការការពារសិទ្ធិកុមារដោយសារឪពុកម្តាយជនចំណាកស្រុកខកខានមិនបានចុះឈ្មោះទារកទើបកើតនៅក្នុងប្រទេសកំណើតរបស់ពួកគេ។

ជាមួយគ្នានេះ នាយកកម្មវិធីមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស លោក យុន ថារ៉ូ បាននិយាយកាលពីម្សិលមិញថា ប្រជាជនកម្ពុជាដែលធ្វើការនៅបរទេសត្រូវការបទប្បញ្ញត្តិដែលការពារសិទ្ធិការងាររបស់ពួកគេ និងដោះស្រាយវិវាទដែលកើតឡើងរវាងនិយោជិត និងនិយោជក។ លោកបន្ថែមថា ដោយសារពលករចំណាកស្រុកមិនមានសិទ្ធិពេញលេញក្នុងការប្រកួតប្រជែងការបញ្ចប់អត្ថប្រយោជន៍សេវាក្នុងប្រទេសក្រៅ អន្តរាគមន៍ពីអង្គការសង្គមស៊ីវិល ឬប្រព័ន្ធគាំទ្រផ្នែកច្បាប់ណាមួយពីកម្ពុជាគួរតែត្រូវបានផ្តល់ដល់ពួកគេ។ លោកក៏បាននិយាយដែរថា រដ្ឋាភិបាលកំពុងព្យាយាមកែតម្រូវថ្លៃសេវាមួយចំនួន រួមទាំងឯកសារ និងការចុះបញ្ជី។ លោកក៏បានអំពាវនាវឱ្យមានរបបសន្តិសុខសង្គមដែលអាចធានាសុវត្ថិភាព សុខភាព ការស្នាក់នៅ និងទប់ស្កាត់ការរំលោភបំពានពីនិយោជកផងដែរ។ បច្ចុប្បន្ននេះ កម្ពុជាមានពលករទៅក្រៅប្រទេសសរុបចំនួន ១៣០១៦០៩នាក់ នៅក្នុងប្រទេសចំនួន៧ ដូចដែលបានបង្ហាញក្នុងពិធីអបអរសាទរទិវាពលកម្មអន្តរជាតិ ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន៕

## ពលករខ្មែរម្នាក់ ជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប់ ខណៈជិះម៉ូតូបុកទ្រូងផ្លូវនៅស្រុកថៃ ត្រូវកម្លាំងសមត្ថកិច្ចបញ្ជូនមកស្រុកខ្មែរវិញ

https://www.kampucheathmey.com/ 25/05/2022

ហេតុការណ៍គ្រោះថ្នាក់នេះកើតឡើង វេលាម៉ោង ៤ ល្ងាច កាលពីថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២២ អាជ្ញាធរថៃបានប្រាប់សមត្ថកិច្ចខ្មែរប្រចាំនៅច្រកអូរបីជាន់ថា សពពលរដ្ឋខ្មែរនេះ មានឈ្មោះ សៅ រស្មី ភេទប្រុស អាយុ ២៩ ឆ្នាំ រស់នៅភូមិអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ សមត្ថកិច្ចថៃបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ពេលកើតហេតុនោះសពជនរងគ្រោះបានជិះម៉ូតូយ៉ាងលឿនមកដល់ចំណុចស្រុកផាត់តាយ៉ា ខេត្តឈុនបុរីប្រទេសថៃ ស្រាប់តែបើកទៅបុកទ្រូងផ្លូវជាតិបណ្តាលឲ្យម៉ូតូជ្ជលបោកទៅនិងថ្នល់ជាតិបាក់.ក ស្លាប់ភ្លាមៗតែម្តង។ ក្រោយកើតហេតុសមត្ថកិច្ចថៃ បានបញ្ជូនសាកសពពលរដ្ឋខ្មែរដឹកតាមរថយន្តចេញតាមច្រកអូរបីជាន់ ដើម្បីប្រគល់ឲ្យទៅក្រុមគ្រួសារយកទៅធ្វើបុណ្យតាមប្រពៃណី នៅភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ តែម្តង៕ **វ៉ាន់ណាង**

# ទាហានថៃឃាត់ខ្មែរម្នាក់ខណៈចូលលួចកាត់ឈើ២ដុំ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៥ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១០:១៦

ខេត្តបន្ទាយមានជ័យ ៖ បុរសជនជាតិខ្មែរម្នាក់បត្រូវបានទាហានថៃឃាត់ខ្លួនក្នុងករណីចូលលួចកា.ប់ឈើចំនួន២ដុំនៅក្នុងទឹកដីថៃ ហើយត្រូវបានបញ្ជូនតុលាការ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ស្ថិតនៅភូមិសាស្ត្រភូមិសូន្យសាម ឃុំថាប់ថៃ ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ។

មន្ត្រីទំនាក់ទំនងកម្ពុជា-ថៃបានប្រាប់ថា ពលរដ្ឋខ្មែរដែលត្រូវទាហានថៃឃាត់មានឈ្មោះ ហេង វណ្ណា ហៅតុល ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅភូមិដងរ៉ែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ។ មន្ត្រីរូបនោះបានបញ្ជាក់ថា នៅពេលដែលទាហានថៃឃាត់គឺបានចោទប្រកាន់ពីបទលួចចូលកាប់ឈើតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ ត្រង់ចំណុចភូមិសូន្យសាម ឃុំថាប់ថៃ ស្រុកតាប្រាយ៉ា ខេត្តស្រះកែវប្រទេសថៃ ដែលឈមក្នុងកម្ពុជាភូមិដងរ៉ែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ។ មន្ត្រីទំនាក់ទំនងកម្ពុជា-ថៃបានបញ្ជាក់ថា នៅពេលទាហានថៃឃាត់ពលរដ្ឋខ្មែរម្នាក់ឈ្មោះ ហេង វណ្ណា ហៅតុល មានឈើ២កំណាត់ និងរណារដៃ១ ក្រោយទាហានថៃឃាត់មន្ត្រីទំនាក់ទំនងកម្ពុជា-ថៃ និងអាជ្ញាធរជាប់ជាយដែនបានស្នើសុំទៅទាហានភាគីថៃថា បញ្ជូនទៅតុលាការខេត្តស្រះកែវប្រទេសថៃ ធ្វើការអប់រំរយៈពេល១សប្តាហ៍សិន ទើបអោយត្រឡប់មកស្រុកកំណើតវិញ៕

# ជប៉ុនចាប់ផ្តើមធ្វើតេស្តជំនាញពលករខ្មែរ នៅធ្វើការនៅប្រទេសជប៉ុន

https://www.kampucheathmey.com/ ថ្ងៃពុធ ២៥ ឧសភា ២០២២ដោយ Dy Bunnara

រាជរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមអនុញ្ញាតឱ្យធ្វើតេស្តជំនាញនិងភាសាជប៉ុនសម្រាប់ពលករខ្មែរជំនាញផ្នែកកសិកម្មនិងសេវាកម្ម ដើម្បីបញ្ជូនទៅធ្វើការនៅប្រទេសជប៉ុននាពេលខាងមុខនេះ។

លោក អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងនៅក្នុងសេចក្តីជូនដំណឹងមួយចុះថ្ងៃទី ២៥ ឧសភានេះថា តាមសេចក្តីជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញឱ្យបានជ្រាបថាអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញនិងតេស្តភាសាជប៉ុននឹងរៀបចំការធ្វើតេស្តភាសានិងតេស្តជំនាញតាមរយៈប្រព័ន្ធកុំព្យូទ័រ។ លោករដ្ឋមន្ត្រីបានបន្តថា ប្រភេទតេស្តផ្នែកកសិកម្មនឹងធ្វើនៅសាកលវិទ្យាល័យអន្តរជាតិប៊ែលធីសាខាទួលស្លែងនៅថ្ងៃទី ២៧ ដល់ថ្ងៃទី២៩ ខែឧសភាឆ្នាំ២០២២។ ថ្ងៃទី ១៥ ដល់ថ្ងៃទី ១៧ ខែមិថុនា នៅថ្ងៃទី១៦កក្កដាថ្ងៃទី២០កក្កដា និងថ្ងៃទី ២៦កក្កដាឆ្នាំ ២០២២។

ចំពោះផ្នែកការងារនៅភោជនីយដ្ឋានវិញ នឹងធ្វើនៅវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំដែលមានអាសយដ្ឋាននៅសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញដោយធ្វើតេស្តនៅថ្ងៃទី១៥ដល់ថ្ងៃទី១៧ខែមិថុនាថ្ងៃទី ១៦ កក្កដាថ្ងៃទី ២០កក្កដានិងថ្ងៃទី២៦កក្កដាឆ្នាំ២០២២។

ចំពោះការចុះឈ្មោះធ្វើតេស្តជំនាញ និងភាសាជប៉ុន បេក្ខជនត្រូវបង់ប្រាក់តម្លៃ ៣៣ ដុល្លារអាមេរិកដោយបេក្ខជនមានអាយុចាប់ពី ១៧ ឆ្នាំឡើងទៅ ដោយមិនគិតពីមក្រិតវប្បធម៌ឡើយ និងត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជាអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ។

លោករដ្ឋមន្ត្រីបានបញ្ជាក់ថា ការបរិច្ឆេទនៃការធ្វើតេស្តនេះអាចនឹងផ្លាស់ប្តូរអាស្រ័យទៅលើស្ថានភាពជំងឺកូវីដ១៩។ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បច្ចុប្បន្ននេះមានពលករខ្មែរប្រមាណជាង ១លាន២សែននាក់ធ្វើការនៅក្រៅប្រទេស ក្នុងនោះមានពលករចំនួន១១,៤៥៣ នាក់ធ្វើការនៅប្រទេសជប៉ុន៕ សំអឿន

## ពលករខុសច្បាប់ត្រូវប្រុងប្រយ័ត្នអ្នកជួញដូរមនុស្ស

https://www.khmertimeskh.com/ ណាង វាសនា / ខ្មែរថាមស៍ May 26, 2022

អ្នកនេសាទងាយរងគ្រោះដោយការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម បានកើតឡើងដោយសារពួកគេខ្វះព័ត៌មានអំពីការក្លាយជាពលករចំណាកស្រុក។ អ្នកនេសាទចំនួន៤នាក់ ដែលឆ្លងកាត់ការលំបាកយ៉ាងខ្លាំង បានចែករំលែកទុក្ខលំបាករបស់ខ្លួនជាមួយកាសែតខ្មែរថាមស៍។ ម្នាក់ក្នុងចំណោមពួកគេ បានរៀបរាប់អំពីរឿងញាក់សាច់ នៃការរត់គេចខ្លួន ពីឈ្មួញកណ្តាល។ ហើយអកុសលបំផុតក្នុងចំណោមពួកគេ ត្រូវត្រឡប់មកប្រទេសកម្ពុជាវិញដោយដៃទទេ បន្ទាប់ពីធ្វើការអស់រយៈពេល ១១ ឆ្នាំនៅបរទេស។

លោក នី នល អាយុ ៥៧ ឆ្នាំ អតីតពលករចំណាកស្រុក បាននិយាយថា៖«ខ្ញុំធ្វើការជាអ្នកនេសាទបាន១ឆ្នាំ ហើយនោះគឺជាថ្ងៃដេកមិនលក់។ ខ្ញុំត្រូវបានគេអនុញ្ញាតឱ្យគេងតែ២ ឬ៣ម៉ោងប៉ុណ្ណោះ។ ដោយសារខ្ញុំជាកម្មករខុសច្បាប់ គេបង្ខំខ្ញុំឲ្យធ្វើការថែមម៉ោង»។ លោកបន្តថា ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានសំណាងណាស់ ដែលខ្ញុំមិនដែលមានបញ្ហាប្រាក់ខែ។ ខ្ញុំស្គាល់កម្មករខុសច្បាប់មួយចំនួន ដែលតែងតែធ្វើការថែមម៉ោង។ អ្នកនេសាទមិនអាចគេចខ្លួនបានទេ ដោយសារពួកគេតែងតែនៅលើសមុទ្រ ហើយពេលខ្លះ ពួកគេភាគច្រើនមិនមានលុយត្រឡប់ទៅផ្ទះវិញ។ ខ្ញុំក៏ធ្លាប់ធ្វើការជាកម្មករសំណង់ជាង២០ឆ្នាំផងដែរ។ លោកបន្ថែមថា ខ្ញុំចង់ប្រាប់រឿងមួយថា អ្នកដែលស្វែងរកការងារនៅបរទេស សូមទៅដោយស្របច្បាប់។ ការធ្វើចំណាកស្រុកខុសច្បាប់នឹងមានភាពងាយស្រួល ប៉ុន្តែវាអាចធ្វើឱ្យអ្នកមានបញ្ហាធំៗដូចជា ការងារលើសទម្ងន់ ការរំលោភលើការងារ និង ការជួញដូរមនុស្ស។

លោក ប៉ាវ ព្រិច អាយុ ៥៤ ឆ្នាំ ជាអ្នកនេសាទម្នាក់ទៀតបាននិយាយថា គាត់បានសម្រេចចិត្តទៅប្រទេសថៃក្នុងឆ្នាំ ១៩៩៥ ដោយសារជីវភាពក្រីក្រ។ លោកបាននិយាយថា៖«ខ្ញុំបានបង់ប្រាក់ចំនួន៣៥០០បាតទៅឱ្យឈ្មួញកណ្តាល ដែលជាប្រាក់ដែលឪពុកម្តាយរបស់ខ្ញុំបានផ្តល់ឱ្យខ្ញុំ បន្ទាប់ពីខ្ចីពីអ្នកជិតខាង និងលក់គ្រឿងអលង្ការ»។ លោកបន្តថា ការងារដំបូងរបស់ខ្ញុំគឺកម្មករសំណង់។ ខ្ញុំមានមិត្តម្នាក់នៅទីនោះ ដែលបានណែនាំឱ្យខ្ញុំផ្លាស់ប្តូរការងារ ដោយសារកម្មករសំណង់ទទួលបានប្រាក់ខែតិច។ គាត់ធ្វើការជាអ្នកនេសាទ ហើយសុំខ្ញុំធ្វើជាអ្នកនេសាទដែរ។ ខ្ញុំធ្វើការជាងមួយឆ្នាំកន្លះក្នុងនាមជាអ្នកនេសាទ ហើយវាលំបាកខ្លាំងណាស់ ព្រោះជាធម្មតា ពលករខ្មែរត្រូវបានកម្មករថៃធ្វើបាប។ យើងត្រូវបានគេអនុញ្ញាតឱ្យគេងតែ១ឬ២ម៉ោងប៉ុណ្ណោះ ហើយនៅខែមីនា ខែកញ្ញា និងខែធ្នូ អត់បានដេកទាល់តែសោះ។ លោកបន្ថែមថា ហើយនៅឆ្នាំ២០០៨ ខ្ញុំបានជួបមេខ្យល់ម្នាក់ដែលសន្យាផ្តល់ការងារឱ្យខ្ញុំ និង ៦ នាក់ទៀតនៅប្រទេសថៃម្តងទៀត។ នៅតាមផ្លូវ យើងកំពុងញ៉ាំអាហារនៅស្ថានីយ៍រថភ្លើង។ ខ្ញុំបានឮមេខ្យល់ និងថៅកែថៃចរចាគ្នាពីតម្លៃក្រុមខ្ញុំ។ មេខ្យល់ចង់បាន ១៥.០០០ បាតក្នុងម្នាក់រយៈពេល ៣ ខែ ប៉ុន្តែថៅកែថៃឲ្យតែ ១០.០០០ បាតក្នុងម្នាក់។ ខ្ញុំរន្ធត់ចិត្តជាខ្លាំង នៅពេលឮការចរចានេះ។ អ្នកខ្លះទៀតមិនបានយកចិត្តទុកដាក់ទេ ពីព្រោះមិនសូវចេះភាសាថៃ។ ភ្លាមៗនោះ ខ្ញុំលែងហូបបាយ ហើយបានជូនដំណឹងដល់មិត្តរួមក្រុមអំពីផែនការរបស់មេខ្យល់ក្នុងការលក់យើងទៅបុរសជនជាតិថៃនោះ។ ខ្ញុំបានប្រាប់ពួកគេថា ខ្ញុំនឹងរត់គេច ហើយអ្នកណាក៏អាចចូលរួមជាមួយខ្ញុំបានដែរ។ គ្រប់គ្នាបានឈរជាមួយខ្ញុំ ហើយយើងបានរត់ចេញពីទីនោះ។ ហើយខ្ញុំបាននាំពួកគេទៅជួបថៅកែមុន របស់ខ្ញុំ។ ថៅកែមុនរបស់ខ្ញុំនៅតែស្គាល់ខ្ញុំ ហើយបានផ្តល់ការងារដល់យើងទាំងអស់គ្នា។ ខ្ញុំបានក្លាយជាអ្នកនេសាទ ហើយរយៈពេល៣ខែ យើងនៅលើសមុទ្រ។ ពេលវេលាត្រឡប់ទៅដីគោក

មកដល់ ថៅកែខ្ញុំសួរថា មានអ្នកណាចង់ត្រឡប់ទៅផ្ទះវិញទេ ខ្ញុំក៏ឆ្លើយថាបាទ។ ដូច្នេះហើយបានជាខ្ញុំអាចត្រឡប់មកកម្ពុជាវិញ ហើយឥឡូវ ខ្ញុំជាកសិករ។ លោកបន្ថែមថា៖«ខ្ញុំចង់ប្រាប់អ្នករាល់គ្នាក្នុងសហគមន៍ ជាពិសេសយុវជនថា ប្រសិនបើអ្នកមានគម្រោងធ្វើចំណាកស្រុក សូមគិតឲ្យបានត្រឹមត្រូវ។ ត្រូវប្រាកដថា អ្នកមានឯកសារផ្លូវការតាមច្បាប់ដើម្បីទៅប្រទេសថៃ ឬប្រទេសផ្សេងទៀត»។

លោក សាន នៅ អាយុ ៣១ ឆ្នាំ ជាអតីតជនចំណាកស្រុកខុសច្បាប់ម្នាក់ទៀតបាននិយាយថា៖«ខ្ញុំបានចំណាយពេលប្រហែល ១១ ឆ្នាំនៅក្នុងប្រទេសថៃ។ ខ្ញុំមិនចាំច្បាស់ទេ។ ខ្ញុំធ្វើការជាអ្នកនេសាទ និងជាជនចំណាកស្រុកខុសច្បាប់ ជីវិតលំបាកខ្លាំងណាស់ ព្រោះខ្ញុំមិនអាចទៅណាបាន ហើយត្រូវធ្វើការក្រោមការភ័យខ្លាច»។ លោកបន្តថា ខ្ញុំនៅតែមិនអាចបំភ្លេចរឿងនោះ។ ខ្ញុំត្រូវបានគេផ្តល់កន្លែងតូចចង្អៀតសម្រាប់គេង ដែលមិនអាចអង្គុយបានត្រឹមត្រូវ។ ក្នុងរដូវវស្សា ម្ចាស់កប៉ាល់មិនដែលអនុញ្ញាតឱ្យខ្ញុំគេងទេ។ គាត់ធ្លាប់ដាស់ខ្ញុំឲ្យភ្ញាក់ ធ្វើការក្នុងពេលងងឹត។ លោកបន្ថែមថា បន្ទាប់មក រឿងអកុសលបំផុតបានកើតឡើងចំពោះខ្ញុំ។ ថ្ងៃមួយ ខ្ញុំត្រូវបានប៉ូលីសថៃចាប់ខ្លួន ហើយពួកគេបញ្ជូនខ្ញុំទៅឃុំឃាំង។ មួយសប្តាហ៍ក្រោយមក ពួកគេបានបញ្ជូនខ្ញុំមកកម្ពុជាវិញ។ ខ្ញុំសល់ដៃទទេ ពីព្រោះថៅកែថៃមិនបើកប្រាក់ខែឲ្យខ្ញុំឡើយ។ ខ្ញុំសល់តែក្រមានៅលើស្មា នៅពេលខ្ញុំត្រូវបាននិរទេស។ ខ្ញុំបានជួលកង់នៅព្រំដែន ហើយខ្ញុំត្រូវសុំលុយពីឪពុកម្តាយដើម្បីបង់ថ្លៃកង់។

ចំពោះការផ្តល់ជំនួយសង្គ្រោះដល់ពលករចំណាកស្រុកខុសច្បាប់ដូចអ្នកនេសាទទាំងនេះ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងមនុស្សជាតិ (CENTRAL) សហការជាមួយអង្គការអន្តរជាតិខាងការងារ បានបើកមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍នៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៣ ខែឧសភា។ មជ្ឈមណ្ឌលនេះ បានផ្តល់សេវាឥតគិតថ្លៃដល់ពលករចំណាកស្រុក និង ជនរងគ្រោះនៃការជួញដូរមនុស្ស។ ដោយឡែក ការរៀបចំសិក្ខាសាលាសម្រាប់ពលករចំណាកស្រុក គឺដើម្បីឲ្យពួកគេជួប និងផ្លាស់ប្តូរបទពិសោធន៍ និងជាកន្លែងសម្រាប់បណ្តាញទំនាក់ទំនងផងដែរ៕

## សមត្ថកិច្ចបញ្ជូន
## ស្ត្រីដែលប្រើអំពើហិង្សាលើកូនស្រីចិញ្ចឹមរបស់ខ្លួន ឱ្យរបួសពេញខ្លួនទៅតុលាការ

http://freshnewsasia.com/ 2022-05-26 03:24pm

**(ភ្នំពេញ)៖** នគរបាលខណ្ឌទួលគោក រាជធានីភ្នំពេញ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២នេះ បានបញ្ជូនស្ត្រីដែលបានប្រើប្រាស់អំពើហិង្សាមកលើកូនស្រីចិញ្ចឹមរបស់ខ្លួនឱ្យរបួសពេញខ្លួន ទៅតុលាការចាត់ការបន្តតាមនីតិវិធីច្បាប់។ នេះបើតាមលោកវរសេនីយ៍ឯក សាន សុខសីហា អ្នកនាំពាក្យស្នងការនគរបាលរាជធានីភ្នំពេញ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។

សូមជម្រាបថា ស្ត្រីជាម្តាយចិញ្ចឹមដែលបានប្រើប្រាស់អំពើហិង្សាមកលើកូនស្រីចិញ្ចឹមរបស់ខ្លួន កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ នៅចំណុចមុខផ្ទះលេខ១៣Eo ផ្លូវលេខ២១៩ ក្រុមទី២២ ភូមិ០៣ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ជនសង្ស័យដែលត្រូវជាម្តាយចិញ្ចឹមឈ្មោះ ចាន់ ធីតា ហៅ ធីតា អាយុ៣៧ឆ្នាំ មុខរបរ លក់កាហ្វេ ស្នាក់នៅផ្ទះលេខ១៣Eo ផ្លូវលេខ២១៩ ក្រុមទី២២ ភូមិ០៣ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ដោយឡែកម្តាយចិញ្ចឹមជាជនសង្ស័យនោះឈ្មោះ កេង សុភា អាយុ៣៦ឆ្នាំ មុខរបរនៅផ្ទះ ស្នាក់នៅផ្ទះជួល ផ្លូវលំ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ចំណែកក្មេងស្រីរងគ្រោះ សមត្ថកិច្ចបានប្រគល់ជូនមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ និងមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ដើម្បីបញ្ជូនក្មេងស្រីរងគ្រោះទៅព្យាបាលនៅមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ ក្រោមការថែទាំជាបណ្តោះសន្ទរបស់អង្គការមិត្តសំឡាញ់៕

# ប្រទេសថៃនិយាយថា
# រដ្ឋាភិបាលក្រុងវ៉ាស៊ីនតោនគួរចាត់ទុកការជួញដូរមនុស្សជាបញ្ហាក្នុងតំបន់

https://www.khmertimeskh.com/ Khmer Times May 25, 2022

ប្រទេសថៃបានជំរុញឱ្យមន្ត្រីសហរដ្ឋអាមេរិកកុំកំណត់គោលដៅប្រទេសនីមួយៗនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនអំពីការជួញដូរមនុស្ស (TIP) ដោយកត់សម្គាល់ថា ទីក្រុងវ៉ាស៊ីនតោនគួរតែចាត់ទុកបញ្ហានេះជាបញ្ហាក្នុងតំបន់។

ឧត្តមសេនីយ៍ទោ Surachat Hakparn ជំនួយការអគ្គស្នងការនគរបាលជាតិ បាននិយាយកាលពីម្សិលមិញថាគណៈប្រតិភូថៃដឹកនាំដោយ Chettaphan Maksamphan អគ្គនាយកនៃនាយកដ្ឋានកិច្ចការអាមេរិកនិងប៉ាស៊ីហ្វិកខាងត្បូងបានជួបជាមួយមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកនៅទីក្រុងវ៉ាស៊ីនតោនពីថ្ងៃទី ១៥-១៨ ខែឧសភា នៅមុនការចេញផ្សាយរបាយការណ៍ TIP ឆ្នាំ២០២២ ដែលបានគ្រោងទុកនឹងបញ្ចេញនៅខែក្រោយ។ លោកបានបន្តថា ក្នុងជំនួបនោះ ប្រតិភូថៃបានស្នើឲ្យមន្ត្រីអាមេរិក ពិចារណាលើបញ្ហាជួញដូរមនុស្សជាបញ្ហាក្នុងតំបន់ ព្រោះបញ្ហានេះពាក់ព័ន្ធនឹងប្រទេសជាច្រើន។ ពួកគេក៏បានកត់សម្គាល់ផងដែរថា ប្រទេសថៃមិនមែនជាប្រទេសដើម ឬជាប្រទេសគោលដៅសម្រាប់ការជួញដូរមនុស្ស ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ TIP ពីមុននោះទេ។

ឧត្តមសេនីយ៍ទោ Surachat ដែលជាអ្នកទទួលបន្ទុកលើប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស បាននិយាយថាបញ្ហានេះមិនគួរត្រូវបានស្តីបន្ទោសលើប្រទេសជាក់លាក់ណាមួយនោះទេ។ លោកបានបន្តថា៖ « ប្រទេសថៃគ្រាន់តែជាចំណុចឆ្លងកាត់ប៉ុណ្ណោះ ហើយរដ្ឋាភិបាលថៃបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបង្ក្រាបការជួញដូរមនុស្ស»។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ គណៈប្រតិភូថៃក៏បានរាយការណ៍ព័ត៌មានថ្មីៗដល់មន្ត្រីសហរដ្ឋអាមេរិកអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយការជួញដូរមនុស្ស រួមទាំងការកាត់ទោសជនសង្ស័យ និងការផ្តល់ជំនួយដល់ជនរងគ្រោះផងដែរ។ ឧត្តមសេនីយ៍ទោ Surachat បាននិយាយថា ប្រទេសថៃបានឃើញការកើនឡើងយ៉ាងខ្លាំងនៃករណីជួញដូរមនុស្សនៅចន្លោះខែតុលាឆ្នាំមុន និងខែនេះ ដោយមានករណីជួញដូរចំនួន ១៩៣ ករណី និង ២០០ ករណីពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ។ លោកបានកត់សម្គាល់ថា ទ្រព្យសម្បត្តិដែលទាក់ទងនឹងការជួញដូរដែលមានតម្លៃ ១៤២ លានបាតត្រូវបានរឹបអូសក្នុងអំឡុងពេលនោះ។

ឧត្តមសេនីយ៍ទោ Surachat បានបន្តទៀតថា អាជ្ញាធរសហរដ្ឋអាមេរិកបានសម្តែងការពេញចិត្តចំពោះការបង្ក្រាបការជួញដូរមនុស្សរបស់ប្រទេសថៃ ជាពិសេសការជួយសង្គ្រោះមនុស្សចំនួន ២០០ នាក់ ដែលបានលួចទៅធ្វើការដោយខុសច្បាប់នៅក្នុងប្រទេសកម្ពុជា។ លោកបាននិយាយថា មន្ត្រីសហរដ្ឋអាមេរិកក៏បានផ្តល់អនុសាសន៍មួយចំនួន រួមទាំងការបង្កើតកិច្ចសហការកាន់តែជិតស្និទ្ធរវាងភ្នាក់ងារដែលពាក់ព័ន្ធក្នុងការផ្តល់ជំនួយដល់ជនរងគ្រោះពីការជួញដូរ ការរឹតបន្តឹងការអនុវត្តច្បាប់ និងការបង្កើនការបង្ក្រាបប្រឆាំងនឹងមន្ត្រីរដ្ឋដែលឃុបឃិតក្នុងការជួញដូរមនុស្ស។ លោកបាននិយាយថា សហរដ្ឋអាមេរិកក៏បានស្នើឱ្យប្រទេសថៃដាក់ឯកសារលើប្រធានបទចំនួន៦ រួមទាំងចំនួនជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះ និងព័ត៌មានលម្អិតរបស់វា។

ប្រទេសថៃត្រូវបានគេទម្លាក់ទៅក្នុងតារាងឃ្លាំមើលលំដាប់ទី២ ក្នុងរបាយការណ៍ TIP កាលពីឆ្នាំមុន។ រដ្ឋាភិបាលសង្ឃឹមថាវានឹងត្រូវបានធ្វើឱ្យប្រសើរឡើងនៅឆ្នាំនេះសម្រាប់ការដោះស្រាយបញ្ហា ដែលបានលើកឡើងនៅក្នុងរបាយការណ៍កាលពីឆ្នាំមុន។ Bangkokpost

# ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

## ឃុំខ្លួនស្ត្រីម្នាក់ ពាក់ព័ន្ធនឹងការប្រើអំពើហិង្សាវាយទៅលើកូនស្រីចិញ្ចឹមអាយុ៥ ឆ្នាំ

https://cen.com.kh/ Posted ByPen Srey NeatMay 27, 2022

ភ្នំពេញ ៖ ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២២នេះ បានបង្គាប់ឲ្យឃុំខ្លួន ត្រូវចោទស្ត្រីម្នាក់ និង បញ្ជូនទៅឃុំខ្លួន នៅក្នុងពន្ធនាគារ ជាបណ្តោះអាសន្ន ដើម្បីរង់ចាំចាត់ការ តាមផ្លូវច្បាប់ ជាប់ពាក់ព័ន្ធនឹងការ ប្រើហិ.ង្សាវា.យទៅលើកូនស្រីចិញ្ចឹមអាយុ៥ ឆ្នាំ ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ១៣Eo ផ្លូវលេខ ២១៩ ក្រុមទី២២ ភូមិ៣សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២២ ។

យោងតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នរបស់តុលាការដំបូងរាជធានីភ្នំពេញបានឱ្យដឹងថា ស្ត្រីត្រូវចោទម្នាក់នេះមានឈ្មោះ ចាន់ ធីតា ហៅ ធីតា ភេទស្រី អាយុ ៣៧ ឆ្នាំ មុខរបរលក់កាហ្វេ មានទីលំនៅផ្ទះលេខ ១៣Eo ផ្លូវលេខ ២១៩ ក្រុមទី ២២ ភូមិ៣ សង្កាត់ផ្សារដេប៉ូទី ១ ខណ្ឌទួលគោក ។ ចំណែកកុមារីរងគ្រោះ អាយុ ៥ ឆ្នាំ មានម្តាយង្កើត ឈ្មោះ កេង សុភា ភេទស្រី អាយុ ៣៦ ឆ្នាំ មុខរបរនៅផ្ទះស្នាក់នៅផ្ទះជួល ផ្លូវលំ ភូមិឫស្សីសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ ឈ្មោះ ចាន់ ធីតា ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ ″ ហិ.ង្សាដោយចេតនា មានស្ថានទម្ងន់ទោស ″ និង ត្រូវបានសមត្ថកិច្ចនគរបាលចាប់ខ្លួន កាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២២ នៅសង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## ម្តាយជនជាតិម៉ាឡេស៊ីរិះគន់អាជ្ញាធរកម្ពុជាដោយចោទថាបានលាតត្រដាងព័ត៌មានលម្អិតអំពីកូនប្រុសដែលគេបង្ខាំង

https://www.khmertimeskh.com/ Khmer Times May 29, 2022

ម្តាយជនជាតិម៉ាឡេស៊ីម្នាក់ ដែលអះអាងថា កូនប្រុសរបស់គាត់ត្រូវបានចាប់បង្ខាំងខ្លួន ដោយក្រុមបោកប្រាស់នៅក្នុងកម្ពុជា បានចោទប្រកាន់អាជ្ញាធរនៅទីនេះថា បានបែកធ្លាយព័ត៌មានទាក់ទងនឹងទីកន្លែងរបស់កូនប្រុសគាត់ទៅកាន់ក្រុមឧក្រិដ្ឋជន ដែលចោទប្រកាន់ថា បានល្បួងគាត់នៅទីនោះតាមរយៈការឆបោកនៃការផ្តល់ការងារ។ អ្នកស្រី Wong អះអាងថា កូនប្រុសរបស់គាត់ត្រូវបានល្បួងមកកម្ពុជាកាលពី ៧ ខែមុន ហើយបានប្រាប់គាត់ថាគាត់ជាប់នៅទីនោះ ហើយនិយាយថា ក្តីសង្ឃឹមតែមួយគត់របស់គាត់គឺត្រូវសងប្រាក់ចំនួន ១៣,០០០ ដុល្លារ ដើម្បីដោះលែងកូនប្រុសគាត់ ដែលជាចំនួនដែលគាត់និយាយថា គាត់មិនអាចមានលទ្ធភាពនោះទេ។ អ្នកស្រីបាននិយាយថា ការខិតខំប្រឹងប្រែងដើម្បីជួយសង្គ្រោះគាត់រហូតមកដល់ពេលនេះបានបរាជ័យ បើទោះជាអ្នកស្រីបានផ្តល់ព័ត៌មានដ៏មានតម្លៃដល់អាជ្ញាធរក៏ដោយ។ គាត់បានពន្យល់ថា គាត់បានទទួលព័ត៌មានអំពីទីកន្លែងរបស់កូនប្រុសគាត់ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់អ្នកជួយ និងពីអ្វីដែលកូនប្រុសរបស់គាត់បាននិយាយនៅក្នុងការហៅទូរស័ព្ទសម្ងាត់ ប៉ុន្តែបដិសេធមិនផ្តល់ព័ត៌មានថា តើអ្នកណាជាអ្នកជួយនោះទេ។ គាត់បានផ្តល់ព័ត៌មានលម្អិតទៅស្ថានទូតម៉ាឡេស៊ីនៅភ្នំពេញ ដែលគេជឿថាបានបញ្ជូនព័ត៌មានទៅនគរបាលកម្ពុជា។

អ្នកស្រី Wong បានប្រាប់ FMT ដែលជាវិបផតថលព័ត៌មានអនឡាញរបស់ប្រទេសម៉ាឡេស៊ីថា "ទោះជាយ៉ាងនេះក្តី ការភ្ញាក់ផ្អើលរបស់ខ្ញុំ គឺថាក្រុមនេះបានសាកសួរកូនប្រុសរបស់ខ្ញុំអំពីព័ត៌មានលម្អិតពិតប្រាកដដែលពួកគេបានទទួលពីនគរបាលកម្ពុជា។ «បន្ទាប់ពីព័ត៌មាននេះបែកធ្លាយ គាត់ត្រូវបានបញ្ជូនទៅក្រុមហ៊ុនមួយផ្សេងទៀតពីការហៅទូរស័ព្ទជាមួយកូនប្រុសរបស់ខ្ញុំកាលពីប៉ុន្មានថ្ងៃមុន ដោយគាត់បានប្រាប់ខ្ញុំថា គាត់ត្រូវបានផ្ទេរទៅក្រុមទី

បីម្តងផ្សេងទៀត»។ កូនប្រុសរបស់អ្នកស្រី Wong ត្រូវបានគេជឿថាបានចូលមកប្រទេសកម្ពុជាដោយខុសច្បាប់ពី Penang កាលពីខែវិច្ឆិកាឆ្នាំមុន។ "ខ្ញុំបានលឺថាជនរងគ្រោះមួយចំនួនត្រូវបានដោះលែង បន្ទាប់ពីក្រុមគ្រួសាររបស់ពួកគេបានបង់ថ្លៃលោះ។ ប៉ុន្តែ លុយ ១៣,០០០ដុល្លា គឺជាចំនួនដ៏ច្រើនសម្រាប់ខ្ញុំ ហើយទុក្ខលំបាកនោះនឹងមិនបញ្ចប់ត្រឹមនោះទេ»។ អ្នកស្រី Wong ធ្លាប់បានប្រាប់ព័ត៌មានលម្អិតអំពីបញ្ហារបស់កូនប្រុសនាងទៅកាន់ប្រធានសេវាកម្មសាធារណៈ MCA លោក Michael Chong កាលពីខែមីនា។ បន្ទាប់ពីការផ្សព្វផ្សាយជាសាធារណៈអំពីករណីនេះ ជនជាតិម៉ាឡេស៊ីចំនួន ១៦ នាក់ត្រូវបានជួយសង្គ្រោះពីខេត្តព្រះសីហនុក្នុងប្រទេសកម្ពុជា និងបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ។

លោក Chong បានអះអាងថា ក្មេងជំទង់ពីរនាក់ទៀតត្រូវបានគេជួយសង្គ្រោះពីក្រុមនោះ ប្រហែល៣សប្តាហ៍មុន។ លោកបានមានប្រសាសន៍ថា "ពួកគេកំពុងស្ថិតនៅក្នុងប្រទេសកម្ពុជា ហើយកំពុងរង់ចាំដំណើរការរៀបចំឯកសារ ហើយសង្ឃឹមថានឹងត្រូវបានបញ្ជូនមកប្រទេសវិញ នៅសប្តាហ៍ក្រោយ"។

ខ្មែរថាមស៍ បានលាតត្រដាងពីក្រុមការងារនៃក្រុមបោកប្រាស់ទាំងនេះ ដែលត្រូវបានគេបោក មកប្រទេសកម្ពុជា ដើម្បីធ្វើការនៅក្នុងកន្លែងលេងល្បែងស៊ីសងខុសច្បាប់តាមប្រព័ន្ធអ៊ីនធឺណែត ដែលប្រតិបត្តិការរបស់ពួកគេនៅតែជាស្រមោល និងបំភាន់ភ្នែក។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់នគរបាលកម្ពុជា ជាមួយនឹងស្ថានទូតបរទេសផ្សេងទៀត ដូចជា ម៉ាឡេស៊ី ថៃ ឥណ្ឌូនេស៊ី ប៉ាគីស្ថាន វៀតណាម បាននាំអោយមានការដោះលែងមនុស្សរាប់សិបនាក់ ប្រសិនបើមិនបានរាប់រយនាក់នៃអ្នកដែលគេបង្ខាំងខ្លួន។ ទោះជាយ៉ាងណាក៏ដោយ មនុស្សជាច្រើនទៀតនៅតែធ្វើការជាមួយក្រុមនោះ ហើយមនុស្សជាច្រើនត្រូវបានគេរាយការណ៍ថាមិនចង់ចាកចេញដោយហេតុផលផ្សេងៗ ដែលភាគច្រើនគឺជាផលចំណេញដែលពួកគេទទួលបាន ប្រសិនបើពួកគេអាចសម្រេចគោលដៅដែលបានកំណត់៕

## កម្លាំងនគរបាលការពារព្រំដែនគោក ទទួលប្រជាពលរដ្ឋវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ស្រុកសំពៅលូន

https://gdlf-kh.com/ 30/05/2022 Sam Sophearum បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៨ និង០០នាទី នាថ្ងៃចន្ទ ១៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន២៦នាក់ ស្រី៨នាក់ ក្មេងស្រី២នាក់ ។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឲ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្ពែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ៕